ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * * * *


ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សាកលវិទ្យាល័យភូមិន្ទកសិកម្ម

មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម

* * * * *

ម៉ី មុនីសេដ្ឋា


# ការអភិវឌ្ឍន៍សហគមន៍នៅខេត្តបន្ទាយមានជ័យ

# COMMUNITY DEVELOPMENT IN BANTEAY MEANCHEY PROVINCE


ជំនាន់ទី ៨

១៩៩១ – ១៩៩៥

សារណាបញ្ចប់ការសិក្សា

ភ្នំពេញ ,ខែ ធ្នូ ឆ្នាំ ១៩៩៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
* * * * *

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
សាកលវិទ្យាល័យភូមិន្ទកសិកម្ម
មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម
* * * * *

ម៉ី មុនីសេដ្ឋា

# ការអភិវឌ្ឍន៍សហគមន៍នៅខេត្តបន្ទាយមានជ័យ

# COMMUNITY DEVELOPMENT IN BANTEAY MEANCHEY PROVINCE

សមាសភាពគណៈមេប្រយោគ

| | | |
|---|---|---|
| ប្រធានគណៈមេប្រយោគ | : | លោក ចាន់ ណារ៉េត |
| អ្នកដឹកនាំ | : | លោក ទ្រី ម៉េង |
| អ្នកជំនួយការ | : | លោក លាត សំណាង |
| អ្នកជំនួយការ | : | លោក ខៃ សត្យា |

ជំនាន់ទី ៨
១៩៩១ – ១៩៩៥

សារណាបញ្ចប់ការសិក្សា
ភ្នំពេញ ,ខែ ធ្នូ ឆ្នាំ ១៩៩៥

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * * * *

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សាកលវិទ្យាល័យភូមិន្ទកសិកម្ម

មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម

* * * * *

អនុញ្ញាតអោយការពារគំរោង

សាកលវិទ្យាល័យ

ថ្ងៃទី 2 DEC NOV 1995 ឆ្នាំ ១៩៩

ចាន់ ណាវ៉េត

# ការអភិវឌ្ឍន៍សហគមន៍នៅខេត្តបន្ទាយមានជ័យ

# COMMUNITY DEVELOPMENT IN BANTEAY MEANCHEY PROVINCE

គំរោងយកបរិញ្ញាប័ត្រក្សេត្រវិទ្យ

ឈ្មោះនិស្សិត : ម៉ី មុនីសេដ្ឋា ...................

ព្រឹទ្ធបុរសមហាវិទ្យាល័យ : លោក ផាត់ មុនី ...................

អ្នកដឹកនាំគំរោង : លោក ឡូវ ម៉េង ...................

អ្នកជំនួយការ : លោក លាត សំណាង ...................

អ្នកជំនួយការ : លោក ខៃ សត្យា ...................

ជំនាន់ទី ៨

១៩៩១–១៩៩៥

សារណាបញ្ចប់ការសិក្សា

ភ្នំពេញ , ខែ ធ្នូ ឆ្នាំ ១៩៩៥

មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម ពុំមានយោបល់លើមតិដែល
មាននៅក្នុងសារណានេះទេ ។
បណ្ដាមតិទាំងឡាយក្នុងសារណានេះចាត់ទុកជាមតិផ្ទាល់របស់អ្នកនិពន្ធ ។

ព្រឹទ្ធបុរស

សាកលវិទ្យាធិការ

ចាន់ ណារ៉ែត

# សេចក្តីថ្លែងអំណរព្រះគុណ និងថ្វាយព្រះពរ

ទូលបង្គំ **ម៉ី មុនីសេដ្ឋា**

**សូមក្រាបថ្វាយបង្គំ**

**ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន**
**ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងព្រះអគ្គមហេសី**

សូមថ្លែងព្រះអំណរព្រះករុណាទិគុណ សម្តេចជាអម្ចាស់ជីវិតលើត្បូង ដែលបានបំពេញព្រះរាជបេសកកម្មបង្រួបបង្រួមជាតិ ប្រទានសន្តិភាពដល់ប្រទេសជាតិ ពិសេសប្រទានវរោកាសដល់ កូនចៅ និងទូលបង្គំបានសិក្សា រហូតបានសំរេចជោគជ័យ ។ ទូលបង្គំសូមថ្វាយព្រះពរ សូមព្រះអង្គទ្រង់ព្រះចំរើនព្រះជន្មាយុទីឃាយឺនយូរជាងរយព្រះវស្សា ។

# សេចក្តីថ្លែងអំណរគុណ

* * * *

ខ្ញុំបាទឈ្មោះ **ម៉ី មុនីសេដ្ឋា** និស្សិតជំនាន់ទី ៨ មហាវិទ្យាល័យវិទ្យាសាស្រ្តកសិកម្ម នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ចំការដូង ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ÷

– រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

– ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

– សាកលវិទ្យាល័យភូមិន្ទកសិកម្ម

–មន្ទីរកសិកម្ម និងការិយាល័យក្សេត្រសាស្រ្តកសិកម្មខេត្តបន្ទាយមានជ័យ

–អង្គការ CARERE OPS

ដែលបានអនុញ្ញាត និងផ្តល់លទ្ធភាពអោយខ្ញុំបាទចូលរៀន ក្រេបជញ្ជក់នូវចំណេះដឹងវិទ្យាសាស្រ្តទាំងឡាយ ព្រមទាំងបង្កលក្ខណៈងាយស្រួលដល់ការសិក្សាស្រាវជ្រាវ ផ្តល់នូវកន្លែងស្នាក់នៅ ហូបចុក សំភារៈ ថវិកា និងផ្តល់ឯកសារស្រាវជ្រាវវិទ្យាសាស្រ្តក្នុងពេលធ្វើកម្មសិក្សារហូតទទួលបានជោគជ័យជាស្ថាពរ ។

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ÷

| | | | |
|---|---|---|---|
| – ឯកឧត្តម | តាវ | សេងហួរ | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| – ឯកឧត្តម | ដួង | ខែម | អភិបាលខេត្តបន្ទាយមានជ័យ |
| – លោក | ចាន់ | ណារ៉េត | សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| – លោក | ផាត់ | មុនី | សាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| – លោក | ឃួន | អៀង | ព្រឹទ្ធបុរសរងមហាវិទ្យាល័យវិទ្យាសាស្រ្តកសិកម្ម នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម |

ដែលបានបង្កលក្ខណៈងាយស្រួលដល់ការសិក្សា ជួយដាស់តឿនណែនាំក្នុងរយៈពេលសិក្សា ៤ឆ្នាំកន្លងមក ។

| | | | |
|---|---|---|---|
| – លោក | ទ្រី | ម៉េង | ជាអ្នកដឹកនាំ |
| – លោក | លាភ | សំណាង | ជាអ្នកជំនួយការ |
| – លោក | ខៃ | សត្យា | ជាអ្នកជំនួយការ |

– បុគ្គលិកអង្គការ ព្រមទាំងបុគ្គលិកកសិកម្មទាំងអស់

និងមិត្តរួមឯកទេស និងមិត្តរួមសាកលវិទ្យាល័យភូមិន្ទកសិកម្ម ដែលបានជួយពន្យល់ណែនាំអំពីការសរសេរសារណាបទ និងជួយអប់រំទូន្មានបង្ហាត់បង្រៀន ព្រមទាំងបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាងរហូតដល់ខ្ញុំបាទបានបញ្ចប់ការសិក្សាជាស្ថាពរ ។

# សេចក្តីថ្លែងអំណរគុណ

* * * *

ដោយកត្តញ្ញូតាធមិ និងទឹកចិត្តគោរពស្រឡាញ់យ៉ាងធំធេង ខ្ញុំបាទជាកូន បង និង ជាប្អូន សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះ :

- លោកឪពុក ម៉ី ណាយ
- អ្នកម្តាយ ខៃត ស្រ៊ាន

ដែលបានផ្តល់កំណើតចិញ្ចឹមទំនុកបំរុង និងអប់រំកូនរហូតបានបញ្ចប់ការសិក្សាជាស្ថាពរ ។

- បងប្រុស ម៉ី មុនីបូរិន្ទ
- បងស្រី ម៉ី មុនីមាលី
- បងស្រី ម៉ី មុនីចិន្តា
- ប្អូនស្រី ម៉ី មុនីកញ្ញា
- ប្អូនស្រី ម៉ី មុនីសុខា

ដែលបានជួយទំនុកបំរុងដល់ការសិក្សារបស់ខ្ញុំ ។

# សង្ខេបសារណា

* * * *

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសដែលពឹងផ្អែកលើវិស័យកសិកម្ម ដើម្បី អភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម ជាពិសេសសង្គមជនបទដែលមានប្រជាជនប្រមាណ ៨៥ ភាគរយ រស់នៅ និងប្រកបរបរ ចិញ្ចឹមជីវិត ដោយយករបរកសិកម្ម ចិញ្ចឹមសត្វជារបរសំខាន់នឹងចំបង ។

ដើម្បីធ្វើការសិក្សាវាយតំលៃអោយបានត្រឹមត្រូវ នូវកិច្ចអភិវឌ្ឍន៍សហគមន៍ស្រុកមង្គលបូរី ជាបឋមបានសិក្សាស្រាវជ្រាវស្គាល់ពីតំបន់ ព្រមជាមួយគ្នានឹងការស្វែងរកអោយឃើញនូវបញ្ហារបស់កសិករ ដើម្បីឈានទៅរកការបង្កើតឡើងនូវទិសដៅ និងផែនការសំរាប់ការអភិវឌ្ឍន៍ ។

បញ្ហាដែលរកឃើញមាន :

- ប្រជាកសិករខ្វះទឹកប្រើប្រាស់ក្នុងគ្រួសារ និងផលិតកម្មដំណាំ
- ដីខ្វះជីជាតិផូស្វាត (P) ពុំអំណោយផលល្អដល់ដំណាំ
- ជួបប្រទះជម្ងឺរុក្ខជាតិ និង សត្វ
- ការខ្វះខាតនូវការយល់ដឹងអំពីបច្ចេកទេសកសិកម្មជឿនលឿន
- ការខ្វះខាតពូជសត្វល្អៗ
- ការខ្វះខាតថ្នាំសង្កូវសំរាប់ព្យាបាលជម្ងឺប្រជាកសិករ
- ការខ្វះខាតអុសដុត
- តំបន់ខ្លះអសន្តិសុខ និងដីបង្កប់ដោយមីន បង្កផលវិបាកដល់កសិករក្នុងការដាំដំណាំផ្សេងៗ
- ការខ្វះខាតសំភារៈកសិកម្ម
- មិនអាចរកចំណូលអ្វីបានក្រៅពីរបរកសិកម្ម

ការសិក្សាអំពីសកម្មភាពការងារដែលមណ្ឌលបានអនុវត្តកន្លងមក បានបង្ហាញអោយឃើញនូវប្រព័ន្ធការងារអភិវឌ្ឍន៍ក្នុងតំបន់នេះ ដូចជា : ការបង្កើតគណៈកម្មការអភិវឌ្ឍន៍ស្រុក ឃុំ ភូមិ ប្រធានក្រុម ការបង្កើតក្រុមឥណទានកសិកម្ម , ការចូលរួមរបស់កសិករ , ការចូលរួមពីសំណាក់រដ្ឋអំណាចមូលដ្ឋាន , ដែលមានទំនាក់ទំនងគ្នាមិនអាចកាត់ផ្តាច់បាន ដើម្បីឈានរកដំណោះស្រាយ ពោលគឺធ្វើអោយមានការរីកចំរើននូវផ្នែកផលិកម្ម កសិកម្ម និងធ្វើអោយកើនឡើងនូវប្រាក់ចំណូលប្រចាំគ្រួសារ ការងារអប់រំផ្សាយ និងការចូលរួមរបស់កសិករ គឺជាការងារសំខាន់បំផុតដែលធ្វើអោយកើនឡើងជាបន្តបន្ទាប់នូវបច្ចេកទេសវិទ្យាសាស្ត្រជឿនលឿនសមស្របក្នុងស្រទាប់កសិករ ហើយបង្កើនឡើងនូវភាពមានជំនឿលើសម្ថភាពផ្ទាល់ខ្លួន ។

ឆ្លងតាមការសិក្សាពិនិត្យឃើញ :

–ផ្នែកផលិតកម្មដំណាំ កសិករបានចាប់ដំណើរការកែប្រែរបៀបដាំដុះដោយបញ្ចូលបច្ចេកទេសកសិកម្មសមស្របក្នុងផលិតកម្ម ។

–ផ្នែកចិញ្ចឹមសត្វ កសិករបានអនុវត្តជាបណ្តើរៗនូវការចិញ្ចឹមតាមបច្ចេកទេស

–ផ្នែកធារាសាស្ត្រ ប្រព័ន្ធធារាសាស្ត្រ ជាបញ្ហាសំខាន់បំផុតសំរាប់ការងារអភិវឌ្ឍន៍កសិកម្ម ដោយសារតែការខូចខាតយ៉ាងធ្ងន់ធ្ងរ បណ្តាលមកពីទឹកជំនន់ និងភាពរាំងស្ងួត ដែលកើនឡើងជាញឹកញាប់ ។

–ផ្នែកឥណទានកសិកម្ម ត្រូវបានឧបត្ថម្ភដោយអង្គការ CARERE និងអង្គការ NGO,S ក្នុងស្រុក កសិករមានលទ្ធភាពទទួលបាននូវប្រភពទុនដើម្បីធ្វើអោយកើនឡើងនូវផលិតកម្មដំណាំស្រូវ និងផលិកម្មបន្លែ ។

–ការប្រើប្រាស់ទឹកស្អាតមានប្រជាជនប្រមាណ ១៥ ភាគរយ នៃប្រជាជនជនបទទាំងអស់ ហេតុនេះហើយអង្គការ CARERE អាចជីកអណ្តូងដៃនិងអណ្តូងខ្វងដល់ប្រជារាពលរដ្ឋ ។

–ផ្នែកយល់ដឹងពីកម្មវិធីអភិវឌ្ឍន៍ជនបទរបស់កសិករកាន់តែកើនឡើងជាលំដាប់ ពីមួយថ្ងៃទៅមួយថ្ងៃ ។

ឆ្លងតាមរយៈការខ្វះខាតត្រូវបំពេញតាមសំណូមពរដូចតទៅ :

–បង្កើនការអប់រំផ្សព្វផ្សាយតាមរយៈការធ្វើបង្ហាញ ប៉ុន្តែការបង្ហាញគួរតែជាគំរូដ៏ល្អ

–ការផ្តល់រង្វាន់ ឬ សរសើរលើកទឹកចិត្តចំពោះកសិករដែលមានស្នាដៃ

–ការស្នើអោយរៀបចំធ្វើក្រោលគោ– ទ្រុងជ្រូកតាមផ្ទះកសិករដើម្បីជៀងវាងការលែងសត្វអោយដើររកស៊ីសេរី ។

–ការស្នើអោយអ្នកផ្សព្វផ្សាយក្នុងក្រុមអភិវឌ្ឍន៍បង្កើន (ការរៀនសូត្រ) ជានិច្ចនូវកំរិតយល់ដឹង និងទេពកោសល្យផ្ទាល់ខ្លួន ។

–ការស្នើអោយអ្នកអប់រំផ្សព្វផ្សាយក្រើនរំលឹកអោយបានញឹកញាប់នូវគ្រប់ការអនុវត្តដែលបានកែប្រែហើយដល់កសិករ ។

–ការស្នើអោយបង្កើនការអប់រំផ្សព្វផ្សាយដល់កសិករខ្លះដែលគេនៅមិនទាន់យល់ច្បាស់ពីគោលបំណងនៃកម្មវិធីអភិវឌ្ឍន៍ ។

ការសិក្សាវាយតំលៃកិច្ចអភិវឌ្ឍន៍សហគមន៍ស្រុកមង្គលបូរី គឺជាការចូលរួមយ៉ាងតូចមួយក្នុងការធ្វើអោយកើតមានដំបូងបំផុតនូវកម្មវិធីសិក្សាអំពីអភិវឌ្ឍន៍សហគមន៍ដោយឈានចេញពីនេះ យើងខ្ញុំសង្ឃឹមថាទៅថ្ងៃអនាគតនឹងមានអ្នកសិក្សាកែលំអ និងសិក្សាស្រាវជ្រាវបន្តដើម្បីអោយកាន់តែមានសុក្រឹត–ភាព ។

# មាតិកាអត្ថបទ

* * *


សេចក្តីថ្លែងអំណរគុណ

សង្ខេបសារណា

មាតិកាអត្ថបទ

បញ្ជីរូបរូបភាព

សេចក្តីផ្តើម

ទំព័រ

## ផ្នែកទី ១

## សំយោគអត្ថបទ និង ការស្រាវជ្រាវឯកសារ

**ជំពូក ១ : សំយោគបណ្ណាល័យសាស្ត្រ**

១ យល់ដឹងអំពីអភិវឌ្ឍន៍ជនបទ ........................................ ១

១.១ គោលគំនិតនៃការអភិវឌ្ឍន៍ជនបទ........................................ ១៥

១.១.១ ការចូលរួមសង្កេតស្ថានការណ៍ជនបទ PRA ........................................ ១៨

១.១.២ គោលដៅនៃការចូលរួមសង្កេតស្ថានការណ៍ជនបទ (PRA)........................ ១៨

១.១.៣ តួនាទីនិងការចូលរួមរបស់ប្រជាជនក្នុង PRA ........................................ ១៨

១.១.៤ វិធីសាស្ត្រប្រើប្រាស់ក្នុង PRA ........................................ ១៨

១.១.៥ យុទ្ធវិធីរបស់ PRA ........................................ ១៩

១.១.៦ បិតុនិយម........................................ ២០

១.១.៧ គោលបំណងនៃកម្មវិធីអប់រំផ្សព្វផ្សាយកសិកម្ម ........................................ ២១

១.១.៨ អំពីតួនាទីភារកិច្ចរបស់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម........................................ ២១

១.១.៩ ការកែប្រែស្ថានភាពរបស់កសិករ និងប្រជាជនរស់នៅតាមជនបទអោយប្រសើរឡើង ........................................ ២២

## ផ្នែកទី ២

## ការងារស្រាវជ្រាវ

**ជំពូក ២ : របៀបស្រាវជ្រាវ**

២.១ របៀបស្រង់ពតិមាន ........................................ ២៥

២.២ ការប្រមូលទិន្នន័យ ........................................ ២៥

២.៣ ការបកស្រាយទិន្នន័យ ........................................ ២៥
២.៤ ការវិភាគទិន្នន័យ ........................................ ២៦
២.៥ ភាពខុសឆ្គងនៃការស្រាវជ្រាវ ........................................ ២៦
ជំពូក ៣ : ស្ថានភាពទូទៅនៃខេត្តបន្ទាយមានជ័យ
១ ស្ថានភាពទូទៅ ........................................ ២៧
២ ទីតាំងភូមិសាស្ត្រ ........................................ ២៧
៣ ស្ថិតិប្រជារាស្ត្រ ........................................ ២៧
៤ ស្ថិតិសត្វ ........................................ ២៧
៥ ធាតុអាកាស ........................................ ២៨
៥.១ សីតុណ្ហភាព ........................................ ២៨
៥.២ គ្រោះធម្មជាតិ ........................................ ២៨
៥.៣ កំពស់ទឹកភ្លៀង ........................................ ២៨
ជំពូក ៤ : ស្ថានភាពទូទៅស្រុកមង្គលបូរី
១ ស្ថានភាពទូទៅ ........................................ ៣០
២ ទីតាំងភូមិសាស្ត្រ ........................................ ៣០
៣ លក្ខខ័ណ្ឌសេដ្ឋកិច្ច កសិកម្ម ........................................ ៣១
៣.១ ផ្នែកដាំដុះ ........................................ ៣១
៣.១.១ ដំណាំស្រូវ ........................................ ៣១
៣.១.២ ដំណាំឆ្លងកាត់ ........................................ ៣២
៣.១.៣ ដំណាំឧស្សាហកម្ម ........................................ ៣២
៣.១.៤ ការចិញ្ចឹមសត្វ ........................................ ៣២
៣.១.៥ ការងារជលផល ........................................ ៣៣
៣.១.៦ ការងាររុក្ខកម្ម ........................................ ៣៣
ជំពូក ៥ : សិក្សាអំពីសកម្មភាពការងារដែលតំបន់បានអនុវត្តកន្លងមក
៥.១ ការងារចាប់ផ្តើម ........................................ ៣៤
៥.២ គោលបំណងធ្វើអភិវឌ្ឍន៍ ........................................ ៣៤
៥.៣ របៀបធ្វើការអភិវឌ្ឍន៍ ........................................ ៣៤
៥.៣.១ គណៈកម្មការអភិវឌ្ឍន៍ ........................................ ៣៤
ក–គោលបំណងនៃការបង្កើតគណៈកម្មការអភិវឌ្ឍន៍ ........................................ ៣៥
ខ–អំពីរចនាសម្ព័ន្ធ និង រូបភាពចាត់ចែងគណៈកម្មការអភិវឌ្ឍន៍ ........................................ ៣៥

គ–របនាសម្ព័ន្ធចាត់តាំងគណៈកម្មការអភិវឌ្ឍន៍ ................................ ៣៧
ឃ–អំពីតួនាទីគណៈកម្មការអភិវឌ្ឍន៍ ................................ ៣៨
ង–ភារកិច្ចរបស់គណៈកម្មការអភិវឌ្ឍន៍................................ ៣៨
៥.៤ ការសហការពីប្រជាជន ................................ ៣៩
៥.៥ ការសហការពីរដ្ឋអំណាចមូលដ្ឋាន ................................ ៣៩
៥.៥.១ ការដាំដុះនៅស្ថានីយ៍ចំការឈើហូបផ្លែនៅស្រុកមង្គលបូរី ................................
៥.៥.២ ការងារធារាសាស្ត្រ................................
៥.៦ កម្មវិធីផលិតពូជស្រូវ ................................ ៤២
១–ទំនាក់ទំនងជាមួយរដ្ឋអំណាចស្រុក ឃុំ ភូមិ ជាពិសេសគណៈកម្មការអភិវឌ្ឍន៍ភូមិ ៤២
២–គោលបំណង ................................ ៤២
៣–តំបន់ចំណុច ................................ ៤២
ក–ការជ្រើសរើសភូមិ ................................ ៤៣
ខ–ការជ្រើសរើសកសិករចូលរួម ................................ ៤៣
ឃ–តួនាទីប្រធានក្រុម ................................ ៤៣
ង–ការប្រើប្រាស់ឥណទាន ................................ ៤៣
ច–ការខ្ចីប្រាក់ ................................ ៤៤
ឆ–លក្ខខ័ណ្ឌនៃការខ្ចីប្រាក់ ................................ ៤៤
ជ–វិធីសង ................................ ៤៤
៥.៧ ការងារអប់រំផ្សព្វផ្សាយបច្ចេកទេស និងការចូលរួមរបស់ប្រជាជន................ ៤៤
ក–ការអប់រំផ្សព្វផ្សាយជាលក្ខណៈប្រមូលផ្តុំ ................................ ៤៥
ខ–ការអប់រំផ្សព្វផ្សាយចំពោះកសិករតាមលំនៅដ្ឋាន ................................ ៤៥
គ–ការអប់រំផ្សព្វផ្សាយតាមរយៈការធ្វើទស្សនកិច្ច................................ ៤៥
៥.៨ កម្មវិធីឥណទានបន្លែ ................................ ៤៥
១–ទំនាក់ទំនងជាមួយរដ្ឋអំណាច ................................ ៤៥
២–កំណត់គោលដៅបង្កើតឥណទានបន្លែ ................................ ៤៥
៣–គោលដៅកម្មវិធីឥណទានដាំបន្លែ ................................ ៤៦
៤–ការជ្រើសរើសចំណុច ................................ ៤៦
ក–ការជ្រើសរើសភូមិ ................................ ៤៦
ខ–ការជ្រើសរើសកសិករចូលរួម ................................ ៤៦
៥ រៀបចំក្រុម ................................ ៤៧

៦ ទំហំថវិកា .................................................................. ៤៧

៧ កាលបរិច្ឆេទនៃការខ្ចី និង សង ................................................. ៤៨

៨ ការខ្ចីប្រាក់ .................................................................. ៤៨

**ជំពូក ៦ កម្មវិធីអភិវឌ្ឍន៍របស់អង្គការ CARERE . OPS**

៦.១ គោលបំណង និង ទិសដៅជាយុទ្ធសាស្ត្ររបស់កម្មវិធី.......................... ៥០

៦.១.១ តំបន់ជាទិសដៅកំណត់.................................................... ៥១

៦.១.២ ទំហំកម្មវិធី .................................................................. ៥២

៦.២ យុទ្ធវិធីដំណើរការរបស់កម្មវិធី .................................................. ៥៣

៦.២.១ ការអភិវឌ្ឍន៍សហគមន៍ ...................................................... ៥៤

៦.២.២ ផលិតកម្មកសិកម្ម / ប្រាក់ចំណូល និងការងារ.............................. ៥៦

៦.២.៣ ឥណទាន ...................................................................... ៥៩

៦.២.៤ សុខភាព ...................................................................... ៦១

៦.២.៥ ហេដ្ឋារចនាសម្ព័ន្ធជនបទ.................................................... ៦៣

៦.២.៦ ទឹក និង អនាម័យ .............................................................. ៦៤

សេចក្តីសន្និដ្ឋាន

សំណូមពរ

បណ្ណាល័យសាស្ត្រ

# បញ្ជីវិចិត្ររូប

* * *

**ផែនទី**

ផែនទីស្រុកមង្គលបូរី.................................................. ៣០

**រូបថត**

រូបថតទី ១ : ការចិញ្ចឹមគោនៅភូមិគយម៉ែង ឃុំឫស្សីក្រោក ស្រុកមង្គលបូរី..............
រូបថតទី ២ : សិប្បកម្មធ្វើអង្រឹងនៅភូមិប្រលាយល្វងក្រោម...........................
រូបថតទី ៣ : សកម្មភាពដកស្មៅបែកក្បាលនៅភូមិប្រលាយល្វងក្រោម..................
រូបថតទី ៤ : សកម្មភាពបាញ់ថ្នាំសំលាប់កាជីបនៅភូមិប្រាយល្វងក្រោម...................
រូបថតទី ៥ : សកម្មភាពបង្រៀនដំណាំឈើហូបផ្លែនៅចំការដើមឈើភូមិជំទាវ............
រូបថតទី ៦ : ការជីកអណ្តូងដៃរបស់កសិករនៅឃុំរស្សូតឧបត្ថម្ភដោយអង្គការ CARERE...

**ក្រាហ្វិច**

ក្រាហ្វិច : កំពស់ទឹកភ្លៀង........................................................ ២៩



# សេចក្តីផ្តើម

ព្រះរាជាណាចក្រកម្ពុជាជាប្រទេសកំពុងអភិវឌ្ឍន៍ ដែលមានសេដ្ឋកិច្ចជាតិផ្អែកទៅលើវិស័យកសិកម្ម ដែលមានប្រជាពលរដ្ឋ ៨៥ភាគរយ ជាកសិកររស់នៅជនបទប្រកបមុខរបរកសិកម្ម ។ ប្រទេសកម្ពុជាបានឆ្លងកាត់សង្គ្រាមជាច្រើនឆ្នាំមកហើយ ហេដ្ឋារចនាសម្ព័ន្ធត្រូវខូចខាតទាំងស្រុង ធ្វើអោយកសិករមានជីវភាពខុសគ្នាយ៉ាងខ្លាំងរវាងជនបទ និងទីក្រុង ។

ក្រោយពីបោះឆ្នោតទូទៅក្នុងឆ្នាំ ១៩៩៣ រដ្ឋាភិបាលបានបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីជួយសំរួលជំនួយអន្តរជាតិ និងជួយដោះស្រាយលើកស្ទួយជីវភាពប្រជាជននៅជនបទ ដោយអនុវត្តនូវកម្មវិធីចំរុះ ក្នុងនោះបញ្ហាសំខាន់ចំពោះមុខនៃការងារអភិវឌ្ឍន៍ជនបទសង្កត់ធ្ងន់ទៅលើវិស័យកសិកម្ម ។ ការអភិវឌ្ឍន៍កសិកម្មក្នុងភូមិណាមួយ អាស្រ័យលើកត្តាច្រើនយ៉ាងដូចជា អាកាសធាតុ , ស្ថានភាពដី , គុណភាពគ្រាប់ពូជ , សត្វល្អិត , ជម្ងឺ , បរិមាណទឹក ការចែកចាយទឹកតាមរដូវ , លក្ខណៈមួយចំនួនរបស់ដី ដែលក្នុងនោះ មានទំរង់ដី , ជីជាតិដី , លទ្ធភាពរក្សាសំណើម និងជាតិជូរនៃដី ។ ចំពោះកសិករ ដើម្បីធ្វើអោយ លក្ខខ័ណ្ឌទាំងនេះបានល្អប្រសើរ គាត់ត្រូវមានសំភារៈ កសិកម្មសមស្រប សត្វពាហនៈ ,ជី ,ថ្នាំសំលាប់សត្វ ល្អិត , ថវិកា និង ប្រភពកំលាំងពលកម្ម អោយបានទាន់ពេលវេលា , ទីផ្សារងាយស្រួល , ការដឹកជញ្ជូនល្អ, ការស្តុកម្ហូបរយៈ ភាពងាយកែច្នៃ , តំលៃសមស្រប និងជាពិសេសការយល់ដឹងអំពីបច្ចេកទេសកសិកម្មជឿនលឿន ។ កិច្ចការអភិវឌ្ឍន៍កសិកម្មដូចជាមានភាពលំបាកស្មុគស្មាញណាស់ នៅពេលយើងដឹងថា គ្រប់ លក្ខខ័ណ្ឌខាងលើត្រូវតែធ្វើអោយសំរេចសំរាប់កសិករកម្ពុជា ដែលជាអ្នកប្រកាន់ភ្ជាប់នូវទំនៀមទំលាប់បុរាណ គ្មានទំលាប់កែប្រែមិនហ៊ានប្រថុយប្រថាន និងគ្មានការដឹកនាំអោយកែប្រែផង ។ ហេតុដូច្នេះហើយ អ្វីដែល ទាមទារចាំបាច់នៅក្នុងការធ្វើអភិវឌ្ឍន៍កសិកម្ម គឺភ្នាក់ងារអប់រំផ្សព្វផ្សាយប្រកបដោយការយល់ដឹង ហើយទន្ទឹមនឹងនោះ ក៏ទាមទារផងដែលនូវទេពកោសល្យផ្ទាល់ខ្លួន ។

យើងខ្ញុំសុំលើកយកនូវការអភិវឌ្ឍន៍ជនបទមួយកន្លែងនៅតំបន់អភិវឌ្ឍន៍ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ បានចាប់ដំណើរការពីថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩៤ ក្រោមកិច្ចសហប្រតិបត្តិការរវាងមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត និងអង្គការសហប្រជាជាតិ **UNDP- CARERE** ក្នុងគោលបំណងបញ្ចូលបច្ចេកទេសវិទ្យាសាស្ត្រសមស្របសំរាប់ការអភិវឌ្ឍន៍ផលិតកម្មជាមូលដ្ឋាន ដើម្បីការរីកចំរើននៃជីវភាពរស់នៅរបស់ប្រជាកសិករ និងជួយអោយកសិករបានយល់ ហើយចេះដោះស្រាយបញ្ហាដោយខ្លួនឯង ។

# ផ្នែកទី ១

# សំយោគអត្ថបទ

# និង ការស្រាវជ្រាវឯកសារ

## ១. យល់អំពីអភិវឌ្ឍន៍ជនបទ

### ១.១. គោលគំនិតនៃការអភិវឌ្ឍន៍ជនបទ

ប្រជាជនក្រីក្រគោកយ៉ាកក្នុងប្រទេសកម្ពុជា ភាគច្រើនដែលរស់នៅជនបទ និងមានអាជីពពឹងផ្អែកទៅលើរបរកសិកម្ម ។ អភិវឌ្ឍន៍ជនបទគឺជាចលករ (កំលាំង ឬ សេចក្តី ព្យាយាម) សំរាប់កែលំអស្ថានភាព ជីវភាពរស់នៅរបស់ប្រជាជនទាំងនោះអោយប្រសើរឡើង និងរៀបចំដំណើរការអោយគេរស់នៅដោយខ្លួនឯង ។ គោលគំនិតថ្មីនៃការអភិវឌ្ឍន៍ជនបទបានបន្ថែមនូវផែនការជាច្រើនទៀតពីលើការពង្រីកផលិតកម្មកសិកម្ម ។ អភិវឌ្ឍន៍ជនបទលើកឡើងនូវសំណួរស្តីពីការចែកចាយមិនមែនត្រឹមតែផលិតកម្មប៉ុណ្ណោះទេ។ អ្នកខ្លះត្រូវការអោយគេសួរថា អ្នកណាយកអ្វី ? គឺជាសំនួរមួយដែលនាំអោយគេគិតអំពីការកែប្រែក្នុងការអប់រំ សង្គមដែលស្ថិតនៅក្នុងភាពគ្មានដីស្រែ និងកាន់តែធ្ងន់ធ្ងរទៅទៀត គឺព្រំដែនទំនោរចំពោះបច្ចេកវិជ្ជា ព្រោះហេតុនេះហើយគោលគំនិតអប់រំនៃអភិវឌ្ឍន៍ជនបទមិនមែនកំណត់ព្រំដែនត្រឹមតែការបង្កើនផលិតកម្មកសិកម្មប៉ុណ្ណោះទេ ប៉ុន្តែរួមបញ្ចូលទាំងការងារទូលំទូលាយដែលទាក់ទងនឹងប្រាក់ចំណូលកសិករ និងកត្តាផ្សេងៗដែលមានឥទ្ធិពលទៅលើការចែកចាយប្រភពទុន (មូលនិធិធម្មជាតិ និង ជំនួយ) ។ អភិវឌ្ឍន៍ជនបទដែលយើងចង់បាន គឺទាក់ទងជាមួយកសិករ និងប្រជាជនដែលមានតួនាទីសំខាន់ក្នុងការអនុវត្តតាមការងារអភិវឌ្ឍន៍ ដែលមានតួនាទីក្នុងការអនុវត្តតាមការងារអភិវឌ្ឍន៍ ។ យើងដឹងច្បាស់ថាការចុះក្រីក្របានកើតឡើងស្របគ្នានិងការដុះដាលសេដ្ឋកិច្ចនៅកន្លែងជាច្រើន ។ ផ្ទុយទៅវិញស្ថានភាពនេះនឹង កែប្រែផ្លាស់ប្តូរយ៉ាងហោចណាស់អ្នកក្រីក្រត្រូវរៀបចំឡើង និងអាចបំពេញនូវតំរូវការរបស់គេ ។ ព្រោះហេតុនេះគោលបំណងនៃការអភិវឌ្ឍន៍ជនបទរបស់យើងគឺត្រូវផ្តល់អំណាចដល់អ្នកក្រីក្រនៅជនបទដើម្បីអោយគេ មានលទ្ធភាពលើកកំរិតជីវភាពរបស់គេអោយល្អឡើង និងធ្វើអោយដំណើរការអភិវឌ្ឍន៍មានតំលៃជានិច្ច ។

ទ្រឹស្តីនៃការអភិវឌ្ឍន៍ជនបទរាប់បញ្ចូលរាល់ធាតុសេដ្ឋកិច្ច និងសង្គមដែលមានច្រើននៅក្នុងជីវភាពនៃតំបន់ជនបទ ហើយមានឥទ្ធិពលទៅលើប្រាក់ចំណូលនៃប្រជាជនជនបទ ។

កត្តាទាំងនោះមានទំនាក់ទំនងដោយផ្ទាល់ (មានក្នុងរូបភាពខាងក្រោម) ទៅនឹងប្រភពធនធាន (ដី ទឹក មូលធន ) ទំនាក់ទំនងទៅនឹងបច្ចេកវិជ្ជា (ការផ្សព្វផ្សាយកសិកម្មកែច្នៃគ្រាប់ពូជអោយល្អ ការអប់រំស្រាវជ្រាវវិសាធារណៈ) ការជ្រើសរើសយុទ្ធវិធី (ដំណាំចំរុះ និងការជ្រើសរើស ) ទំនាក់ទំនងទៅនិងវិស័យទូលាយ ក្រៅពីសកម្មភាពកសិកម្ម (សុខភាព , អប់រំ , ការផលិតចំណីអាហារអភិវឌ្ឍន៍ពាណិជ្ជកម្ម) ។

ក–<u>កត្តាតូច</u> ( **Micro factors** )




(រូបទី ១)

ខ–<u>កត្តាធំ</u> (**Macro factors**)




(រូបទី ២ )

តារាងកត្តាតូចៗ និងកត្តាធំៗ នៃប្រាក់ចំណូលរបស់កសិករ ពុំបានបញ្ជាក់ពីទំនាក់ទំនងក្នុងចំណោមកត្តាទាំងនោះទេ ដូច្នេះយើងសូមបង្ហាញពីទំនាក់ទំនងនេះខាងក្រោម ÷

រូបភាពបង្ហាញពីទំនាក់ទំនងកត្តាតូចៗ និងកត្តាធំៗ ជាមួយប្រាកចំណូលរបស់កសិករ

ប្រកបដោយទំនោរនៃកត្តាកំណត់




ប្រកបដោយទំនោរនៃកត្តាកំណត់ក៏រិតធំ

(រូបទី ៣)

ស្តែងចេញពីកត្តាទាំងអស់ខាងលើ គោលបំណងដំបូងបង្អស់របស់អភិវឌ្ឍន៍ជនបទ គឺត្រូវធ្វើយ៉ាងណាដើម្បីដោះស្រាយអោយបាននូវការចាំបាច់ជាមូលដ្ឋានរបស់ប្រជាជន ។ ប្រជាជនស្ទើរគ្រប់វប្បធម៌បានឯកភាពគ្នាថា : ស្បៀងអាហារសមស្រេបជាក់លាក់មួយ , ការស្លៀកពាក់ត្រឹមត្រូវ និងជំរកជា

ការចាំបាច់របស់សុខភាពមនុស្ស ។ ការយកចិត្តទុកដាក់ផ្នែកវេជ្ជសាស្ត្រ ទឹកស្អាត និងអនាម័យចាំបាច់ សំរាប់សុខភាពល្អ អាចត្រូវបានចាត់ទុកដែរថាជាសេចក្តីត្រូវការជាមូលដ្ឋាន ។ ក្រៅពីអភិវឌ្ឍន៍ជនបទ នៅមានគោលបំណងគាំទ្រប្រជាជននូវសញ្ញេតនាយុត្តិធម៌សង្គម នូវសញ្ចេតនាពាក់ព័ន្ធនឹងអ្នកដទៃ និងនូវសញ្ចេតនាស្មោះស្ម័គ្រ និង ទៀងត្រង់ ។

**១.១.១.ការចូលរួមសង្កេតស្ថានការណ៍ជនបទ «ParticipatryRural ppraisal(PRA)**

**PRA** គឺជាបែបផែននៃការសិក្សាសង្កេតពាក់កណ្តាលរចនាសម្ព័ន្ធជាមួយប្រជាជននៅតាមជនបទ ស្តីអំពីស្ថានភាពរស់នៅរបស់ពួកគេ , បញ្ហានានា និងលទ្ធភាពដោះស្រាយបញ្ហា , លទ្ធភាពបង្កើត និងច្នៃប្រឌិតរបស់ពួកគេ ។

**១.១.២. គោលដៅរបស់ PRA**

មានគោលដៅចំបងពីរ :

-បង្កើតអោយមានការចូលរួមគ្រប់និន្នាការក្នុងមូលដ្ឋាន ដើម្បីអោយមានការឆ្លើយតបកាន់តែច្រើនពីប្រជាកសិករក្នុងមូលដ្ឋាន តាំងពីស្ថានភាពរស់នៅ និងប្រព័ន្ធបរិស្ថានវិទ្យាក្នុងមូលដ្ឋាន ។

-ការវិវត្តន៍លើវិធីសាស្ត្រមួយដែលអាចនឹងផ្តល់នូវពត៌មានទាន់ពេលវេលា និងមានប្រសិទ្ធភាព ។ ផ្អែកលើពត៌មានតាមរយៈ **PRA** យើងអាចដំណើរការនូវសកម្មភាពចាំបាច់ៗ ទាំងឡាយដើម្បីអភិវឌ្ឍន៍ ។ **PRA** អាចឆ្លើយតបទៅនឹងសេចក្តីត្រូវការចាំបាច់នានា ហេតុនេះវាមានតួនាទីសំខាន់ក្នុងការងារអភិវឌ្ឍន៍ ជាពិសេសចំពោះការងារអភិវឌ្ឍន៍ដែលធានាបាននូវភាពយូរអង្វែង ។

**១.១.៣. តួនាទី និងការចូលរួមរបស់ប្រជាជនក្នុង PRA**

-ការស្វែងយល់ពីស្ថានការណ៍នានា

-ការវិភាគបញ្ហា

-ការអនុវត្តសកម្មភាពនានាដើម្បីអភិវឌ្ឍន៍

-ការត្រួតពិនិត្យ និងការវាយតំលៃ

ដូច្នេះ**PRA** ជាវិធីសាស្ត្រសំខាន់ដែលអាចជំរុញអោយមានការចូលរួមតាមបែបផែននេះ ។

**១.១.៤. វិធីសាស្ត្រប្រើប្រាស់ក្នុង PRA**

-ការធ្វើសំភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធ

-ការស៊ើបអង្កេត

-ការបង្ហាញ អធិប្បាយដោយរូបភាព

វិធីសាស្ត្រនេះ ត្រូវបានគេប្រើក្នុង **PRA** ព្រោះថាប្រជាកសិកររស់នៅជនបទភាគច្រើនមិនចេះអក្សរ ។ ការបង្ហាញដោយរូបភាពនេះជួយសំរួលអោយអ្នកដែលមិនចេះអក្សរទទួលបាននូវទស្សនៈវិស័យដែលគេកំពុងចូលរួមពិភាក្សា , ទន្ទឹមនឹងនេះក៏ជាការធានាមួយដែលពួកគេអាចចូលរួមយ៉ាងសកម្មក្នុងការផ្តល់ពត៌មាន ព្រមទាំងការវិភាគពត៌មានទាំងនោះ ។

### ១.១.៥. យុទ្ធវិធីរបស់ PRA

ក–កាលប្បវត្តិ (Time Line) : វាជួយយើងក្នុងការស្វែងយល់អំពីប្រវត្តិរបស់ភូមិ សហគមន៍ សកម្មភាពបាតុភូតផ្សេងៗ ។ ល ។

ខ–ទិន្នាការ (Trends) : វាជួយយើងក្នុងការស្វែងយល់នូវការផ្លាស់ប្តូរប្រវត្តិរចនាសម្ព័ន្ធ, បាតុភូត , ទំនាក់ទំនង ។ល។

គ–ការគូរផែនទីសង្គម ( Social mapping ) : ផែនទីសង្គមអាចជួយយើងនូវរូបភាពច្បាស់លាស់របស់រចនាសម្ព័ន្ធភូមិខឿនសេដ្ឋកិច្ចប្រជាជន លក្ខណៈវប្បធម៌សង្គម ព្រមទាំងពត៌មានពិស្តារផ្សេងៗទៀត ដែលអាចបង្ហាញនៅលើផែនទី ។

ឃ–ការធ្វើផែនទីប្រភពធនធាន : វាអាចជួយសំរួលដល់ការសិក្សាអំពីដី , ព្រៃឈើ , ទឹក និងធនធានផ្សេងទៀតដែលមាននៅក្នុង ឬ ជុំវិញភូមិ ។ វាអាចជួយក្នុងការធ្វើផែនការអភិវឌ្ឍន៍កសិកម្មព្រៃឈើ ។ល។

ង–តារាងសិក្សាតាមរដូវកាល (Seasionalty Study ) : ការសិក្សានេះបង្ហាញអោយយើងយល់នូវការខុសប្លែកគ្នាពីរដូវមួយទៅរដូវមួយនៃសកម្មភាពបាតុភូតអ្វីមួយ ដូចជាកំរិតទឹកភ្លៀង , លទ្ធភាពកំលាំងពលកម្ម ,ការងារកសិកម្ម ,ពិធីបុណ្យ ,ការចំណាយ ,ប្រាក់ចំណូល ,រយៈពេល ខ្វះខាតជីវភាពរស់នៅ ។

ច–ការហូរនៃធនធាន : ដើម្បីសិក្សាពីអ្វីដែលជាធនធានហូរចូលមកក្នុងភូមិ គ្រួសារ , កសិដ្ឋានពីកន្លែងណា ? មានចំនួនប៉ុន្មាន ? និងអ្វីដែលហូរចេញពីគ្រួសារ , កសិដ្ឋាន ទៅណា ? ចំនួនប៉ុន្មាន ជាទំរង់បែបដូចម្តេច ? ការសិក្សាអំពីលក្ខណៈនេះ យើងអាចយល់ពីជីវភាពសេដ្ឋកិច្ចរបស់អ្នកភូមិ បញ្ហាផ្សេងៗ និងលទ្ធភាពនានា ។

វាជួយដល់ការធ្វើផែនការសកម្មភាពសេដ្ឋកិច្ច ឧស្សាហកម្មប្លែកៗ លើកសិផលហ៊ឹកហ៊ឺនជំនាញ ។

ឆ–ចំណាត់ថ្នាក់ទ្រព្យធន : គឺជាការស្វែងយល់ស្ថានភាពសេដ្ឋកិច្ចសង្គមរបស់មនុស្សម្នាក់ ឬ ក៏គ្រួសារមួយ ។

ជ–ការវិភាគជីវភាព : វាជាវិធីមួយមិនជាផ្លូវការ និងពាក់កណ្តាលរចនាសម្ព័ន្ធក្នុងការស្រង់យកពត៌មានសេដ្ឋកិច្ចសង្គមរបស់គ្រួសារមួយ ។

ការសង្កេតស្ថានភាពក្នុងផ្ទះ ការកាត់បន្ថយការសួរសំណួរមួយចំនួន ។ ការអនុវត្តនេះអាចជួយអោយយើងយល់ដឹងពីវិធីដែលប្រជាជនដោះស្រាយបញ្ហាជីវភាពរបស់គេ ។

ឈ–ការកត់ត្រាក្នុង PRA (ជាចំណុចសំខាន់) ត្រូវកត់ត្រាពីអ្វី ? (បន្ថែមទៅលើ , អ្នកណា , ទីណា , និងពេលវេលា

–គោលដៅនៃការធ្វើ PRA

–សង្ខេបដំណើរការ

-ការចងក្រងទិន្នន័យជាក់ស្តែង

-និទានកថា ( **Narrative** )

* ជំនួយដល់ទិន្នន័យជារូបភាព

* បង្ហាញនូវការវិភាគ

* កត់ត្រាផែនការ បើសិនជាមាន

-សំយោគពត៌មានទាំងអស់

ដោយមានការបកស្រាយដើម្បីបង្ហាញនូវរូបភាពចំណុះមួយដែលជួយដល់ការធ្វើផែនការ និងសកម្មភាពពេលខាងមុខ ។

ញ- **Rapid Rural Apprasal ( PRA )**

គឺជាវិធីសាស្រ្តនៃការស្ទាបស្ទង់ មានបញ្ជីសំណួរត្រឹមត្រូវ អាចសង្កេតតាមរយៈការមើលផែនទី សួរផ្ទាល់ជាមួយកសិករ ឬ អង្កេតតាមផ្សារហាងទំនិញផ្សេងៗ អាចប្រមូលពត៌មាន ។

### ១.១.៦. ចិត្តនិយម

បិតុនិយមគឺជាការត្រួតពិនិត្យប្រជាជនដោយឧបត្ថម្ភសេចក្តីត្រូវការរបស់ប្រជាជន ប៉ុន្តែមិនបានជួយអោយប្រជាជនមានម្ចាស់ការទទួលខុសត្រូវដោយខ្លួនឯង ។ អ្វីដែលយើងធ្វើសំរាប់ប្រជាជនហើយអ្វីដែលយីងធ្វើនោះ ប្រជាជនអាចធ្វើសំរាប់ខ្លួនគេបាន ហៅថាបិតុនិយម ។

បិតុនិយម អាចជា :

-អំណោយ (ដូចជាសំភារៈ , គ្រាប់ពូជ , អាហារ)

«ប្រជាជនមិនថែរក្សារបស់ដែលគេមិនបានរកដោយការខំប្រឹងប្រែងរបស់គេឡើយ »

( **two ears of corn** )

«ប្រាក់មិនមែនជាគ្រឿងលើកទឹកចិត្តសំរាប់ប្រើប្រភពមូលដ្ឋានឡើយ »

-ការបំរើប្រជាជន (ដូចជា ការកសាងផែនការ, ជួយផ្តល់អ្នកបច្ចេកទេសពីខាងក្រៅ , ការផ្លាស់ប្តូរប្រព័ន្ធមូលដ្ឋាន )

«ប្រជាជនកំរនឹងឆ្លៀតក្នុងការដោះស្រាយបញ្ហារបស់គេណាស់ ប្រសិនបើកម្មវិធីមួយកំពុងដោះស្រាយនូវបញ្ហាសំរាប់គេហើយនោះ »

<u>តើហេតុអ្វីបានជាបិតុនិយមធ្វើអោយខូចប្រយោជន៍</u>

-ប្រជាជនបាត់បង់នូវជំនឿលើសមត្ថភាពផ្ទាល់ខ្លួនរង់ចាំ តែលើជំនួយខាងក្រៅ

-បង្កើតការបែងចែក និងវិសមភាពចំពោះប្រជាជន

-បង្វែរការចាប់អារម្មណ៍ពីការស្វែងរកដំណោះស្រាយ

-បង្កើនបុព្វហេតុខុស

-កំណត់ឱកាសក្នុងការពង្រីកកំរៃចំណេញគ្រប់កន្លែង

### ១.១.៧. គោលបំណងនៃកម្មវិធីអប់រំផ្សព្វផ្សាយកសិកម្ម

–សំដៅជួយកសិករអោយបង្កើននូវផលិតផល និងប្រាក់ចំណូលផ្សេងទៀតរបស់គាត់អោយកាន់តែប្រសើរឡើងថែមទៀត ។

–ជួយកសិករក្នុងការទទួលយកបច្ចេកវិជ្ជាថ្មី និងវិធីសាស្ត្រថ្មីៗ សំរាប់ផលិតកម្មកែច្នៃ និងការលក់ដូររបស់គាត់ ។

–ជួយកសិករអោយចេះលៃលក ធ្វើការផ្លាស់ប្តូរ និងអាចកត់សំគាល់នូវការផ្លាស់ប្តូរដែលប្រព្រឹត្តទៅនឹងកន្លែងដទៃទៀត ដើម្បីធ្វើការកែប្រែរបៀបរបបកសិកម្មបែបបុរាណមួយចំនួនលែងសមស្រប ។

–ជួយកសិករដោយធ្វើយ៉ាងណាបំភ្លឺអោយច្បាស់លាស់ដល់កសិករក្នុងស្រុករបស់គេថា គាត់បានយល់ច្បាស់អំពីស្ថានភាពបច្ចុប្បន្ន គោលបំណងតំរូវការ និង បញ្ហាលំបាករបស់កសិករ ។

–បង្កើននូវភាពយល់ដឹងដល់កសិករចំពោះលទ្ធភាពថ្មី ជំរុញការយកចិត្តទុកដាក់បច្ចេក–ទេសថ្មី ។

–ផ្តល់ពត៌មានចំពោះកសិករនៅពេលដែលគាត់ត្រូវការ និងក្នុងមធ្យោបាយដែលធ្វើអោយកសិករអាចយល់បាន ។

–ចាត់តាំងអប់រំ និងជំរុញកសិករអោយប្រកាន់យកនូវការទទួលខុសត្រូវសំរាបការអភិវឌ្ឍន៍សហគមន៍របស់គាត់ផង ។

### ១.១.៨. អំពីតួនាទីភារកិច្ចរបស់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម

ករណីយកិច្ចរបស់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម គឺ :

* ជួយកសិករអោយបង្កើនផលិតផលប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ច និងអាចផ្តល់ប្រាក់ចំណេញដល់ពួកគេ ។

* ជួយដល់កសិករ និងប្រជាជនទូទាំងប្រទេសអោយមានស្បៀងគ្រប់គ្រាន់ និងសុខុមាលភាព

តួនាទីរបស់ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម គឺ កំណត់រកអោយឃើញពីតំរូវការបញ្ហាលំបាកឱកាសរបស់កសិករ និងប្រជាជនរស់នៅតាមជនបទតាមរយៈ ÷

ក–ការជួប និងជជែកពិភាក្សាជាប្រចាំជាមួយកសិករម្នាក់ៗក្តី , ជាមួយក្រុមកសិករក្តី អំពីការងារអនុវត្ត និងបញ្ហាលំបាកក្នុងវិស័យកសិកម្ម ។

ខ–ការប្រមូល និងវិភាគពត៌មានអំពីស្ថានភាពក្នុងពេលបច្ចុប្បន្នរបស់ពួកគេ និងអំពីមធ្យោបាយផ្សេងៗដែលអាចកែប្រែស្ថានភាពនោះអោយល្អឡើង ។

គ–តាមដានអោយជាប់លើពត៌មានអំពីការស្រាវជ្រាវ និងការអភិវឌ្ឍន៍ផ្សេងៗ ដែលអាចមានអត្ថប្រយោជន៍ដល់កសិករក្នុងពេលបច្ចុប្បន្ន និងទៅអនាគត ។

១.១.៩.ការកែប្រែស្ថានភាពរបស់កសិករ និងប្រជាជនរស់នៅតាមជនបទអោយប្រសើរ

ឡើង តាមរយៈ ÷

– ការស្តាប់ និងឆ្លើយតបនឹងតំរូវការ និងបញ្ហាលំបាកដែលកសិករលើកឡើងតាមរបៀបដ៏គួរសម , ងាយយល់ និងមានអត្ថប្រយោជន៍ ។

–ការឆ្លើយតបទៅនឹងសំណួមពរ , ផ្តល់ពត៌មានអោយរហ័ស និងស្មោះត្រង់បំផុតទៅតាមសមត្ថភាពដែលខ្លួនមាន ។

–ការផ្តល់អោយកសិករនូវពត៌មានទាន់ពេលវេលា ដែលអ្នកជឿថាអាចមានអត្ថប្រយោជន៍ចំពោះពួកគេ តាមរយៈប្រើប្រាស់វិធីសាស្ត្រ ផ្តល់ពត៌មានតាមបែបនិយាយអត្ថបទសរសេរ និងរូបភាពបដា និងប្រព័ន្ធឃោសនាដែលសមស្រប ។

–ការដើរតួជាអ្នកប្រភពពត៌មានដោយការប្រើប្រាស់ជំនាញឯកទេស និងបទពិសោធន៍របស់អ្នកដទៃទៀតនៅពេលចាំបាច់ ។

ក–នាំចូលនូវវិធីសាស្ត្រថ្មី ជឿនលឿន និងសមស្របសំរាប់ការងារកសិកម្ម ការកែច្នៃនិងការធ្វើចរាចរណ៍ផលិតកម្មកសិកម្ម តាមរយៈ ÷

–ការធ្វើតេស្តសាកល្បង ការវាយតំលៃ និងការធ្វើបង្ហាញអំពីបច្ចេកវិជ្ជាទាំងនេះមុនពេលផ្សព្វផ្សាយវាកសិករទទួលយកទៅអនុវត្តជាទូទៅ ។

–ការបង្កើតគំរោងកម្មវិធី ដោយឈរលើមូលដ្ឋាននៃការវិភាគស្ថានភាពរបស់អ្នក ដែលក្នុងនោះមានគូសបញ្ជាក់យ៉ាងច្បាស់លាស់អំពីគោលបំណង និងគោលដៅ (កម្មវត្ថុ) ដែលអាចវាស់វែងបាន ។

ខ–សំរបសំរួលដល់ការ អភិវឌ្ឍន៍សហគម , ការអប់រំនិងការផ្តល់អំណោយដល់ប្រជាជនដែលរស់នៅតាមជនបទ តាមរយៈ ÷

–ការជួយប្រជាជនដែលរស់នៅជនបទ , ជាបុគ្គលម្នាក់ក្តី , ជាក្រុមក្តីក្នុងការវិភាគ និងស្វែងយល់អំពីឫសគល់នៃបញ្ហាលំបាករបស់ពួកគេ និងមធ្យោបាយអ្វីដែលពួកគេអាច ជួយខ្លួនពួកគេបានតាមរយៈការចុះបញ្ជាំងទៅលើ និងរៀនសូត្រពីបទពិសោធន៍ដែលពួកគេមាន ។

–ជួយពួកកសិករអោយរៀនសូត្រអំពីទេព្យកោសល្យនៃការងារចូលរួម ការធ្វើគំរោងផែនការ ការរៀបចំចាត់ចែង ការគ្រប់គ្រង និងការវាយតំលៃគំរោងកម្មវិធីរបស់គេផ្ទាល់ ។

–ការដើរតួរជាអ្នក «ប្រភព» ដែលអាចជួយផ្តល់គំនិតពត៌មាន និងធនធានមួយចំនួនដែលប្រជាជនអាចត្រូវការក្នុងការកែប្រែស្ថានភាពរបស់គេអោយប្រសើរឡើង ។

គ–ភាពទទួលខុសត្រូវរបស់ភ្នាក់ងារអប់រំផ្សព្វផ្សាយកសិកម្មគឺ :

* ជាអ្នកដែលមានសមត្ថភាព និងប្រសិទ្ធភាពខ្ពស់ក្នុងតួនាទីរបស់អ្នកជាភ្នាក់ងារផ្សព្វផ្សាយម្នាក់ ។

* ជាអ្នកដែលស្នេហាជាតិ និងមានជំនាញឯកទេសដែលធ្វើជាគំរូល្អៗដល់អ្នកដទៃទៀត តាមរយៈធ្វើខ្លួនអោយទៅជាមនុស្សមានអត្ថប្រយោជន៍ , ស្មោះត្រង់ , រាបសារ , គួរអោយទុកចិត្តបាន និងគោរព ពេលម៉ោងនៅក្នុងការបំពេញករណីយកិច្ចរបស់ខ្លួន ។

* ធ្វើការដោយឯករាជ្យ ម្ចាស់ការដោយគ្មានការត្រួតត្រាពីអ្នកដទៃ ទៅតាមតួនាទីរបស់អ្នកជាភ្នាក់ងារផ្សព្វផ្សាយកសិកម្មអោយបានយ៉ាងតិច ៣០ ម៉ោង ក្នុងមួយសប្តាហ៍ ។

* រក្សាទុកនូវកំណត់ត្រាប្រចាំថ្ងៃ ស្តីពីចលនា (ការធ្វើដំណើរ) និងសកម្មភាពរបស់អ្នករៀងរាល់ថ្ងៃ ដែលក្នុងនោះមានឈ្មោះភូមិ និងកសិករដែលបានទៅទស្សនា , ចំងាយផ្លូវធ្វើដំណើរ , ប្រេងឥន្ធនៈដែលទិញ និងគណនី ឬ ប័ណ្ណចំណាយទាំងអស់ដែលទាក់ទងនឹងការបំពេញករណីកិច្ចរបស់អ្នក ។

* រៀបចំរបាយការណ៍ប្រចាំខែ មួយច្បាប់សំរាប់អ្នកសំរបសំរួលសេវាផ្សព្វផ្សាយខេត្ត និងមួយច្បាប់ទៀតរក្សាទុកជាឯកសារផ្ទាល់ខ្លួន (សរុប ២ ច្បាប់ ) ។

* ចូលរួមប្រជុំ , សន្និសីទ , សិក្ខាសាលា , វគ្គអនុវត្តខ្លីៗ តាមសំណូមពររបស់អ្នកសំរបសំរួលសេវាផ្សព្វផ្សាយខេត្ត ។

# ផ្នែកទី ២

# ការចារសិក្សា

# ស្រាវជ្រាវអនុវត្ត

## ជំពូក ២

## របៀបស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវអំពីសង្គមជនបទ ជាការងារមួយលំបាកស្មុគស្មាញ ហើយទាមទាររយៈពេលវែង ។ ឯការសិក្សាស្រាវជ្រាវពីជំហានដំបូងនៃការអភិវឌ្ឍន៍សមាគមន៍ក្នុងខេត្តបន្ទាយមានជ័យ យើងបានធ្វើការស្រាវជ្រាវស្រង់ពត៌មាន និងអង្កេតជាលំដាប់លំដោយ អំពីបញ្ហារួមពីថ្នាក់ខេត្ត ស្រុក ឃុំ រហូតដល់ភូមិ ដើម្បីស្វែងយល់ពីស្ថានភាពទូទៅស្តីពីសង្គមរស់នៅ ជំនឿសាសនា ធនធានធម្មជាតិ ។ល។ តាមបណ្តាថ្នាក់និមួយៗ ដើម្បីធ្វើវិភាគរកបញ្ហាចម្បងដែលត្រូវដោះស្រាយក្នុងគោលដៅឈានទៅរកការស្តារនិងអភិវឌ្ឍន៍សហគមន៍ ។

### ២.១. របៀបស្រង់ពត៌មាន

ចំពោះពត៌មានតាមខេត្ត ស្រុក និងឃុំ យើងបានស្រង់តាមមាតិកាអត្ថបទស្តីពីផ្នែកនិមួយៗ ដោយចោទសួរផ្ទាល់ ។

ដើម្បីស្រង់ពត៌មាន យើងបានរៀបចំជាបញ្ជីសំណួរដែលមានទាំងអស់ ៩៨ សំណួរ ដោយចែកជា ៦ ផ្នែក គឺ :

ផ្នែកទី I អំពីគ្រួសារ

ផ្នែកទី II អំពីផលិតកម្មដំណាំ

ផ្នែកទី III អំពីប្រភពទឹក

ផ្នែកទី IV អំពីផ្នែកចិញ្ចឹមសត្វ

ផ្នែកទី V អំពីកម្មវិធីឥណទាន

ផ្នែកទី V I អំពីស្ថានភាពសេដ្ឋកិច្ច

(សំណួរទាំងអស់ត្រូវបានភ្ជាប់នៅចុងបញ្ចប់សារណាជាឧបសម្ព័ន្ធទី ....

### ២.២. ការប្រមូលទិន្នន័យ

គឺជាការពង្រាយចំលើយទាំងអស់ដែលបានស្រង់

បាននាំកសិករមកដាក់ក្នុងតារាងរួមធំមួយទៅ តាមប្រភេទចំលើយ ។

### ២.៣. ការបកស្រាយទិន្នន័យ

ចំលើយទាំងអស់របស់កសិករ ត្រូវដាក់តំរៀបទៅតាមប្រភេទថ្នាក់ក្រុម ដោយត្រូវបានគណនាជាភាគរយ ។

**២.៤. ការវិភាគទិន្នន័យ**

ក្រោយពីបានធ្វើការបកស្រាយទិន្នន័យរួចហើយ យើងបានចាប់ផ្តើមលើកទិន្នន័យទាំងនោះមកវិភាគរកអោយឃើញឫសគល់នៃបញ្ហា និងធ្វើសំណូមពរក្នុងជំហានដំបូងនៃកិច្ចអភិវឌ្ឍន៍សហគមន៍ដែលជាវិធានការដែលត្រូវដោះស្រាយ ដើម្បីសំរេចគោលដៅនៃកិច្ចអភិវឌ្ឍន៍សហគមន៍ទៅថ្ងៃមុខអោយមានប្រសិទ្ធភាពកាន់តែខ្ពស់ ។

**២.៥–ភាពខ្វះខាតនៃការស្រាវជ្រាវ**

–ជាការស្រាវជ្រាវលើកដំបូង (បទពិសោធន៍មានតិច)

–រយៈពេលខ្លី ការសិក្សាស្រាវជ្រាវពុំបានគ្រប់គ្រាន់

# ជំពូក ៣

## ស្ថានភាពទូទៅនៃខេត្តបន្ទាយមានជ័យ

**១— ស្ថានភាពទូទៅ :**

ខេត្តបន្ទាយមានជ័យគឺជាខេត្តមួយថ្មីទើបបង្កើតឡើងក្នុងសម័យរដ្ឋកម្ពុជា ក្នុងឆ្នាំ ១៩៨៨ ដោយ កាត់ចេញពីភូមិសាស្ត្រខេត្តបាត់ដំបងចំនួន ៥ ស្រុក និងភូមិសាស្ត្រខេត្តសៀមរាបចំនួនមួយស្រុក ។

ក្រោយមករាជរដ្ឋាភិបាលបានរៀបចំរចនាសម្ព័ន្ធរដ្ឋបាលគ្រប់គ្រងរបសខេត្តទៅជា ៨ស្រុក រួមមាន :

- –ស្រុកមង្គលបូរី
- –ស្រុកសេរីសោភ័ណ
- –ស្រុកភ្នំស្រុក
- –ស្រុកព្រះនេត្រព្រះ
- –ស្រុកអូរជ្រៅ
- –ស្រុកស្វាយចេក
- –ស្រុកថ្មពួក
- –ស្រុកបន្ទាយអំពិល

**២—ទីតាំងភូមិសាស្ត្រ :**

ខេត្តបន្ទាយមានជ័យមានផ្ទៃដីសរុប ៧៨១.៥០០ ហិកតា ក្នុងនោះផ្ទៃដីបង្កបង្កើនផល ២២៤.៥៥០ ហិកតា ផ្ទៃដីភ្នំសរុប ៣៥១.៦១២ ហិកតា និងស្ទឹង ត្រពាំង បឹងបួរ លំនៅដ្ឋាន ចំនួន ២៥០.៣៣៨ ហិកតា ។

ខេត្តបន្ទាយមានជ័យមានព្រំប្រទល់ :

- –ខាងជើងជាប់ប្រទេសថៃ
- –ខាងត្បូងជាប់ខេត្តបាត់ដំបង
- –ខាងលិចជាប់ប្រទេសថៃ
- –ខាងកើតជាប់ខេត្តសៀមរាប

បន្ទាយមានជ័យមានចំងាយពីភ្នំពេញ ៣៦១ គីឡូម៉ែត្រ តាមផ្លូវជាតិលេខ ៥ ។

**៣—ស្ថិតិប្រជារាស្ត្រ :**

ប្រជារាស្ត្រទាំងខេត្តចំនួន ១០០.៤៧៤ គ្រួសារ មនុស្សរាយសរុប : ៥០៦.៥៦៦ នាក់ ក្នុងនោះ ស្រី : ២៦២.២៧៧ នាក់ ។

**៤—ស្ថិតិសត្វ :**

ក្នុងខេត្តបច្ចុប្បន្នមានសត្វពាហនៈសរុប : ១៣៣.៤២៣ ក្បាល កំលាំងអូសទាញសរុប : ៦៣.៣៣៨ ក្បាល ។ ចំពោះសត្វដែលនៅសេសសល់ពីកំលាំងអូសទាញ គឺសំរាប់ការផលិតកូន និង ផ្គត់ផ្គង់ជាស្បៀងអាហារ តែនៅមិនទាន់ឆ្លើយតបតាមតំរូវការប្រើប្រាស់ និងការហូបចុករបស់ប្រជារាស្ត្រ ប្រមាណ ៥០៦.៥៦៦ នាក់ ដែលមាននៅក្នុងខេត្ត ។

## ៥– ធាតុអាកាស :

ខេត្តបន្ទាយមានជ័យ ក៏ដូចជាប្រទេសកម្ពុជាទាំងមូល មានអាកាសធាតុត្រូពិច ដែលទទួលរបបខ្យល់មូសុងបក់កាត់យ៉ាងទៀតទាត់ បង្កើតបានជារដូវធំៗពីរ គឺរដូវប្រាំង និងរដូវវស្សា ។

–រដូវប្រាំងចាប់ផ្តើមពីខែ វិច្ឆិកា ដល់ខែ មេសា ដែលមានខ្យល់មូសសុងប្រាំងបក់កាត់ពីឥសានទៅនិរតី ចេញពីប្រភពស៊ីបេរីទៅសមុទ្រឥណ្ឌា ដោយពុំមាននាំទឹកភ្លៀងមកជាមួយទេ ។

ប៉ុន្តែរដូវប្រាំងបានបែងចែកជាពីររដូវទៀតគឺ រដូវរំហើយ ចាប់ពីខែ វិច្ឆិកា ដល់ខែ មករា និង រដូវក្តៅ ចាប់ពីខែ កុម្ភៈ ដល់ខែ មេសា ដែលជារដូវធ្វើអោយរុក្ខជាតិស្វិតស្រពោន ។

–រដូវវស្សាចាប់ផ្តើកពីខែ ឧសភា ដល់ខែ តុលា ដែលមានខ្យល់មូសុងវស្សា បក់កាត់ពីនិរតីទៅឥសាន មានប្រភពពីសមុទ្រឥណ្ឌា នាំទឹកភ្លៀងមកជាច្រើនបក់សំដៅទៅស៊ីបេរី ។

### ៥.១–សីតុណ្ហភាព :

តាមការងារអនុវត្តន៍របស់ស្ថានីយ៍ឧត្តុនិយម និងជលសាស្រ្តកងរ៉ាខេត្តបន្ទាយមានជ័យ ដែលទើបចាប់ផ្តើមកសាងស្ថានីយ៍នេះបានវាស់សិតុណ្ហភាពក្នុងដីដែលមានជំរៅ០,១ ម៉ែត្រ , ០,២ ម៉ែត្រ និង ០,៦ ម៉ែត្រ ។

ក្នុងនោះស្ថានីយ៍ទើបសាកល្បងអនុវត្តក្នុងខែ កក្កដា និង សីហា ឆ្នាំ ១៩៩៥ នេះ ដែលតាម របាយការណ៍បានអោយដឹងថា សីតុណ្ហភាពជាមធ្យមប្រចាំខែ នាចន្លោះពី ៣០ អង្សា ទៅ ៣០,២ អង្សា ។

### ៥.២–គ្រោះធម្មជាតិ :

នៅរដូវវស្សាឆ្នាំ ១៩៩៤ កន្លងទៅនេះ ដើមរដូវមានគ្រោះទឹកជំនន់នៅតំបន់មួយចំនួននៃខេត្តបន្ទាយមានជ័យ និងរាំងស្ងួតនៅចុងរដូវបង្កបង្កើនផល មូលហេតុដោយសារការកាប់ព្រៃឈើធ្វើអោយប្រែប្រួលបរិស្ថាន បង្កអោយទឹកភ្លៀងធ្លាក់មិនទៀងទាត់ និងមិនគ្រប់គ្រាន់ ។

៥.៣– កំពស់ទឹកភ្លៀង :

តាមឯកសារដែលទទួលបានពីអង្គការ **CARERE** ហើយដែលមានប្រភពពីការិយាល័យជលសាស្រ្ត នៃមន្ទីរកសិកម្មខេត្តបន្ទាយមានជ័យបានបង្ហាញពីទិន្នផលកំពស់ទឹកភ្លៀងគិតពីឆ្នាំ ១៩៨៨–១៩៩៣ **VS** ១៩៩៤ ដែលបង្ហាញតាមក្រាហ្វិចខាងក្រោម ÷

សរុបកំពស់ទឹកភ្លៀងខែ និងមធ្យមឆ្នាំ 1988 - 93 ពេលនិងឆ្នាំ 1994



# ជំពូក ៤

## ស្ថានភាពទូទៅស្រុកមង្គលបូរី

### ១—ស្ថានភាពទូទៅ :

មង្គលបូរីជាស្រុកមួយស្ថិតនៅក្នុងខេត្តបន្ទាយមានជ័យ ហើយមានការរីកចំរើនជាងបណ្តាស្រុកនានា ពិសេសការងារកសិកម្ម ។

ស្រុកមង្គលបូរីមានប្រព័ន្ធធារាសាស្ត្រខ្វាត់ខ្វែង ដោយយកប្រភពទឹកស្ទឹងមង្គលបូរី សំរាប់ស្រោចស្រពដំណាំស្រូវទាំងរដូវប្រាំង និងរដូវវស្សា ។ ស្រុកមានបណ្តាញផ្លូវគមនាគមន៍តូចធំគ្រប់គ្រាន់សំរួលក្នុងការធ្វើដំណើរ ។

### ២—ទីតាំងភូមិសាស្ត្រ :

ស្រុកមង្គលបូរីមានទីតាំងរដ្ឋបាលក្នុងឃុំឫស្សីក្រោក ស្ថិតតាមបណ្តោយផ្លូវជាតិលេខ ៥ ត្រង់ចំណុចយាយជីច្រូតស្រូវ ។ ស្រុកនេះមានចំងាយប្រមាណ ៩ គីឡូម៉ែត្រ ពីទីរួមខេត្តបន្ទាយមានជ័យ ។

\+ ព្រំប្រទល់ :

– ខាងជើងទល់នឹងទីរួមខេត្តបន្ទាយមានជ័យ និង ស្រុកព្រះនេត្រព្រះ

– ខាងកើតទល់នឹងស្រុកព្រះនេត្រព្រះ

– ខាងត្បូងទល់នឹងស្រុកបាត់ដំបង និង ស្រុកបវេល

– ខាងលិចទល់នឹងស្រុកបវេល និងស្រុកសិរីសោភ័ណ

\+ ផ្ទៃដីសរុប : ៧២.៥០០ ហិកតា ក្នុងនោះ ÷

| | | |
|---|---|---|
| – ផ្ទៃដីបង្កបង្កើនផល | : | ៤៥.០០០ ហិកតា |
| – ផ្ទៃដីព្រៃ | : | ៩.០០០ ហិកតា |
| – ផ្ទៃដីលំនៅដ្ឋាន | : | ៣.៨៥៩,២០ ហិកតា |
| – ផ្ទៃដីស្ទឹងបឹងបួរ | : | ១៤.៦៤០,៨០ ហិកតា |

ស្រុកមង្គលបូរីចែកជា ១៣ ឃុំ , ១៥៦ ភូមិ , ២៥.០៧៧ គ្រួសារ មនុស្សរាយ : ៩២៧ នាក់ ក្នុងនោះ ប្រុស ៦២.២៣២ នាក់ ស្រី : ៦៧.៦៩៥ នាក់ ។

| | | |
|---|---|---|
| សមាសភាពជនជាតិ | : | |
| – ចិន ប្រហែល | : | ២ ភាគរយ |
| – ឡាវ ប្រហែល | : | ២,៥ ភាគរយ |
| – ថៃ ប្រហែល | : | ០,១ ភាគរយ |
| – ចាម ប្រហែល | : | ០,១ ភាគរយ |

ប្រជារាស្ត្រ ៩៥ ភាគរយប្រកបរបរកសិកម្ម ។

# Srok Mongkol Borei (Khet Banteay Meanchey)



## ៣–លក្ខខណ្ឌសេដ្ឋកិច្ច–កសិកម្ម

### ៣.១–ផ្នែកដាំដុះ

ទោះបីប្រជារាស្ត្របានខិតខំបង្កបង្កើនផលយ៉ាងណាក៏ដោយ ក៏ប្រជារាស្ត្រពុំបានទទួលផលឆ្លើយតបតាមការខិតខំនេះឡើយ ។ ព្រោះឆ្នាំកន្លងមកនេះ ប្រជារាស្ត្រយើងទូទាំងខេត្ត ដោយឡែកស្រុកមង្គលបូរី បានជួបប្រទះគ្រោះធម្មជាតិដោយទឹកជំនន់ និងគ្រោះរាំងស្ងួតបណ្តាលអោយដំណាំស្រូវរលួយ និងស្កកស្វិត អស់ ១៣.២៥០ ហិកតា ។

#### ៣.១.១–ដំណាំស្រូវ

ជាទូទៅប្រជាជនមានទំលាប់ដាំស្រូវក្នុងស្រុកដែលមានពូជស្រូវស្រាល–ស្រូវកណ្តាល និងស្រូវធ្ងន់ ។

**ពូជស្រូវដែលកសិករនិយមចូលចិត្ត**

| ល.រ | ពូជស្រូវស្រាល | ពូជស្រូវកណ្តាល | ពូជស្រូវធ្ងន់ |
|---|---|---|---|
| ១ | សុមាលី | រលកថ្ងិត | **B9** |
| ២ | លំអងខ្សាច់ | ផ្កាខ្ញី | នាងខុន |
| ៣ | មាសអង្ករ | ឈុតតាណា | **C8** |
| ៤ | | | នាងមេញ |
| ៥ | | | នាងជិម |

ប្រជាជននិយមចូលចិត្តដាំស្រូវក្នុងស្រុក ពីព្រោះស្រូវក្នុងស្រុកមានការលូតលាស់ស្របទៅតាមលក្ខណៈតំបន់ ទោះបីមានការខ្វះខាតជី ថ្នាំសំលាប់សត្វល្អិតខ្វះក៏ដោយ ក៏អាចផ្តល់ទិន្នផលបានសមស្របតាមគុណភាពរបស់ដីនោះដែរ ។

ទន្ទឹមនឹងនេះដែរ គុណភាពរបស់អង្កររត្រូវបានប្រជាជនទូទាំងប្រទេសវាយតំលៃថាមានគុណភាពខ្ពស់ មានឱជារសឆ្ងាញ់ និងមានតំលៃខ្ពស់ ។

ការដាំដុះស្រូវមានលក្ខណៈយថាផលរណបទៅនឹងទឹកភ្លៀង ។ បណ្តាប្រភេទសត្វចង្រៃដែលបានបំផ្លាញស្រូវកសិករ ភាគច្រើនជាពពួកកណ្តុប , មមង់ , រដូវហ្វូង ។ល។

ប្រភេទជម្ងឺដែលធ្លាប់ជួបប្រទះ គឺ ជម្ងឺពីរីគុយឡារ៉្យូស (**Pyriculariose , Riceblast** ) និងសែរកូស្ប៉ូរ៉្យូស ( Cercosporiose ) ។

### ៣.១.២–ដំណាំឆ្លងកាត់

–ដំណាំរួមផ្សំ សរុប ១៤១ ហិកតា ក្នុងនោះ

- ពោត ១៣២ ហិកតា
- ដំឡូងមី ៤ ហិកតា
- ដំឡូងល្វា ៥ ហិកតា

–ដំណាំបន្លែ សរុប ៨១ ហិកតា ក្នុងនោះ

- សណ្តែកបាយ ១៧ ហិកតា
- សណ្តែកផ្សេងៗ ១០ ហិកតា
- បន្លែគ្រប់មុខ ៥៤ ហិកតា

### ៣.១.៣– ដំណាំឧស្សាហកម្ម សរុប ១៣០ ហិកតា ក្នុងនោះ

- ក្រចៅ ១០២ ហិកតា
- អំពៅ ២០ ហិកតា
- សណ្តែកដី ២ ហិកតា
- ល្ង ៦ ហិកតា

### ៣.១.៤–ការចិញ្ចឹមសត្វ

ការចិញ្ចឹមសត្វរបស់ប្រជាកសិករ នៅពុំទាន់មានលក្ខណៈបច្ចេកទេសជឿនលឿន ឬលក្ខណៈឧស្សាហកម្មនៅឡើយ គឺចិញ្ចឹមជាលក្ខណៈគ្រួសារ និងតាមទំលាប់តៗគ្នាពីបុរមបូរាណមកតែប៉ុណ្ណោះ។

ស្ថានភាពនេះ បណ្តាលអោយការចិញ្ចឹមសត្វនៅមានកំរិត និងមានជម្ងឺឆ្លងរីកដុះដាលក្នុងហ្វូងសត្វ ដែលនាំអោយខូចខាត និងបាត់បង់ផលប្រយោជន៍របស់គេ ។

យើងពិនិត្យឃើញថា នៅរដូវប្រាំង និងដើមរដូវភ្លៀងធ្លាក់ដំបូង ជម្ងឺឆ្លងសត្វរមែងលេចកើតលើហ្វូងសត្វពាហនៈ សត្វស្លាប់ដែលបណ្តាលអោយអន្តរាយ និងខូចខាតសត្វអស់មួយចំនួនធំ និងមានការថយចុះនូវការផលិតកូន ការថយចុះកំលាំងពលកម្ម ។

<u>ជម្ងឺទាំងឡាយដែលលេចកើតនៅក្នុងហ្វូងសត្វរួមមាន</u> :

ក–<u>ចំពោះគោ–ក្របី</u>

+ ជម្ងឺ អុតក្តាម
+ ជម្ងឺ សារទឹក
+ ជម្ងឺ បូសខ្យល់

ខ–ចំពោះជ្រូក

–ជម្ងឺ ប៉េស្ត

–ជម្ងឺ សារទឹក

–ជម្ងឺ កញ្ជ្រិល

–ជម្ងឺ គ្រុនសន្ធំជ្រូក

គ–ចំពោះមាន់ – ទា

– ជម្ងឺ ញ៉ូវកាស

– ជម្ងឺ អុតក្តាម

– ជម្ងឺ សារទឹក

ជម្ងឺមួយទៀតដែលបង្កលើសត្វគ្រប់ប្រភេទ គឺជម្ងឺបង្កឡើងដោយពពួកប៉ារ៉ាស៊ីត ។

កត្តាសំខាន់បណ្តាលមកពីគ្មានថ្នាំចាក់ការពារជម្ងឺអោយបានគ្រប់គ្រាន់ នឹងខ្វះថ្នាំសំរាប់ព្យាបាល និងថ្នាំសំរាប់បញ្ចុះព្រូនគ្រប់ប្រភេទ ។ ទន្ទឹមនឹងនេះ ប្រជាជនមួយចំនួនក៏នៅពុំទាន់មានជំនឿជឿជាក់លើការចាក់ថ្នាំការពារ ក៏ដូចជាព្យាបាលដែរ ។ ដូច្នេះកម្មវិធីគំរោងអភិវឌ្ឍន៍កែទំរង់ការងារបសុព្យាបាល «ការការពារសុខភាពសត្វ» គឺជាចំណុចគន្លឹះសំរាប់រាងស្កាត់ជម្ងឺដង្កាត់នានា និងជាទូទៅឈានទៅលប់បំបាត់នូវប្រភេទជម្ងឺឆ្លងទាំងឡាយដែលធ្លាប់កើត ព្រមទាំងឈានទៅអភិឌ្ឍន៍ការចិញ្ចឹមសត្វតាមលក្ខណៈបច្ចេកទេស ។

**៣.១.៥–ការងារដំណាំផល**

រដូវនេសាទឆ្នាំនេះ យើងពិនិត្យឃើញម្ចាស់ឡូត៍នេសាទទាំង ៣ មានការជួបការលំបាកក្នុងការប្រមូលផលនេសាទ ដោយខ្មែរក្រហមបានធ្វើការអុកឡុក និងជំរិតយកប្រាក់ និងត្រីពីម្ចាស់ឡូត៍នេសាទយ៉ាងច្រើនទៀតផង ធ្វើអោយការប្រមូលផលត្រីមានចំនួនទាបជាងឆ្នាំមុនៗ ។

–ប្រភេទត្រីស្រស់ សរុប ៥២.៧០០ គ.ក្រ ក្នុងនោះត្រីលេខ ១ ១៣.៧០០គ.ក្រ ត្រីលេខ ២ ៧៧.២០០ គ.ក្រ ត្រីលេខ ៣ ១៩.៨០០ គ.ក្រ ។

–ប្រភេទត្រីច្នៃសរុប ១១.៦០០ គ.ក្រ ក្នុងនោះប្រហុក ៧.៥០០ គ.ក្រ ត្រីឆ្អើរ ២.១០០ គ.ក្រ ត្រីងៀត ២.០០០ គ.ក្រ ។

**៣.១.៦–ការងាររុក្ខកម្ម**

បានចុះត្រួតពិនិត្យរុក្ខផលក្នុងស្រុកខាងក្រោម :

| | |
|---|---|
| – ស្ថិតិឈើអារ សរុប | ៤២០ $ម^៣$ |
| – ស្ថិតិឈើមូល | ២០.២២៤ $ម^៣$ |
| – បង្គោលក្រាក់ | ៣៣០ ដើម |
| – ធ្យូង | ១០.១០០ គ.ក្រ |

# ជំពូក ៥

## ៥—សិក្សាពីសកម្មភាពការងារដែលតំបន់បានអនុវត្តកន្លងមក

### ៥.១—ការងារចាប់ផ្តើម

តំបន់អភិវឌ្ឍន៍កសិកម្មក្នុងខេត្តបន្ទាយមានជ័យ ស្រុកមង្គលបូរី បានចាប់ដំណើរការពិភាក្សាសំរេចអោយបង្កើតឡើងនៅថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩៤ ក្រោមកិច្ចសហប្រតិបត្តិការរវាងមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត រដ្ឋអំណាចមូលដ្ឋាន និងអង្គការ **CARERE** ។

### ៥.២—គោលបំណងនៃការធ្វើអភិវឌ្ឍន៍

តំបន់អភិវឌ្ឍន៍កសិកម្មស្រុកមង្គលបូរីបង្កើតឡើងក្នុងគោលបំណង «ធ្វើអោយរីកចំរើននូវផលិតកម្មកសិកម្ម ព្រមទាំងប្រាក់ចំណូលប្រចាំគ្រួសារ ដោយចង្អុលបង្ហាញនូវកត្តាទាំងឡាយ ដែលជាកត្តាកំណត់សំខាន់ជាងគេត្រូវលើកកំពស់ការជីវភាពរស់នៅខាងផ្នែកសេដ្ឋកិច្ច និងសង្គម ។

ទន្ទឹមនឹងនេះដែរជួយអោយប្រជាជនដោះស្រាយនូវបញ្ហាដោយខ្លួនឯង ។

បញ្ហាកត្តាសំខាន់ៗដែលជាអាទិភាពចំបងចំពោះមុខរបស់ប្រជាជនកសិករ គឺ :

- ភាពខ្វះខាតទឹកប្រើប្រាស់ក្នុងគ្រួសារ និងផ្ទៃដីបង្កបង្កើនផលស្រូវ
- ភាពខ្វះខាតនូវការយល់ដឹងអំពីបច្ចេកទេសកសិកម្ម
- ភាពខ្វះខាតនូវពូជសត្វ និងកំលាំងអូសទាញ
- ភាពខ្វះខាតនូវសំភារៈកសិកម្ម
- ភាពខ្វះខាតនូវអុសដុត
- គ្មានមុខរបរបន្ថែមក្រៅពីផលិតផលកសិកម្ម ដើម្បីបង្កើនប្រាក់

កត្តាសំខាន់មួយទៀតដែលរាប់បញ្ចូលក្នុងកត្តាខាងលើនេះដែរ គឺបញ្ហាចំនួនស្ត្រីមេម៉ាយខ្វះខាតនូវកំលាំងពលកម្ម និងជនពិការបាត់បង់លទ្ធភាពពលកម្មដោយសារសង្គ្រាម ។

### ៥.៣—របៀបធ្វើការអភិវឌ្ឍន៍

ដើម្បីងាយស្រួលដល់ការទទួលខុសត្រូវបានគ្រប់ផ្នែកនៅក្នុងវិស័យកសិកម្ម និងពាំនាំនូវបច្ចេកទេសដល់ប្រជាកសិករ រួមជាមួយអង្គការ **CARERE** បានពិនិត្យសំរេចរៀបចំឡើងនូវក្រុមមួយដែលមានឈ្មោះថា «ក្រុមអភិវឌ្ឍន៍» ។

#### ៥.៣.១—គណៈកម្មការអភិវឌ្ឍន៍ ( V.D.C)

គណៈកម្មការអភិវឌ្ឍន៍ភូមិ គឺជាសមាសភាព ស្ថាប័នក្រៅរដ្ឋាភិបាលមួយតំណាងអោយប្រជាជនក្នុងភូមិនិមួយៗ សំរាប់ដឹកនាំគ្រប់គ្រងការអនុវត្តអភិវឌ្ឍន៍នានាក្នុងក្របខ័ណ្ឌភូមិរបស់ខ្លួន ។

គណៈកម្មការនេះកើតឡើងតាមការផ្តួចផ្តើមគំនិតរួមគ្នា រវាងមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត និង តំណាងផ្នែកសហគមន៍របស់អង្គការ **UNDP / CARERE** ឬ **NGO'S** ផ្សេងៗ ហើយត្រូវបាន

ចាត់តាំងឡើងតាមលក្ខការណ៍ប្រជាធិបតេយ្យ អាស្រ័យដោយប្រជាជនធ្វើការជ្រើយរើសតាមរយៈ ការបោះឆ្នោតមានសមាជិកពី ៥ ទៅ ៩ រូប តាមទំហំការងារជាក់ស្តែងនៃភូមិតូច ឬ ធំ និងត្រូវបានទទួលស្គាល់ជាផ្លូវការក្នុងអាណត្តិសកម្មភាពរបស់ខ្លួន ពីអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ។

ក–គោលបំណងនៃការបង្កើតគណៈកម្មការអភិវឌ្ឍន៍ភូមិ :

ការបង្កើតគណៈកម្មការអភិវឌ្ឍន៍ភូមិ ដែលសំរេចបានជារូបរាងកន្ទងមក សំដៅបំរើអោយគោលបំណងសំខាន់ៗ ដូចតទៅ ÷

–បង្កអោយមានការចូលរួមចំណែកកាន់តែប្រសិទ្ធភាពក្នុងកម្មវិធីអភិវឌ្ឍន៍ ដោយការប្រើប្រាស់ ប្រភពទុននៃធនធានមនុស្សតាមភូមិនិមួយៗ ។

–សំរួលដល់ការអនុវត្តកម្មវិធីនានា តាមរយៈការបង្កើតឡើងក្រុមការងារទាំងឡាយអោយទទួលរ៉ាប់រងភារកិច្ចទាំងនេះនៅក្នុងមូលដ្ឋានរបស់ខ្លួន ។

–រួមចំណែកធ្វើអោយមានការរីកចំរើនក្នុងជីវភាពរស់នៅ និងលើកកំពស់សេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ។

–ធ្វើអោយប្រជាពលរដ្ឋស្គាល់ពីតំលៃរបស់ខ្លួន មានជំនឿលើខ្លួនឯង និងចេះដោះស្រាយគឺផ្តល់គំនិត ដើម្បីដោះស្រាយបញ្ហាលំបាកទាំងឡាយចោទឡើងចំពោះមូលដ្ឋាន និងសហគមន៍របស់ខ្លួន។

–បង្កើន និងពង្រឹងសាមគ្គីភាពប្រជាជនក្នុងសហគមន៍ បង្កអោយមានភាពចេះជួយឈឺឆ្អាលគ្នា និងជ្រោមជ្រែងនូវសេចក្តីសំរេចចិត្តរបស់គេ ដើម្បីផលប្រយោជន៍គ្រួសារ និងសហគមន៍របស់គេ ។

–តំណាងអោយប្រជាជពលរដ្ឋក្នុងការគាំទ្រ ដោះស្រាយនូវអ្វីដែលជាសេចក្តីត្រូវការប៉ងប្រាថ្នាចង់បានរបស់គេដោយពិតប្រាកដ ។

–បង្កើនសុក្រិតភាពអំពីការផ្តល់ទិន្នន័យ និងការកសាងគំរោងផែនការសំរាប់កម្មវិធីមួយៗ ក្នុងមូលដ្ឋាននិមួយៗ ។

ខ–អំពីរចនាសម្ព័ន្ធ និងរូបភាពចាត់ចែងគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ :

គណៈកម្មការអភិវឌ្ឍន៍ភូមិ ជាខ្សែរយៈបណ្តោយនៃគណៈកម្មការអភិវឌ្ឍន៍ ខេត្ត ក្រុង ស្រុក និងឃុំ ។ គណៈកម្មការនេះមិនមែនជាអង្គការចាត់តាំងរដ្ឋបាលរបស់រដ្ឋាភិបាលទេ តែចាំបាច់ត្រូវទទួលស្គាល់ និងទ្រង់សកម្មភាពការងាររបស់ខ្លួនពីអាជ្ញាធររបស់រាជរដ្ឋាភិបាល ។

គណៈកម្មការអភិវឌ្ឍន៍ភូមិ ត្រូវបានចាត់តាំងឡើងតាមរយៈការបោះឆ្នោតដោយផ្ទាល់ពីប្រជាជនក្នុងភូមិរបស់ខ្លួន ។ សមាសភាពគណៈកម្មការត្រូវបានជ្រើសរើសពីក្នុងចំណោមប្រជាជនដែលសកម្មភាពការងារមានសមត្ថភាព និងមានកំរិតជីវភាពធូរធារបង្គួរ ២០ ភាគរយ កំរិតមធ្យម ៦០ ភាគរយ និង កំរិតជីវភាពទាប ២០ ភាគរយ ។ សមាភាពចាំបាច់ត្រូវមានតំណាងនារីភេទចូលរួម ប្រមាណពី ៣០ ទៅ ៥៩ ភាគរយ និងមានចំនួនរួមពី ៥ ទៅ ៩ រូប អាស្រ័យតាមបរិមាណគ្រួសារតិច ឬ ច្រើននៃភូមិនិមួយៗ ។ បន្ទាប់ពីបានទទួលការបោះឆ្នោតគាំទ្រពីប្រជាជនរួចហើយ សមាជិកគណៈកម្មការអភិវឌ្ឍន៍

ភូមិនិមួយៗ ធ្វើការបោះឆ្នោតមួយលើកទៀត ដើម្បីជ្រើសតាំងប្រធាន អនុប្រធានគណៈកម្មការ និង បេឡាធិការ ។ ដើម្បី សំរួលតាមភាពជាក់ស្តែងអំពីសមត្ថភាពធ្វើការងាររបស់គណៈកម្មការកន្លងមកនេះ នៅភូមិមួយចំនួន ការរៀប ចំជ្រើសរើសប្រធាន អនុប្រធាន លេខាធិការ និង បេឡាធិការ អាចសំរបសំរួលតាមការឯកភាពគ្នាក្នុងគណៈ កម្មការដែលបានតែងតាំងតាមលំដាប់សំលេងឆ្នោតពីខ្ពស់ មកទាបបន្ទាប់និងពិនិត្យទៅលើក៏រិតសមត្ថភាព និង ការសំរេចចិត្តរបស់បុគ្គលជាសមាជិកផងដែរ ។

## គ-រចនាសម្ព័ន្ធចាត់តាំងគណៈកម្មការអភិវឌ្ឍន៍



ឃ–អំពីតួនាទីគណៈកម្មការអភិវឌ្ឍន៍

–ជាតំណាងអោយប្រជាជនក្នុងភូមិរបស់ខ្លួន ក្នុងការបង្ហាញលើកឡើងនូវគំរោងផែនការ បំណងប្រាថ្នា និងសំណូមពរនានាដែលផុសចេញពីសេចក្តីត្រូវការពិតប្រាកដ របស់ប្រជាជនក្នុងសហគមន៍ខ្លួនផ្តល់ជូនអង្គការក្រៅរដ្ឋាភិបាលនានាទាំងជាតិនិងអន្តរជាតិ ព្រមទាំងបណ្តាស្ថាប័នពាក់ព័ន្ធក្នុងកម្មវិធីអភិវឌ្ឍន៍។

–សិក្សាស្រាវជ្រាវស្វែងយល់អោយបានគ្រប់ជ្រុងជ្រោយអំពីសភាពការណ៍រួមក្នុងមូលដ្ឋានខ្លួនកត់សំគាល់ និងកំណត់បញ្ហាអោយបានត្រឹមត្រូវសមស្របតាមសេចក្តីត្រូវការរបស់ប្រជាជនក្នុងភូមិរបស់ខ្លួន។

–ពិភាក្សាគ្នាល្អិតល្អន់ ដើម្បីកំណត់បានត្រឹមត្រូវនូវការចាត់លំដាប់បញ្ហាដែលចាំបាច់សំរាប់អនុវត្ត ឬលើកសំណូមពរឡើងថ្នាក់លើ «លើកគំរោងផែនការស្នើឡើងថ្នាក់លើ» ។

–រួមចំណែកក្នុងការដោះស្រាយបញ្ហា តាមរយៈការស្រាវជ្រាវស្វែងរកវិធានការជាគន្លឹះនានាសំរាប់ដឹកនាំការអនុវត្តរបស់សហគមន៍ រួមមានការចូលរួមជាកំលាំងពលកម្ម ឬ ការចូលរួមជាទុនខ្លះ ឬផ្តល់ជាគំនិតជូនថ្នាក់លើ ដើម្បីបានជាមូលដ្ឋានទុនសំរាប់ដំណោះស្រាយបញ្ហាបានឆាប់រហ័ស ។

–ជួយពង្រឹងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីអភិវឌ្ឍន៍នានា តាមរយៈការតែងតាំង–បុគ្គលទទួលខុសត្រូវ ឬ រៀបចំក្រុមការងារដើម្បីដឹកនាំគ្រប់គ្រង និងចាត់តាំងសកម្មភាពអនុវត្ត ។

–តាមដានត្រួតពិនិត្យ ជំរុញសកម្មភាពអនុវត្តកម្មវិធីនានា និងរាំងខ្ទប់បានទាន់ពេលវេលានូវបាតុភាពអសកម្មផ្សេងៗ ដែលជះឥទ្ធិពលមិនល្អ ឬ បង្កភាពមិនរីកចំរើនចំពោះកម្មវិធីកំពុងអនុវត្ត ។

–ធ្វើជាស្ពានចំលងនូវបទពិសោធន៍ល្អៗ បច្ចេកវិទ្យាទំនើប ជឿនលឿនពីមជ្ឈដ្ឋានខាងក្រៅមកច្នៃប្រឌិត បង្កបានជាសកម្មភាពជាក់ស្តែងបំរើអោយកម្មវិធីអភិវឌ្ឍន៍របស់សហគមន៍ខ្លួន ។

–ផ្សព្វផ្សាយពីលទ្ធផលរីកចំរើនបទពិសោធន៍ជឿនលឿន ក្នុងសកម្មភាពរបស់ខ្លួនដល់បណ្តាភូមិជិតខាង ដើម្បីញ៉ាំងសកម្មភាពអភិវឌ្ឍន៍អោយមានភាពផុលផុសបន្តគ្នាទៅគ្រប់ទីកន្លែងសំដៅបំរើអោយភាពរីកចំរើនឡើងនៃជីវភាព និងសេចក្តីថ្លៃថ្នូររបស់សង្គមមនុស្សនៅក្នុងភូមិ ឃុំ ស្រុក ខេត្តរបស់ខ្លួន ។

–រួមចំណែកជួយអប់រំប្រជាជនអោយយល់ច្បាស់ពីអ្វីដែលជាប្រយោជន៍ចំពោះមុខ និងយូរអង្វែង អ្វីដែលជាប្រយោជន៍ផ្ទាល់ខ្លួន និងប្រយោជន៍សាធារណៈ អ្វីដែលជាកាតព្វកិច្ចរបស់គេទាំងឡាយត្រូវអនុវត្តសំរាប់បច្ចុប្បន្ន និងទៅអនាគត ដើម្បីលើកកំពស់មនសិការស្នេហាជាតិរបស់គេទាំងឡាយនោះអោយកាន់តែមានភាពមោះមុតចូលរួមយ៉ាងខ្លាំងក្លាក្នុងភារកិច្ចការពារ និងកសាងមាតុភូមិជាទីស្រឡាញ់របស់ខ្លួន ។

ង–អំពីភារកិច្ច

គណៈកម្មការអភិវឌ្ឍន៍ភូមិមានភារកិច្ចជាក់ស្តែងដូចតទៅ

**១–ភ្ជាប់ជាប់សភាពការណ៍គ្រប់វិស័យនៅក្នុងមូលដ្ឋានខ្លួន**

ក–ត្រូវធ្វើការសិក្សាស្រាវជ្រាវ ដើម្បីស្វែងយល់ និងក្តាប់បានច្បាស់លាស់អំពី :

– ស្ថិតិសមាសភាពប្រពៃណី វប្បធម៌ ទំនៀមទំលាប់របស់ប្រជាជន ។

–ស្ថានភាពវិស័យសេដ្ឋកិច្ច សង្គមកិច្ច ដែលជាវិស័យពាក់ព័ន្ធដោយផ្ទាល់ដល់ជីវភាពរស់នៅរបស់ប្រជាជន ។

ខ–ពិភាក្សា សន្និដ្ឋាន វាយតំលៃអោយបានសមស្របបំផុតនូវចំណុចខ្លាំង ចំណុចខ្សោយនានារបស់មូលដ្ឋានខ្លួន ដើម្បីវិភាគបានប្រាកដប្រជា ស៊ីជំរៅនូវមូលហេតុនៃបញ្ហាទាំងឡាយ ដូចជា :

–អំពីប្រភពធនធាន តើមូលដ្ឋានយើងមានអ្វីខ្លះ ហើយដែលលលបង្កបានជាលក្ខណៈអំណោយផលល្អ សំរាប់លើកកំពស់ជីវភាពរស់នៅរបស់ប្រជាជន ? អ្វីដែលយើងនៅខ្វះខាត ? អ្វីដែលមានហើយ តែនៅមិនទាន់មានការរីកចំរើន ត្រូវកែលំអបន្ថែម ?

–អំពីសេចក្តីត្រូវការ : តើមានបញ្ហាណាខ្លះដែលប្រជាជនចង់បាន ? សំណូមពរទាំងនេះសមស្របឬទេ ? បញ្ហាចាំបាច់ដែលយើងត្រូវចាប់អារម្មណ៍មានអ្វីខ្លះ ? ត្រូវដោះស្រាយតាមវិធីណា ? ដោយមធ្យោបាយអ្វី ?

–អំពីលទ្ធភាពសំរេចគោលបំណងនេះ តើប្រភពធនធានមនុស្ស និងមធ្យោបាយ សំភារៈដែលមានក្នុងមូលដ្ឋានយើងអាចដោះស្រាយបញ្ហានេះបានឬទេ ? បើបានក្នុងកំរិតណា ? បញ្ហាអ្វីខ្លះដែលត្រូវពឹងពាក់អន្តរាគមន៍ពីខាងក្រៅ ? បើពឹងពាក់ តើយើងត្រូវទាក់ទងអង្គភាពណា អង្គការណា ដើម្បីជួយយើង ។

បំពេញបានល្អនូវការងារនេះ អាចនឹងពង្រីកបាននូវការបង្កលក្ខណៈងាយស្រួលក្នុងកិច្ចទំនាក់ទំនងរបស់ភូមិជាមួយនិងភ្នាក់ងារស្ថាប័ននានារបស់រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ ។

**៥.៤–ការសហការពីប្រជាជន**

ការចូលរួមពីសំណាក់ប្រជាជន គឺជាគន្លឹះយុទ្ធសាស្ត្រលើកឡើងនូវដំណោះស្រាយដ៏ស្មុគស្មាញទាំងឡាយ និងជួយជំរុញអោយការអភិវឌ្ឍន៍បានទទួលនូវជោគជ័យ ។

គ្រប់ការកសាងកម្មវិធី ដើម្បីធ្វើការអភិវឌ្ឍន៍នៅក្នុងតំបន់ត្រូវតែមានការចូលរួមពីប្រជាជនដោយមានការស្ទាបស្ទង់ និងផ្លាស់ប្តូរយោបល់គ្នា ចំណុចសំខាន់គឺត្រូវបានស្វែងរកឃើញថា «តើគាត់មានបំណងចង់ចូលរួមជាមួយយើងឬក៏ទេ ? តើគាត់យល់អំពីគោលបំណងរបស់យើងឬទេ ?

**៥.៥–ការសហការពីរដ្ឋអំណាចមូលដ្ឋាន** ( ភូមិ–ឃុំ–ស្រុក និង ខេត្ត )

ជាការពិតណាស់ ដើម្បីសំរេចការងារអភិវឌ្ឍន៍បានក្រុមអភិវឌ្ឍន៍មិនអាចកាត់ផ្តាច់បានពីការរួមសហការរដ្ឋអំណាចមូលដ្ឋានបានឡើយ ។ ការចូលរួមពីសំណាក់រដ្ឋអំណាចជាកត្តាមួយចាំបាច់ដើម្បីឈានទៅរកភាពងាយស្រួលនៃ ដំណោះស្រាយ ។

៥.៥.១ ការដាំដុះនៅស្ថានីយ៍ចំការឈើហូបផ្លែនៅស្រុកមង្គលបូរី

| ឈ្មោះដំណាំ | ចំនួនដើមដែលដាំ | សេចក្តីផ្សេងៗ |
|---|---|---|
| ១–<u>ដំណាំហូបផ្លែ</u> | | |
| –ស្វាយអ៊ុករ៉ងថង | ៤៩ ដើម | |
| –ស្វាយខៀវស្មើយ | ១៩ ដើម | |
| –ស្វាយណាំដកម៉ៃ | ៣០ ដើម | |
| –ស្វាយលាងសែន | ១៩ ដើម | |
| –ក្រូចចិន | ៧ ដើម | |
| –ក្រូចថ្លុង | ៧ ដើម | |
| –ល្មុត | ១២ ដើម | |
| –ឡាំងសាត | ៦ ដើម | |

| ឈ្មោះដំណាំ | ផ្ទៃដី (ហិកតា) | សេចក្តីផ្សេងៗ |
|---|---|---|
| ១–<u>ដំណាំរួមផ្សំ</u> | | |
| –ពោត | ១៣២ | |
| –ដំឡូងមី | ៤ | |
| –ដំឡូងជ្វា | ៥ | |
| ២–<u>ដំណាំបន្លែ</u> | | |
| –សណ្តែកបាយ | ១៧ | |
| –សណ្តែកផ្សេងៗ | ១០ | |
| –បន្លែគ្រប់មុខ | ៥៤ | |
| ៣–<u>ដំណាំឧស្សាហកម្ម</u> | | |
| –ក្រចៅ | ១០២ | |
| –អំពៅ | ២០ | |
| –សណ្តែកដី | ២ | |
| –ល្ង | ៦ | |

៥.៥.២ –**ការងារធារាសាស្ត្រ**

| ល.រ | តំបន់ | សកម្មភាពការងារ | សេចក្តីផ្សេងៗ |
|---|---|---|---|
| ១ | ឃុំចំនោម | ជួសជុលទំនប់ | ចំនោមលិចប្រវែង ១៥ម អនុវត្តបាន៥ម ស្មើនឹង ២៣ម៣ |
| ២ | ឃុំឫស្សីក្រោក | ស្តារប្រឡាយ | គោកជ្រឹងប្រវែង ១.០០ម អនុវត្ត ១.០០០ម ស្មើនឹង ១.២០០ម៣ |
| ៣ | ឃុំបន្ទាយនាង | ស្តារប្រឡាយ | ១.៥០០ម ទៅប្របែកប្រវែង ១.៥០០ម អនុវត្ត ៩១០ម ស្មើនឹង ២.៧៣០ម៣ |
| ៤ | ឃុំអូរប្រាសាទ | ស្តារប្រឡាយ | រ៉ាចំការចេក ប្រវែង ១.០០០ម អនុវត្តបាន ១.០០០ម ស្មើនឹង ២.១០០ម៣ |
| ៥ | ឃុំភ្នំតូច | ជួសជុលទំនប់ | អូរប្រគៀបប្រវែង ១.០០០ម អនុវត្ត ៣០ម ស្មើសឹង ១៥០ |
| ៦ | ឃុំគោកបល្ល័ង្គ | ជួសជុលទំនប់ | រ៉ាថ្មី ប្រវែង ១.០០០ម អនុវត្ត ១០០ម ស្មើនឹង ៧៥០ម៣ |
| ៧ | ឃុំស្រះរាំង | ជួសជុលទំនប់ក្រូច | ប្រវែង ១០០ម ស្មើនឹង ៤៧៥ |
| ៨ | ឃុំគយម៉ែង | ជួសជុលទំនប់ | ចុងគោកប្រវែង ២០០ម អនុវត្ត ២០០ម ស្មើនឹង ១.៣០០ម៣ |
| ៩ | ឃុំរហាត់ទឹក | ស្តារប្រឡាយ | អូរដង្កោប្រវែង ១.៥០០ម អនុវត្តបាន ៧៥០ម ស្មើនឹង ១.៨០០ម៣ |
| ១០ | ឃុំឫស្សីក្រោក | ធ្វើសំណង់អំពីបេតុង | ១កន្លែងប្រវែង ៤ម នៅប្រឡាយអន្លង់រាំង |

## ៥.៦–កម្មវិធីផលិតពូជស្រូវ ឬ ពង្រីកស្រូវពូជ Rice seed production

### ១–ទំនាក់ទំនងជាមួយរដ្ឋអំណាចស្រុក ឃុំ ភូមិ ជាពិសេសគណៈកម្មការអភិវឌ្ឍន៍ភូមិ ដើម្បី :

–ទទួលស្គាល់ខ្លឹមសារកម្មវិធីត្រូវពង្រីកស្រូវពូជ

–យកពត៌មានអំពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ចនៅមូលដ្ឋាន និងជ្រើសរើសចំណុចសំរាប់កម្មវិធីពង្រីកស្រូវពូជ

–ឯកភាពគ្នាលើផែនការអភិវឌ្ឍន៍ពង្រីកពូជស្រូវ

–យកពត៌មានអំពីការងារឥណទានរបស់អង្គការដទៃទៀត

### ២–គោលបំណង

- ជួយពង្រីកស្រូវពូជអោយមានគុណភាពល្អ ដើម្បីជួយជីវភាពដល់កសិករក្រីក្រ
- បង្កើនចំណូលដល់កសិករក្នុងការធ្វើអាជីវកម្មកសិកម្ម
- បំពាក់បំប៉នបច្ចេកទេសកសិកម្មដល់កសិករ
- ផ្តល់ដើមទុនអោយកសិករអោយមានលទ្ធភាព និងអនុវត្តនូវបច្ចេកទេសថ្មី
- បង្កើតក្រុមឥណទានដែលមានសមាជិក ២៥ នាក់
- ផ្តល់ទុនដល់ទៅ ១០៤ $ ចំពោះអ្នកចូលរួមម្នាក់
- យកការប្រាក់ ២ ភាគរយ រៀងរាល់ខែ យកការប្រាក់ ១ ភាគរយប្រចាំខែ និង ១ភាគរយទៀត សំរាប់សងដើមទាំងអស់នៅពេលប្រមូលផល ។

### ៣–តំបន់ចំណុច

តំបន់អភិវឌ្ឍន៍ទីមួយ មានស្រុកមង្គលបូរី និងស្រុកសេរីសោភ័ណ

តំបន់ទីមួយ : (២៥០ គ្រួសារ និង ២០ ហិកតា )

| លេខរៀង | ស្រុក | ឃុំ | ភូមិ |
|---|---|---|---|
| ១ | មង្គលបូរី | ឫស្សីក្រោក | ចំការត្រដោក |
| ២ | មង្គលបូរី | ឫស្សីក្រោក | ជំទាវ |
| ៣ | មង្គលបូរី | បត់ត្រង់ | បត់ត្រង់ |
| ៤ | មង្គលបូរី | បត់ត្រង់ | បត់ត្រង់កើត |
| ៥ | មង្គលបូរី | អូរប្រាសាទ | គោកឆ្នងកណ្តាល |
| ៦ | មង្គលបូរី | អូរប្រាសាទ | គោកឆ្នងកើត |
| ៧ | មង្គលបូរី | បន្ទាយនាង | ត្របែក |
| ៨ | មង្គលបូរី | បន្ទាយនាង | ភ្នំ |

ក–ការជ្រើសរើសភូមិ

- ប្រភពទឹកអាចធានាបាន
- ដីស្រែនោះមានជីជាតិល្អ អាចនាំទឹកបញ្ចូលស្រែនៅពេលគ្មានភ្លៀង ឬរាំងស្ងួត
- ក្នុងការធ្វើដំណើរចេញចូលងាយស្រួល ហើយមានសន្តិសុខល្អ ។

ខ–ការជ្រើសរើសកសិករចូលរួម

កសិករ ២៥ នាក់ នឹងជ្រើសរើសពីភូមិនិមួយៗ ។

ការជ្រើសរើស នឹងយោងទៅតាមលក្ខណស្រម្បត្តិ ដូចខាងក្រោមនេះ ÷

–កសិករសកម្ម ហើយមានផ្ទៃស្រែ ១ ហិកតា

–ស្ម័គ្រចិត្តប្រើប្រាស់ ឬ ធ្វើអោយមានប្រយោជន៍ទៅតាមគ្រោងការណ៍ឥណទាន

–ស្ម័គ្រចិត្តចូលរួមចំណែក ជាក្រុមឥណទាន ហើយអាចចូលរួមសិក្សាបច្ចេកទេសកសិកម្ម រាល់ពេលណាមានសំណូមពរ :

–ស្មគ្រចិត្តសងប្រាក់ដើម (ទុន) រួមជាមួយការប្រាក់

–ស្ម័គ្រចិត្តធ្វើជាអ្នកធានាទៅវិញទៅមក (ក្នុងក្រុម) ប្រសិនបេកមានអ្នកពុំសង

–ស្ម័គ្រចិត្តធ្វើអោយមានសារៈប្រយោជន៍តាមគោលការណ៍កសិកម្ម

–ស្ម័គ្រចិត្តសិក្សារៀនសូត្រ និងអនុវត្តបច្ចេកទេសកសិកម្មថ្មី ដើម្បីពង្រីកស្រូវពូជគុណភាពល្អ

គ–រៀបចំក្រុម

(មុនដំបូង) : សមាជិកត្រូវយល់អំពីការងារសំខាន់ៗរបស់ឥណទានក្នុងគំរោងពង្រីកស្រូវពូជ យល់ដឹងអំពីគោលបំណងនៃឥណទានដែលផ្តល់ ។

(បន្ទាប់មក) រៀបចំក្រុមដោយខ្លួនឯង ដែលមានសមាជិក ៨–៩ នាក់ សមាជិកជ្រើសរើសប្រធានក្រុមរបស់ខ្លួន ដោយធ្វើការបោះឆ្នោតក្នុងក្រុម ។

ឃ–តួនាទីរបស់ប្រធានក្រុម :

ប្រធានក្រុមទទួលខុសត្រូវ ដើម្បី ÷

–អញ្ជើញសមាជិកចូលរួម ឬ រៀនសូត្រ

–តំណាងអោយក្រុមចំពោះអ្នកផ្សព្វផ្សាយ (រួមទាំងបញ្ហាដែលប៉ះពាល់ដល់ការសងទុន)

–កំណត់អោយសមាជិកក្រុមទាំងអស់សងទុនអោយទានពេលវេលា

–ជំនួយដល់អ្នកផ្សព្វផ្សាស ដើម្បីប្រមូលបំណុលហើយនឹងតាមដានសកម្មភាពការងារផ្សេងៗទៀ ។

ង–ការប្រើប្រាស់ឥណទាន

ឥណទានដែលផ្តល់ទៅអោយប្រជាកសិករតាមរយៈមន្ទីរកសិកម្មខេត្ត ត្រូវយកទៅប្រើលើការងារផលិតស្រូវពូជ ។

ច–ការខ្ចីប្រាក់

កសិករដែលចូលរួមនឹងអោយខ្ចីជាអតិបរមាដល់កសិករនិមួយៗ នូវទឹកប្រាក់ ១០៤ ដុល្លារ សំរាប់កម្មវិធីដូចខាងក្រោមនេះ ÷

ស្រូវពូជ (ពូជB9 ,C8 និងពូជនាងខុន )ចំនួន ១០០គីឡូក្រាម សំរាប់ដី ១ ហិកតា<$១៦

- ជីអ៊ុយរ៉េ ( ៤៦–០០–០០) ចំនួន ៥០ គីឡូក្រាមសំរាប់ដី ១ ហិកតា $ < $ ១៣
- ជីឌីអាប៉ូនីញូមហ្វូស្វាត ( ១៦–២០–០០) ១០០ គីឡូក្រាម សំរាប់ដី ១ ហិកតា < $ ៣០
- ផ្តល់សំរាប់ការងាររៀបចំដី ១ ហិកតា (ភ្ជួរពីរដង រាស់ ១ដង) < $ ៣៥
- សំរាប់អន្តរាគមន៍ចំពោះការរាំងស្ងួតបើសិនមាន = $ ១០

ការផ្តល់ពូជ , ជី គឺគិតជាប្រាក់ដុល្លារអាមេរិក ។

ឆ–លក្ខខ័ណ្ឌនៃការខ្ចីប្រាក់

- លក្ខខ័ណ្ឌទីមួយ : ទិសដៅអោយសមាជិកសងគ្រប់ៗគ្នា ត្រូវមានវិធីចងក្រងជាក្រុម ១០ គ្រួសារ ធានាគ្នាទៅវិញទៅមក ហើយត្រូវជ្រើសរើសបង្កើតក្រុមដោយកសិករខ្លួនឯង ។ ការធានាបើម្នាក់ក្នុងក្រុមមិនសង សមាជិកផ្សេងទៀតក្នុងក្រុមត្រូវជួយចេញសងគ្នាអោយទាន់ពេលវេលា ។ បើសមាជិកក្នុងក្រុមមិនជួយចេញសងគ្នាទេ ភ្នាក់ងារគ្រប់គ្រងឥណទាន និងទារប្រាក់អោយគ្រប់ចំនួន ហើយលប់ឈ្មោះក្រុមនោះចោលលែងអោយខ្ចីរហូត ។
- លក្ខខ័ណ្ឌទី ២ : ធានាតំលៃដើមទុន
- លក្ខខ័ណ្ឌទី ៣ : ការខ្ចីអាចខ្ចីបានរហូតដល់ ១០៤ $ ចំពោះកសិករដែលមានដីស្រែ ១ ហិកតា ។
- លក្ខខ័ណ្ឌទី ៤ : រយៈពេលខ្ចីប៉ុន្មានខែ ?

ជ–វិធីសង :

- ត្រូវសងការប្រាក់រៀងរាល់ខែ
- បើមានលទ្ធភាពសង កសិករត្រូវសងការប្រាក់ ២ ភាគរយ
- កសិករត្រូវពិភាក្សាជាមួយភ្នាក់ងារកសិកម្មផ្សព្វផ្សាយ (នូវវិធីសង) ។

ពេលយកប្រាក់មកសង ប្រធានក្រុមត្រូវរំលឹកសមាជិកអោយយកកិច្ចសន្យាមកជាមួយផង ។

## ៤.៧ –ការងារអប់រំផ្សព្វផ្សាយបច្ចេកទេស និងការចូលរួមរបស់ប្រជាជន :

ការងារអប់រំផ្សព្វផ្សាយបច្ចេកទេសធ្វើឡើងដោយរូបភាពច្រើនយ៉ាង ក្នុងនោះរូបភាពសំខាន់ៗមាន :

- ការអប់រំផ្សព្វផ្សាយជាលក្ខណៈប្រមូលផ្តុំ
- ការអប់រំផ្សព្វផ្សាយចំពោះកសិករផ្ទាល់ទៅតាមលំនៅដ្ឋាន
- ការអប់រំផ្សព្វផ្សាយតាមរយៈការធ្វើទស្សនកិច្ច

ក–ការអប់រំផ្សព្វផ្សាយជាលក្ខណៈប្រមូលផ្តុំ

ការងារនេះបានធ្វើឡើងដោយកោះប្រជាជនមកប្រជុំអំពីការងារផ្សព្វផ្សាយ ដូចជា ÷

–របៀបធ្វើជីកំប៉ុស្ត និង អត្ថប្រយោជន៍របស់វា

–បច្ចេកទេសដាំដុះកូនឈើហូបផ្លែ

–បច្ចេកទេសដាំបន្លែ

–ប្រើប្រាស់ពូជស្រូវ

–ការធ្វើឥណទានផលិតពូជស្រូវ

–បង្រៀនបណ្តុះផ្សិត

–បច្ចេកទេសចិញ្ចឹម មាន់ ទា ត្រី ។ល។

ខ–ការអប់រំផ្សព្វផ្សាយចំពោះកសិករតាមលំនៅដ្ឋាន

អ្នកផ្សព្វផ្សាយបានណែនាំកសិករផ្ទាល់នូវបច្ចេកទេសមួយចំនួន ដូចជា - ការធ្វើជីកំប៉ុស្ត និង អត្ថប្រយោជន៍របស់វាចំពោះការថែរក្សាគុណភាពដី ។

–អោយយកចិត្តទុកដាក់លើប្រតិទិនដាំដុះ

–ពន្យល់ដល់កសិករនូវអត្ថប្រយោជន៍នៃការជីកអណ្តូងទឹក , ជីកស្រះតាមគេហដ្ឋាន ។

–អោយកសិករចេះសំអាតលំនៅដ្ឋាន និងមានអនាម័យ ។

គ–ការអប់រំផ្សព្វផ្សាយតាមរយៈការធ្វើទស្សនកិច្ច

–យើងអញ្ជើញកសិករទៅស្រែកសិករដែលគាត់ទទួលទិន្នផលខ្ពស់

–ទៅមើលកន្លែងមានបទពិសោធន៍ល្អៗសំរាប់អោយកសិករឃើញ ចាប់បាននូវបច្ចេកទេសល្អ ដើម្បីអោយគាត់យកអនុវត្តតាម ។

–ធ្វើកសិករមានមតិយោបល់ផ្លាស់ប្តូរនូវបទពិសោធន៍គ្នាទៅវិញទៅមក

### **៥.៨–កម្មវិធីឥណទានដាំបន្លែ (Credit of vegetable production)**

**១–ទំនាក់ទំនងជាមួយរដ្ឋអំណាចស្រុក ឃុំ ភូមិ ជាពិសេសគណៈកម្មការអភិវឌ្ឍន៍ដើម្បី**

- ទទួលស្គាល់ខ្លឹមសារកម្មវិធីឥណទានដាំបន្លែ
- យកពត៌មានអំពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ចនៅមូលដ្ឋាន និងជ្រើសរើសភូមិចំណុច សំរាប់កម្មវិធីដាំបន្លែ
- ឯកភាពគ្នាលើផែនការអភិវឌ្ឍន៍ឥណទានដាំបន្លែ
- យកពត៌មានអំពីការងារឥណទានរបស់អង្គការដទៃទៀត

**២–កំណត់គោលដៅបង្កើតឥណទានដំបន្លែ**

ក–យើងត្រូវធ្វើការវាយតំលៃលើចំណុចទាំងឡាយដូចខាងក្រោម ÷

- ភូមិសាស្ត្រ : យោងទៅតាមកំណត់គំរោងការឥណទានក្នុងការជ្រើសរើសភូមិចំណុច សំរាប់កម្មវិធីដាំបន្លែ
- ដីធ្លី ការបែងចែកដី (ជួល–ប្រវាស់ ឬ ដីកម្មសិទ្ធិ)
- សេដ្ឋកិច្ច : ស្ថានភាពដែលមានស្រាប់ (ការដាំបន្លែ) ។

ស្ថានភាពបំណុលរបស់កសិករ ទីតាំងរបស់ឈ្មួញរកស៊ីចងការប្រាក់ និងអត្រាការប្រាក់ ក៏រិត ជីវភាពប្រជារាស្ត្រ ។

- ប្រជារាស្ត្រ : អ្នកភូមិកំណើត អ្នកចំណូលថ្មីលំនឹងនៃគ្រួសារ ។
- សហគមន៍ : មានទំនាស់បាក់បែកព្រាត់ប្រាស់ ២ វិបត្តិធំៗ ដែលមាននៅក្នុងភូមិ ឃុំ ក្នុងរយៈពេលកន្លងមក ។
- រដ្ឋអំណាច : ទទួលស្គាល់ពីប្រជារាស្ត្រ ភាពសកម្មការដោះស្រាយបញ្ហាសង្គម
- ទំនៀមទំលាប់មិនល្អ : ល្បែងស៊ីសង ប្រមឹក , ចោរ និងប្រការផ្សេងៗទៀត ។

**៣–គោលបំណងកម្មវិធីឥណទានដាំបន្លែ**

- គាំទ្រកសិករដាំបន្លែ ផ្តល់ឥណទាន និងបច្ចេកទេសកសិកម្ម
- ជ្រើសរើសកសិករ ៦០ នាក់
- ការជ្រើសរើសយ៉ាងហោចណាស់ ៥០ ភាគរយ ជាស្ត្រី
- បង្កើតក្រុមឥណទានដែលមានសមាជិក ១០ នាក់
- ផ្តល់ទុនដល់ទៅ $ ២០០ ចំពោះអ្នកចូលរួមម្នាក់
- យកការប្រាក់ ៣ ភាគរយ ក្នុងមួយខែ
- ប្រមូលដើមទុនដែលសងបូករួមជាមួយការប្រាក់អំពីកសិករដែលខ្ចី

**៤–ការជ្រើសរើសតំបន់ចំណុច**

តំបន់អភិវឌ្ឍន៍ទីមួយ

ស្រុក មង្គលបូរី និងសេរីសោភ័ណ

ឃុំ

តំបន់ដែលអាចដាំបន្លែបាន ឫស្សីក្រោក បន្ទាយនាង អូរប្រាសាទ កោះពងសាត់ ព្រះពន្លា និងកំពង់ស្វាយ ។

ក–ការជ្រើសរើសភូមិ

- ប្រភពទឹកអាចធានាបាន
- មានដីសំរាប់ដាំបន្លែ
- មានប្រព័ន្ធរំដោះទឹកបានល្អ តំបន់ដែលអាចដាំបន្លែ

ខ–ការជ្រើសរើសកសិករចូលរួម

កសិករដែលជ្រើសរើស និងយោងទៅលើលក្ខណៈសម្បត្តិដូចខាងក្រោមនេះ :

- កសិករសកម្ម ហើយមានផ្ទៃដីដាំបន្លែយ៉ាងតិច ១ ហិកតា
- មានបំណងចូលជាក្រុមឥណទាន ហើយចូលរួមប្រជុំក្នុងវគ្គបំពាក់បំប៉នបច្ចេកទេស
- មានទំនាក់ទំនងល្អ ហើយជាអ្នកនៅក្នុងចំណោមអ្នកក្រីក្រក្នុងសហគមន៍
- ត្រូវបង់ការប្រាក់ ៣ ភាគរយ រៀងរាល់ខែ
- ត្រូវសងដើមទាំងអស់នៅពេលប្រមូលផល
- ត្រូវទទួលធានាគ្នាទៅវិញទៅមក (តាមក្រុម) ក្នុងករណីមិនសង
- មានបំណងទទួលផលប្រយោជន៍ពីការបំពាក់បំប៉ន

## ៥–រៀបចំក្រុម

(មុនដំបូង) : សមាជិកត្រូវយល់ពីការងារសំខាន់របស់ឥណទានក្នុងគំរោងផលិតដំណាំបន្លែ (មុននឹងក្រុមចាប់ដំណើរការ ) ។ យល់ដឹងអំពីគោលបំណងនៃឥណទានដែលផ្តល់ ។

(បន្ទាប់មក) : រៀបចំក្រុមដោយខ្លួនឯង ដែលមានសមាជិក ១០ នាក់ សមាជិកជ្រើសរើសប្រធានក្រុមរបស់ខ្លួន ។

ក–លក្ខណៈសម្បត្តិ ប្រធានក្រុម :

- ប្រធានក្រុមជាអ្នកមានលក្ខណៈសម្បត្តិ ស្វាហាប់ ស្មោះត្រង់ ហ៊ានទទួលខុសត្រូវចំពោះសមាជិកខ្លួន ។
- ប្រធានក្រុមជាបេក្ខជនដែលត្រូវជ្រើសរើសដោយសមាជិកក្នុងក្រុម (ចំណុចសំរាប់រំលឹកប្រជាកសិករ ) ប្រជាកសិករ គួរជ្រើសរើសប្រធានក្រុមរបស់ខ្លួនដែលមានលក្ខណៈសម្បត្តិជាប្រជាពលរដ្ឋសុទ្ធសាធ លំនៅដ្ឋានហ្នឹងនរ ស្មោះត្រង់នឹងការងារ គួរចេះគិតលេខ រក្សាទុកឯកសារដែលមាន ។
- ពេលជ្រើសរើសប្រធានក្រុម ត្រូវមានសមាជិកឥណទានទាំងអស់ចូលរួម ។

ខ–តួនាទីរបស់ប្រធានក្រុម :

ប្រធានក្រុមត្រូវទទួលខុសត្រូវដើម្បី :

- អញ្ជើញសមាជិកចូលរួមប្រជុំ ឬរៀនសូត្រ
- តំណាងអោយក្រុមចំពោះអ្នកផ្សព្វផ្សាយ (រួមទាំងបញ្ហាដែលប៉ះពាល់ដល់ការងារទុន)
- កំណត់អោយសមាជិកក្រុមទាំងអស់ សងទុនអោយទាន់ពេលវេលា
- ជំនួយដល់អ្នកផ្សព្វផ្សាយដើម្បីប្រមូលបំណុល ហើយនឹងតាមដានសកម្មភាពការងារផ្សេងៗទៀត ។

## ៦–ទំហំថវិកា

អង្គការ **CARERE** មានគោលការណ៍ផ្តល់លុយដល់សមាជិកឥណទាន ដោយយោលទៅតាមទំហំនៃទឹកប្រាក់ដែលអាចបំរើបាននូវដំណើរនៃសកម្មភាពនិមួយៗ ។ សំរាប់កសិករដែលស្ម័គ្រចិត្តមកចូលរួមក្នុងគំរោងផលិតបន្លែនេះ អង្គការ **CARERE** នឹងផ្តល់ជូននូវថវិកាអោយខ្ចី ដើម្បីយកទៅ

បំរើលើគំរោងផលិតបន្លែចំនួនជាអតិបរមា ២០០ $ ដុល្លារអាមេរិក ក្នុងមួយគ្រួសារដែលមានផ្ទៃដីដាំបន្លែ ពី ០,៥ ហិកតា ទៅ មួយហិកតា អាស្រ័យលើផ្ទៃដី និងមុខបន្លែត្រូវដាំដុះ (ដោយទូទាត់ជាទឹកប្រាក់អោយខ្ចី ) ។ ចំពោះគ្រួសារដែលមានផ្ទៃដីដំណាំបន្លែ ១ រ៉ៃ ទៅ ៣ រ៉ៃ (តិចជាងកន្លះហិកតា) នោះ បរិមាណថវិកាដែលត្រូវអោយខ្ចីទាបជាង ២០០$ ដុល្លារអាមេរិក ។

**៧–កាលបរិច្ឆេទនៃការខ្ចី និង សង**

ក្នុងការខ្ចី និងសងនេះ អង្គការ **CARERE** បានរៀបកិច្ចសន្យាមួយ ហើយដាក់អោយសមាជិកឥណទានរបស់ខ្លួនទទួលស្គាល់ និងចុះហត្ថលេខានោះ ដើម្បីទទួលខុសត្រូវ និងគោរពតាម ។

**៨–ការខ្ចីប្រាក់**

• លក្ខការណ៍ទីមួយ : ទិសដៅអោយសមាជិកសងបានគ្រប់ៗគ្នា ត្រូវមានវិធីចងក្រងជាក្រុម ១០ គ្រួសារ ធានាគ្នាទៅវិញទៅមក ហើយត្រូវជ្រើសរើសបង្កើតក្រុមដោយប្រជាកសិករខ្លួនឯង ។ ការធានា បើម្នាក់ក្នុងក្រុមមិនសង សមាជិកផ្សេងទៀតក្នុងក្រុមត្រូវជួយចេញសងគ្នាអោយទាន់ពេលវេលា ។ បើសមាជិកក្នុងក្រុមមិនជួយចេញសងគ្នាទេ ភ្នាក់ងារគ្រប់គ្រងឥណទាន និងទារប្រាក់អោយបានគ្រប់ចំនួន ដោយលប់ឈ្មោះក្រុមនោះចោល លែងអោយខ្ចីរហូត ។ កម្មវិធីឥណទានមិនអាចលើកលែងចំពោះការប្រើប្រាស់ទុនខុសការអប់រំរបស់មន្ទីរកសិកម្មបានឡើយ ។

• លក្ខការណ៍ទី ២ : ធានាតំលៃដើមទុន

• លក្ខការណ៍ទី ៣ : ការខ្ចីអាចខ្ចីរហូតដល់ ២០០ $ ចំពោះកសិករដែលមានផ្ទៃដីដាំបន្លែដល់ទៅមួយហិកតា ។

• លក្ខការណ៍ទី ៤ : រយៈពេលខ្ចីកំណត់ពីថ្ងៃទី .....ខែ ........ ឆ្នាំ ១៩៩៥ ។ រយៈពេលខ្ចីកំណត់ទៅតាមការពិភាក្សាសមស្របទៅតាមប្រភេទបន្លែដែលប្រជាកសិករដាំ និងយោងទៅតាមមូលដ្ឋាននិមួយៗ ។

៩–ការសង ឬ វិធីសង

• ត្រូវសងការប្រាក់រៀងរាល់ខែ

• បើមានលទ្ធភាពសងកសិករត្រូវសងការប្រាក់ពាក់កណ្ដាលរយ ដោយអាចរំលោះដើមខ្លះក៏បាន។ កសិករត្រូវពិភាក្សាជាមួយភ្នាក់ងារកសិកម្មផ្សព្វផ្សាយ (នូវវិធីសង) ។ ពេលយកប្រាក់មកសងប្រធានក្រុមត្រូវរំលឹកសមាជិកអោយយកកិច្ចសន្យាមកជាមួយផង ។

**៦–កម្មវិធីអភិវឌ្ឍន៍របស់អង្គការ UNDP / CARERE**

ការអភិវឌ្ឍន៍សហគមន៍ គឺជាផ្នែកមួយដ៏សំខាន់នៃកម្មវិធីអង្គការ **CARERE** ដែលជំរុញអោយមានកម្មវិធីអភិវឌ្ឍន៍រយៈពេលវែង នឹងមានតួនាទីទំនាក់ទំនងលើគ្រប់វិស័យ ។

ដែលមានការផ្គត់ផ្គង់ជាលុយកាក់ហើយនោះ គឺជាកិច្ចការដែលគេបានយកចិត្តទុកដាក់យ៉ាងខ្លាំង ។ នៅពេលដែលរដ្ឋាភិបាលបានបញ្ជាក់នូវតួនាទីរបស់ទីស្តីការរដ្ឋមន្ត្រីទាំងឡាយ និងពង្រីកផែនការ និងរបៀបធ្វើការចែកចាយធនធាន កម្មវិធីនេះក៏នឹងផ្តោតទៅលើការបង្កើនការគាំទ្រកិច្ចអភិវឌ្ឍន៍នៃសកម្មភាព និងសមត្ថភាពធ្វើផែនការតាមមូលដ្ឋាន ប្រការនេះនឹងត្រូវបំពេញអោយសំរេចដោយការរៀបចំជាដំណាក់ៗដូចតទៅ ÷

- ការវាយតម្លៃរួមដោយបុគ្គលរបស់អង្គការ **CARERE** និងគណៈកម្មាធិការបច្ចេកទេសវិនិយោគមុនៗ និងគំរោងធ្វើឆាប់រហ័ស និងការតភ្ជាប់ជាចាំបាច់រវាងគំរោងនេះ និងទិសដៅ និងផែនការពាក់ព័ន្ធជាមួយរដ្ឋាភិបាល ។
- ការបញ្ជាក់រួមពីសកម្មភាពបំពេញបន្ថែម និងថ្មីៗសំរាប់រៀបចំការផ្តល់ហិរញ្ញវត្ថុដោយរដ្ឋាភិបាល និងអង្គការ យូ អ៊ិន ឌី ភី ។

យុទ្ធសាស្ត្រធ្វើអន្តរាគមន៍នេះមានមូលដ្ឋានឈរលើការចាំបាច់ត្រូវបន្តអនុវត្តគំរោងទាំងឡាយដោយមានការចូលរួមទាំងស្រុងពីមូលដ្ឋាននៅពេលដែលជំរុញវទាក់ទងជាមួយនឹងរដ្ឋាភិបាល ។

ដំណើរការចូលរួមរបស់អង្គការ **CARERE** ជាការសំខាន់ណាស់ ពីព្រោះគំរោងទាំងនេះមិនអាចស្ថិតស្ថេរដោយខ្លួនឯងបានឡើយ ឬក៏មិនអាចធ្វើវិភាគទានដល់ការអភិវឌ្ឍន៍ដែលមានរយៈពេលវែងបានទេ លើកលែងតែឆ្លងកាត់តាមរយៈដំណើរការនេះ ។ ការចូលរួមជាការពង្រឹងអង្គការនានាតាមតំបន់ក៏ដូចជារចនាសម្ព័ន្ធ និងយន្តការនៅថ្នាក់ស្រុក ហើយជាការតភ្ជាប់រវាងអង្គការរចនាសម្ព័ន្ធ និងយន្តការទាំងនេះទៅនឹងអាទិភាពនៃការអភិវឌ្ឍន៍តាមខេត្ត ។

ដើម្បីពង្រឹងសមត្ថភាពចូលរួម និងទាញយកផលប្រយោជន៍ដែលបានមកពីកិច្ចប្រឹងប្រែងនេះអង្គការ **CARERE** នឹងផ្តល់ដល់អង្គការប្រចាំកន្លែងនូវការគាំទ្របន្ថែមខាងបច្ចេកទេស , ភស្តុភារ , ហិរញ្ញវត្ថុ និងប្រតិបត្តិការដែលតម្រូវសំរាប់ធ្វើសកម្មភាពដែលមានមានឯកភាពគ្នាហើយ ។ ទំហំនៃការគាំទ្ររបស់ភាគី ជាសំភារៈ ជាលុយកាក់នឹងត្រូវគេសាកល្បងមើលសិន ។

សកម្មភាពទាំងឡាយនៃកម្មវិធីនឹងត្រូវអនុវត្តដោយការចូលរួមពីគណៈកម្មាធិការតាមមូលដ្ឋានអង្គការក្រៅរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ និងរដ្ឋាភិបាលក្នុងស្រុក ។ អង្គការ **CARERE** នឹងបង្កើនសមត្ថភាពអោយកាន់តែខ្លាំងដើម្បីទាក់ទាញទីស្តីការរដ្ឋមន្ត្រីរបស់រដ្ឋបាលក្នុងស្រុកអោយចូលរួមក្នុងការផ្តល់ការដឹកនាំ និងការគាំទ្រខាងបច្ចេកទេសដែលតម្រូវតាមសំណូមពរ ។

យុទ្ធសាស្ត្រនេះនឹងជួយអោយគេថ្លឹងថ្លែងទុនវិនិយោគលើគ្រប់វិស័យក្នុងតំបន់ជាទិសដៅបានដោយរួមជាមួយនឹងរដ្ឋបាលស្រុកនិមួយៗដែលរីកចំរើនផ្នែកសមត្ថភាពដឹកនាំ និងជួយជំរុញអោយបានដល់កំរិតអតិបរមានូវការវិវត្តន៍គោលនយោបាយ និងកម្មវិធីទៅអនាគតសំរាប់រដ្ឋាភិបាល ដែលអាស្រ័យដោយសមត្ថភាពនេះ និងដែលត្រូវគាំទ្រដោយអង្គការ **CARERE** ដើម្បីជួយជំរុញសហគមន៍អោយបោះជំហានទៅមុខបានដោយខ្លួនឯង ។ បញ្ហានេះនឹងគាំទ្រដល់ដំណើរការអភិវឌ្ឍន៍សំរាប់ទ្រទ្រង់ខ្លួនឯងបាន ហើយអាចបន្តកិច្ចអភិវឌ្ឍន៍នេះតទៅទៀតបានពេលណាដែលអង្គការ **CARERE** ដកខ្លួនចេញ ។

ការអភិវឌ្ឍន៍សហគមន៍តំរូវអោយមានការយកចិត្តទុកដាក់លើរបៀបរៀបចំចាត់ចែងរបស់ប្រជាពលរដ្ឋ ដោយចាត់ទុកវាដូចជាមធ្យោបាយមួយដើម្បីបន្ត និងរក្សាសកម្មភាពរបស់សហគមន៍អោយមានការអភិវឌ្ឍន៏រឹងមាំ ។

សហគមន៍គាំទ្រផងដែរនូវការកកើតវិធីសាស្ត្រខ្លួនក្នុងក្របខ័ណ្ឌអង្គការ **CARERE** ជាមួយអង្គការផ្សេងៗ និងជាមួយរដ្ឋាភិបាលក្នុងការបង្កើតអោយមានអន្តរសកម្មភាពជាមួយអ្នកភូមិ ។

បច្ចុប្បន្ននេះ អង្គការ **CARERE** បានស្នើសុំប្រើអភិវឌ្ឍន៍សហគមន៍ ដូចជាមូលបទមួយដើម្បីជំរុញដំណើរការអភិវឌ្ឍន៍អោយរឹងមាំបានរយៈពេលវែង ដែលអាចជួយអោយប្រជាពលរដ្ឋកម្ពុជាពង្រឹកសមត្ថភាព និងសកម្មភាពនានាសំរាប់ការអភិវឌ្ឍន៍សហគមន៍នេះអោយរឹងមាំបាន ។

នៅគ្រប់វិធីសាស្ត្រដែលចែកជាផ្នែកៗរបសហគមន៍អង្គការ **CARERE** នឹងប្រើវិធីសាស្ត្រអភិវឌ្ឍន៍សហគមន៍ ដើម្បីជំរុញការឈានទៅរក «វិធីអភិវឌ្ឍន៍ដោយមានការចូលរួមសស្រាក់សស្រាំពីប្រជាពលរដ្ឋទាំងពីរប្រភេទ និងដោយឈរលើសហគមន៍ » ។

ប្រជាពលរដ្ឋកម្ពុជា ត្រូវតែប្រឈមមុខចំពោះបញ្ហាជាច្រើនដែលបណ្តាលមកពីមហន្តរាយកន្លងមកដល់ប្រទេសនេះ ។ យោងទៅតាមការស្ទាបស្ទង់នៃការអភិវឌ្ឍន៍សហគមន៍របស់អង្គការ **CARERE** ។

បញ្ហាទីមួយសំខាន់ គឺជាបញ្ហាសេដ្ឋកិច្ច ដែលខ្វះដីធ្លី និងដើមទុន ។ ផលវិបាកដ៏ចំបងមួយនៃបញ្ហានេះ គឺការខ្វះស្រូវ អង្ករដែលដាំដុះក្នុងស្រុក ។

បញ្ហាទី ២ : គឺបញ្ហាព្រាត់ប្រាស់គ្រួសារនៃសង្គមជាតិ ការខិតខំប្រឹងប្រែងដោះស្រាយចំពោះជនពិការ និងជនអសមត្ថភាព ការខូចខាតរចនាសម្ព័ន្ធសង្គមរបស់សហគមន៍ មានមេផ្ទះភាគច្រើនជាស្ត្រីភេទដែលមានលក្ខណៈមិនស្មើគ្នា ។

បញ្ហាទី ៣ : ទាក់ទងនឹងសុខភាពនិងអនាម័យ ។

ស្ថានភាពសុខភាពធ្លាក់ចុះធ្ងន់ធ្ងរដោយការអប់រំមិនបានជិតដល់អំពីការអនុវត្តទំលាប់អនាម័យស្អាតត្រឹមត្រូវ ហើយវាកាន់តែធ្ងន់ធ្ងរថែមទៀតនៅក្នុងកន្លែងជាច្រើនដែលខ្វះទឹកស្អាត ។ ជាងនេះទៀតឧបករណ៍សុខាភិបាល មិនបានគ្រប់គ្រាន់ ហើយថ្នាំពេទ្យមិនអាចគ្រប់គ្រាន់ទៅតាមសេចក្តីត្រូវការ ។

### ៦.១—គោលបំណង និងទិសដៅជាយុទ្ធសាស្ត្ររបស់កម្មវិធី

គោលបំណងធ្វើអភិវឌ្ឍន៍ជាយុទ្ធសាស្ត្រនៃកម្មវិធីរបស់អង្គការ **CARERE** មាន :

ជំនួយការដល់រដ្ឋាភិបាល និងពលរដ្ឋរបស់ប្រទេសកម្ពុជាក្នុងការបង្កើតផែនការ , ការអនុវត្តន៍ការត្រួតពិនិត្យ , ការវាយតម្លៃកម្មវិធីអភិវឌ្ឍន៍ ជាក់ស្តែងមានប្រសិទ្ធភាព និងមានផលប្រយោជន៍អាចទ្រទ្រង់ខ្លួនអោយស្ថិតនៅបាន ។ កម្មវិធីនេះទាក់ទងនឹងគោលនយោបាយរបស់រដ្ឋាភិបាល និងសេចក្តីត្រូវការតាមកន្លែង ហើយជាប់ទាក់ទិននឹងបុរស និងស្ត្រី តាមគ្រប់ទិដ្ឋភាពនៃដំណើរការ ហើយនិងជួយលើកស្ទួយដល់ក៏រិតជីវភាពផ្នែកសេដ្ឋកិច្ច និងសង្គម ។

ជាពិសេសទិសដៅរបស់អង្គការ **CARERE** មានដូចតទៅ ៖

ក–ជំរុញ , ពង្រឹង , និងគាំទ្រដំណើរការសន្តិភាព , នយោបាយផ្សះផ្សា , និងបញ្ចូលជនផ្លាស់ទីកន្លែងអោយចូលទៅក្នុងជីវភាពជាតិឡើងវិញ ជំរុញអោយមានយន្តការនៃការបង្កើតអោយមានដំណោះស្រាយស្ថាប័ននិងសង្គម ដើម្បីអភិវឌ្ឍន៍តាមមូលដ្ឋាន ។

ខ–សំរាប់រយៈពេលខ្លី បង្កើតយន្តការដែលល្មមដំណើរការបានដើម្បីសំរួលការងារជាទិសដៅរបស់សហគមន៍ជាមួយនឹងទីចាត់ការតាមមូលដ្ឋានភ្លាមៗ (ដូចជាៈ ផ្នែកសុខភាព , ផ្នែកអប់រំ និងខាងរដ្ឋាករទឹក) ដើម្បីដាក់ចេញជាលក្ខខ័ណ្ឌតិចបំផុតសំរាប់ការស្តារប្រព័ន្ធសេដ្ឋកិច្ច និងសង្គមកិច្ចឡើងវិញ និងជំរុញអោយមានការចូលរួមអំពីសហគមន៍អោយបានដល់កំរិតអតិបរមាក្នុងការធ្វើគំរោង និងការអនុវត្តន៍ផែនការ ។

គ–សំរាប់រយៈពេលមធ្យម និងរយៈពេលវែង ជំរុញដំណើរការស្តារសេដ្ឋកិច្ចអោយមានសកម្មភាពឡើងវិញ ជំរុញការកែទំរង់ផលិតភាព និងការរីតចំណងទាក់ទងកាន់តែរឹងមាំរវាងមជ្ឈមណ្ឌលផលិតកម្ម និងទីផ្សារ ។ សំភារៈ និងរបៀបសំខាន់ៗ គួរតែរាប់បញ្ចូលទាំងជំនួយ និងការហ្វឹកហ្វឺនបច្ចេកទេស ការស្តារផលិតកម្មស្រូវ ការធ្វើដំណាំតាមប្រភេទ និងពូជខុសៗគ្នា ការបង្កើតអោយមានការងារប្លែកៗគ្នា បណ្តាញទាក់ទងកាន់តែល្អប្រសើរ ការអាចខ្ចីលុយកាក់បាន អាចរក្សាអោយគង់វង់នៅបាន និងកែលំអបរិស្ថានអោយកាន់តែប្រសើរឡើងនៅតាមអង្គការនានានៅមូលដ្ឋាន ។

ឃ–ជំរុញ និងពង្រឹងរបៀបរបបការងារគ្រប់គ្រងចាត់ចែងដោយរដ្ឋាភិបាលក្នុងការរៀបចំអោយមានវិជ្ជការ និងការចូលរួម ដើម្បីបង្កើតសមត្ថភាពតាមថ្នាក់ខេត្ត និងថ្នាក់ស្រុកដើម្បីធ្វើអោយមានគំនិតផ្តួចផ្តើមធ្វើអភិវឌ្ឍន៍ជាក់ស្តែងបានដោយផ្អែកទៅលើមូលដ្ឋាននៃការស្រុះស្រួលគ្នា ។

## ៦១.១–តំបន់ជាទិសដៅកំណត់

ការជ្រើសរើសតំបន់សំរាប់ធ្វើអន្តរាគមន៍នៃកម្មវិធី ត្រូវផ្អែកលើមូលដ្ឋាននៃលក្ខណៈវិនិច្ឆ័យដូចតទៅនេះ ៖

ក–សមាមាត្រដ៏ធំនៃមនុស្សដែលមិនគិតពីផលប្រយោជន៍ខាងសេដ្ឋកិច្ច ឬសង្គមកិច្ច (ជាពិសេស មិនមែនកំរិតទៅលើជនមាតុភូមិនិវត្តន៍ និងជនផ្លាស់ទីកន្លែងនោះឡើយ)

ខ–យ៉ាងហោចណាស់ វត្តមាននៃប្រភពធនធានដែលមានស្រាប់ និង / ឬក៏មូលដ្ឋានផលិតកម្មដែលមានលទ្ធភាពអាចជួយគាំទ្រដល់ពលរដ្ឋជាគោលដៅក្នុងរយៈពេលមធ្យម និងរយៈពេលវែង ។

គ–បង្កើតអោយមានការចូលរួមក្នុងការគាំទ្រនៅថ្នាក់ខេត្ត ជាពិសេសចំពោះ «កម្មវិធីជាតិដើម្បីកែទំរង់រដ្ឋាភិបាល» របស់រដ្ឋាភិបាលក្នុង ÷

i ការសំរបសំរួលការផ្តល់ជំនួយ

ii ការកែទំរង់យន្តការធ្វើផែនការនៅថ្នាក់ខេត្ត

ឃ–សមត្ថភាពដែលស្រាយបំភ្លឺបានយ៉ាងហោចណាស់ក៏កំរិតមួយទាបបំផុតត្រឹមចេះចាត់ចែង តាមស្ថាប័ន និង សង្គម ដើម្បីសំរួលដល់ការផ្តើមគំនិតធ្វើការគ្រប់គ្រងតាមមូលដ្ឋាន ការអនុវត្តន៍ និងងការអភិវឌ្ឍន៍ប្រទាក់ប្រទងគ្នានៃស្ថាប័ន មូលដ្ឋាន ។

ង–អវត្តមាន ឬក៏វត្តមានដ៏តិចតួចនៃគំរោងការណ៍ កម្មវិធីសហប្រតិបត្តិការ អភិវឌ្ឍន៍អន្តរជាតិដទៃៗទៀត និង

ច–កំរិតដ៏ទាបបំផុតនៃហេដ្ឋារចនាសម្ព័ន្ធតម្រូវអោយមានសំរាប់ទ្រទ្រង់ដល់ផលិតកម្មតាមមូលដ្ឋានក្នុងគោលបំណងរួមបញ្ចូលស្រុក និងស្រុកអោយនៅជាមួយគ្នាក្នុងគោលបំណងរួមបញ្ចូលស្រុក និងស្រុកអោយនៅជាមួយគ្នាក្នុងក្របខ័ណ្ឌតំបន់ និងសំរាប់រយៈពេលវែងនៅក្នុងវិស័យសេដ្ឋកិច្ចជាតិ ។

ខណៈដែលសេចក្តីសំរេចអនុវត្តកម្មវិធីក្នុងតំបន់ទាំងឡាយដែលគេបានជ្រើសសំរាំងរួចហើយនោះ ត្រូវផ្អែកទៅលើតម្រូវការមួយដើម្បីអភិវឌ្ឍន៍ធនធានមូលដ្ឋាន (កថាខ័ណ្ឌ ខ) ខាងលើ , យុទ្ធសាស្ត្រនេះនឹងចប់មុននឹងបង្កើតតំបន់ដែលមានបុព្វសិទ្ធិមិនស្មើគ្នា ។ ទន្ទឹមនេះ វានឹងជួយរួមចំណែកក្នុងការបែងចែកធនធានក្នុងប្រទេស និងក្រៅប្រទេសអោយបានសមហេតុសមផល ដើម្បីបង្កើតផលិតផលអោយបានល្អតលាស់ជាប់ជានិច្ច ។

ដោយអនុលោមតតាមលក្ខណៈវិនិច្ឆ័យនេះ ការរៀបចំផែនការធ្វើសកម្មភាពនានាក្នុងតំបន់ទាំងឡាយដែលជាទិសដៅកំណត់ បានបង្ហាញអោយឃើញពីការប្រើប្រាស់ផលប្រយោជន៍ពីធនធានរួមខាងសេដ្ឋកិច្ច និងសង្គមកិច្ចបានដូចខាងក្រោមនេះ ÷

–ការពង្រីក និងការកែលំអផលិតកម្មកសិកម្ម និងការទាញយកផលពីប្រភពធនធានត្រី និងព្រៃឈើ ដោយឈរលើមូលដ្ឋានដែលមិនចេះរីងស្ងួត ។

–ការកែលំអហេដ្ឋារចនាសម្ព័ន្ធផលិតកម្ម និងបណ្តាញផ្លូវថ្នល់

–ការកែលំអបច្ចេកវិទ្យាតាមមូលដ្ឋាន និងការណែនាំអោយបានស្គាល់នូវបច្ចេកវិទ្យាថ្មី ដោយមានការយកចិត្តទុកដាក់ជាពិសេសលើការថែរក្សាបរិយាកាស និងបរិស្ថានវិទ្យាដែលមានផលប្រយោជន៍ ។

–ការបង្កើតការងារអោយបានច្រើនខណៈសាៗគ្នា

–សកម្មភាពដើម្បីបន្ថយពេលវេលា ដែលប្រើប្រាស់ទៅលើកិច្ចកបរដែលធ្វើដោយស្ត្រីមេគ្រួសារ ដើម្បីជួយអោយរស់រានដល់គ្រួសាររបស់ខ្លួន គឺដើម្បីអោយគេអាចឆ្លៀតឱកាសរកបានប្រាក់ចំណូលសំរាប់គ្រួសារ ។

### ៦.១.២–ទំហំនៃកម្មវិធី

កម្មវិធីនេះនឹងបំពេញសកម្មភាពរួមគ្នាដែលត្រូវប្រមូលផ្តុំនៅថ្នាក់ឃុំ ឬថ្នាក់សហគមន៍ និងប្រមូលផ្តុំលើគោលបំណង និងទិសដៅរបស់វា ។ ការបន្តអោយមានសកម្មភាពសេដ្ឋកិច្ច និងសង្គម

លំនឹង និងភាពមិនដាច់ពីគ្នារបស់អង្គការ CARERE នឹងសំរេចបានដោយឆ្លងកាត់តាមការបំពេញកិច្ចប្រឹងប្រែងទៅតាមកម្មវិធីដែលរៀបចំ និងសំរបសំរួល ហើយតាមកំរិតបីខុសៗគ្នា ប៉ុន្តែស្របគ្នានឹងបំពេញអោយគ្នាទៅវិញទៅមក ÷

នៅកំរិតសហគមន៍ដែលបានចូលរួម : ការពង្រឹងយន្តការ ដើម្បីអោយមានការចូលរួមក្នុងកម្មវិធី ផ្តើមចេញអំពីការបញ្ជាក់សកម្មភាពនានាដោយឆ្លងតាមការអនុវត្តន៍ និងការចាត់ចែងធ្វើសកម្មភាពនោះ និងការវាយតម្លៃសកម្មភាពនោះ ។

នៅថ្នាក់ស្រុក : ការលើកកំពស់កំរិតសមត្ថភាពរបស់រដ្ឋាភិបាលដើម្បីធ្វើផែនការ និងអនុវត្តគំរោងតាមផ្នែកៗ ។ បញ្ហានេះនឹងរាប់បញ្ចូលទាំងការគាំទ្រចំពោះការរៀបចំគំរោងផលិតកម្ម និងហេដ្ឋារចនាសម្ព័ន្ធដែលនឹងបង្កើតអោយមានជាមូលដ្ឋានសំរាប់ការពិភាក្សាផ្តល់ថវិកាជាថ្មី ។

នៅថ្នាក់ខេត្ត : ការទទួលស្គាល់នូវការចាំបាច់មាននិវិធីធ្វើការ ដែលផ្តោតទៅលើតំបន់នានា និងមិនមែនទៅលើក្រុមមនុស្សជាគោលដៅ ដូចជា (អ្នកធ្វើមាតុភូមិនិវត្តន៍ ជនផ្លាស់ទីកន្លែងក្នុងស្រុក និងអ្នករស់នៅតាមការប្រមូលផ្តុំជាក្រុមមួយ) ដោយផ្អែកទៅលើប្រការដែលដំណើរការស្តារឡើងវិញ និងដំណើរអភិវឌ្ឍន៍ ដោយមិនគិតពីកត្តាដទៃៗទៀតនោះ បានពឹងផ្អែកជាចំបងទៅលើល័ក្ខខ័ណ្ឌជារួមសំរាប់បង្កើតផលិតផល និងការរកទីផ្សារ ។

ដើម្បីជំរុញយុទ្ធសាស្ត្រនេះអោយបានសំរេចជោគជ័យ ត្រូវអនុវត្តកម្មវិធីនេះយ៉ាងជិតស្និទ្ធជាមួយរដ្ឋអំណាចខេត្ត និងរដ្ឋបាលសាធារណៈដែលត្រូវកែទម្រង់តាមដែលវាបាននិវត្តដោយពង្រឹងសមត្ថភាពបច្ចេកទេស និងរដ្ឋបាលរបស់គេ ។ ក៏នៅមានឱកាសសំរាប់ធ្វើការផ្តល់កោសល្យវិស័យបច្ចេកទេសដែលគេត្រូវការក្នុងកិច្ចការរដ្ឋបាលសាធារណៈ និងការធ្វើផែនការពេលដែលប្រព័ន្ធផែនការរបស់រដ្ឋាភិបាលបានកើតឡើងហើយ ។

## ៦.២–យុទ្ធសាស្ត្រដំណើរការរបស់កម្មវិធី

ដូចបានចង្អុលបង្ហាញរួចមកហើយ កម្មវិធីនេះត្រូវតែមាននិធីបញ្ចូលគ្នាទាំងស្រុង ឆ្ពោះទៅរកកំណែប្រែលើកិច្ចប្រឹងប្រែងធ្វើការបង្រួបបង្រួមជាថ្មី និងការស្តារឡើងវិញនេះអោយទៅជាដំណើរការអភិវឌ្ឍន៍មួយដែលអាចស្ថិតនៅបានយូរអង្វែង ។ ការនេះញុាំងអោយមានសហប្រតិបត្តិការស្និតរម្ជួតរវាងអង្គការ CARERE និងកម្មវិធីនៃអ្នកធ្វើអំណោយផ្សេងទៀត និងបើកាលណាមានការចង់បានទៅវិញទៅមកក៏មានការចែកចាយសំភារៈការងារ ក៏ដូចជាការធ្វើអោយមានសហប្រតិបត្តិការរួមដើម្បីបង្កើតកម្មវិធីដែរ ។

តាមកំរិតកម្មវិធី ចាំបាច់ត្រូវធ្វើសកម្មភាពទាំងឡាយក្នុងវិស័យផ្សេងៗដែលរណបគ្នា និងដែលទាក់ទងគ្នាទៅវិញទៅមក រាប់បញ្ចូលមាន :

- ផលិតកម្មកសិកម្ម
- បង្កើតការងារ និងប្រាក់ចំណូល
- ឥណទាន

- ទឹក និងអនាម័យ
- សុខភាព និង
- ហេដ្ឋារចនាសម្ព័ន្ធនៅជនបទ (រាប់បញ្ចូលបណ្ដាញផ្លូវថ្នល់ និងសាលារៀន)

គ្រប់ផ្នែកទាំងអស់របស់អង្គការ **CARERE** ក្រោយពីបានទទួលហិរញ្ញវត្ថុ ហើយនឹងផ្ដើមដំណើរការព្រមទាំងរួមបញ្ចូលគ្នាដោយផ្អែកលើវិធីសាស្ត្រអភិវឌ្ឍន៍របស់សហគមន៍ ហើយបំពេញការងារឈានទៅកសាងស្ថានប័ននៅមូលដ្ឋាន ។

មាតិនិមួយៗនៃសកម្មភាព និង/ ឬអនុកម្មវិធីដែលបានកត់សំគាល់ ឬបានស្នើដោយសហគមន៍ទាំងឡាយ និងអ្នកតំណាងរបស់ពួកគេ ឬរដ្ឋអំណាចប្រចាំកន្លែង នឹងត្រូវឆ្លងកាត់ការសិក្សាបច្ចេកទេស (ចាប់ពីតម្រូវការអោយមានផ្នែកបច្ចេកទេស ក៏រិតទាបបំផុតទៅដល់ការសិក្សាអនុវត្តន៍ជាក់ស្ដែង ដោយផ្អែកលើឥទ្ធិពលនៃគំរោង ឬតម្រូវការផ្នែកហិរញ្ញវត្ថុ ដែលគេបានរំពឹងគិតទុកជាមុន) ដែលរួមមានពតិមានដូចតទៅ :

- បរិមាណ និងគុណភាពលទ្ធផលដែលត្រូវរំពឹងទុក
- ការបង្ហាញយ៉ាងច្បាស់លាស់អំពីការទទួលខុសត្រូវចំពោះការអនុវត្តន៍ និងការបន្តអនុវត្តន៍
- អ្នកផ្ដល់ពតិមានសំរាប់ធ្វើការវាយតម្លៃលទ្ធផល និង ឥទ្ធិពលទទួលបានដោយផ្ទាល់ (អ្នកផ្ដល់ពតិមានសំរាប់ធ្វើកិច្ចអភិវឌ្ឍន៍)
- ប្រភពថវិកា និងកម្លាំងមនុស្សដែលគេត្រូវការ
- តារាងពេលវេលាធ្វើសកម្មភាព និងប្រាក់ចំណាយដែលគេត្រូវការ
- ការធ្វើវិភាគលើការសិក្សាអនុវត្តន៍ជាក់ស្ដែង និង ផលទទួលបានមកពីការចំណាយតាមដែលគេត្រូវការ ។

### ៦.២.១—ការអភិវឌ្ឍន៍សហគមន៍

ទោះបីជាមិនមានការច្បាស់លាស់ដល់ផ្នែករបស់ខ្លួនយ៉ាងណាក៏ដោយ ក៏ការអភិវឌ្ឍន៍សហគមន៍ (**CD** ) មានសារៈសំខាន់បំផុតដល់ការសំរេចជោគជ័យនៃកម្មវិធីជារួមដែរ ព្រោះវាធ្វើអភិវឌ្ឍន៍អង្គការចាត់តាំងតាមមូលដ្ឋាន ជំរុញកិច្ចអភិវឌ្ឍន៍រយៈពេលវែង និងដើរតួនាទីភ្ជាប់រវាងកម្មវិធី និងផ្នែកទាំងអស់របស់អង្គការ **CARERET** ។ អង្គការនេះក៏មានតម្រូវការមួយដែរ គឺ :

១) បង្កើត និងពង្រឹងទំនាក់ទំនងជាមួយអង្គការឯទៀតៗ និងជាពិសេសជាមួយរដ្ឋាភិបាល
២) បង្កើតការបញ្ជាក់បង្ហាញអោយឃើញប្រសិទ្ធភាព ដែលអ្នកដទៃអាចមានបំណងធ្វើតាម
៣) ផ្សព្វផ្សាយពីជោគជ័យរបស់សហគមន៍ និងអង្គការដែលបានទទួលជំនួយឧបត្ថម្ភ និង
៤) ជំរុញ និងបង្កលក្ខណៈអោយបាននូវការចូលរួមយ៉ាងពេញបន្ទុកអំពីនារីក្នុងដំណើរការអភិវឌ្ឍន៍ ។

ការអភិវឌ្ឍន៍សហគមន៍នឹងជួយដល់យន្តការ និងមធ្យោបាយដើម្បីឆ្លើយតបនឹងតម្រូវការការទាំងឡាយ ។

ទិសដៅចម្បង ។

វិធីដំណើរការអភិវឌ្ឍន៍សហគមន៍ ត្រូវគេបង្កើតឡើងដើម្បី :

- បង្កើនសមត្ថភាពអង្គការសហគមន៍តាមមូលដ្ឋានដើម្បីតែលំអកការិតជីវភាពរស់នៅ និងផ្តល់នូវឱកាសធ្វើការអភិវឌ្ឍន៍ខាងស្មារតី និង សំភារៈសំរាប់ក្រុមជាមុខសញ្ញា
- ជួយដល់អង្គការសហគមន៍តំបន់ក្នុងការចាតតាំងធ្វើសកម្មភាពដើម្បីដោះស្រាយបញ្ហាទាំងឡាយរបស់គេ និងលើកទឹកចិត្តដល់ការកើនឡើងនៃបណ្តាញតាមមូលដ្ឋានចំពោះការអភិវឌ្ឍន៍ដែលមានមិនដាច់ ។

ក្នុងកម្មវិធីសាស្ត្រប្រចាំតំបន់ទាំងមូលរបស់ខ្លួននេះ អង្គការ **CARERE** និងប្រើប្រាស់វិធីសាស្ត្រអភិវឌ្ឍន៍សហគមន៍ដើម្បីជំរុញដំណើរការអភិវឌ្ឍន៍ ដោយមានការចូលរួមសស្រាក់សស្រាំទាំងប្រុសទាំងស្រី និងដោយផ្អែកលើមូលដ្ឋានសហគមន៍ ។ អ្នកបំរើការដល់កិច្ចអភិវឌ្ឍន៍សហគមន៍ ដោយបានទទួលការអប់រំហ្វឹកហ្វឺនសមស្រប ហើយស្ថិតក្រោមឱវាទរបស់កម្មវិធីអភិវឌ្ឍន៍នេះ នឹងទៅជាកត្តាសំខាន់ដើម្បីដឹកនាំការពិនិត្យ ស្វែងយល់ជារួមពីសហគមន៍ ហើយជំរុញ និងតាមដានសកម្មភាពរបស់អង្គការ **CARERE** ។ ក្នុងករណីពិសេស អ្នកធ្វើការងារនៅការិតភូមិ ទោះបីជាកំពុងមានការងារ ឬក៏កំពុងជាប់កិច្ចសន្យា ក៏នឹងជួយដល់ការរក្សាទំនាក់ទំនងជាមួយភូមិ ដើម្បីជួយដល់ ដូចជា :

- ការរៀបចំផែនការធ្វើអភិវឌ្ឍន៍ដោយមានសហគមន៍ជាមូលដ្ឋាន
- ដំណើរការអនុវត្តសកម្មភាពរួមគ្នា
- សកម្មភាពនានាជាមធ្យោបាយបង្កើតស្មារតីយល់ដឹងចូលរួមពីសំណាក់ប្រជាពលរដ្ឋ
- ការកសាងសមត្ថកិច្ច ស្មេរភាព និង
- ការវាយតម្លៃទៅលើការចូលរួម

សកម្មភាព

សកម្មភាពអភិវឌ្ឍន៍សហគមន៍ទាំងឡាយរបស់អង្គការ **CARERE** នឹងមានដូចជា :

- ការហ្វឹកហ្វឺនដល់បុគ្គលិកអភិវឌ្ឍន៍សហគមន៍ អ្នកដឹកនាំសហគមន៍ និងអ្នកចូលរួមជាដៃគូ
- ការពង្រឹងការយល់ដឹងពីសហគមន៍ មុខជំនាញ និង ចំណេះដឹងផ្នែកបច្ចេកទេស ដើម្បីបង្កើតទស្សនៈយល់ដឹងធ្វើអភិវឌ្ឍន៍ និងរៀបចំយុទ្ធសាស្ត្រថ្មី របៀបថ្មី និងវិធីសាស្ត្រថ្មីដែលជាតម្រូវការដល់ការអភីវឌ្ឍន៍សហគមន៍
- ការបង្កើនការិតយល់ដឹងពីសមត្ថភាពរបស់ពលរដ្ឋដើម្បីរួមចំណែក និង ជួយគ្នាទៅវិញទៅមក
- បំរើការដល់គ្រួសារដែលគ្មាននរណាម្នាក់ថែរក្សាកូនចៅរបស់គេក្នុងម៉ោងធ្វើការ
- ពង្រីកការយល់ដឹងអំពីសិទ្ធិរបស់ស្ត្រី និងជំរុញអោយមានការចូលរួមពីស្ត្រីក្នុងគ្រប់ទិដ្ឋភាពជីវភាពរបស់សហគមន៍

- ពង្រីកការចូលរួមរបស់ស្ត្រីក្នុងការអភិវឌ្ឍន៍សហគមន៍ និង ដំណោះស្រាយបញ្ហាតាមសហគមន៍ ។

ដោយគ្មានការកំណត់ដល់លក្ខណៈទូទៅនៃការដែលបានថ្លែងមកហើយនេះ សកម្មភាពរបស់ការអភិវឌ្ឍន៍សហគមន៍ (CD) ក៏និងជួយគាំទ្រ ឬក៏បំពេញបន្ថែមផងដែរដល់សកម្មភាពអោយខ្ចីប្រាក់ សុខភាព និងកសិកម្មរបស់អង្គការ **CARERE** ដើម្បី :

- បង្កើនប្រាក់ចំណូលក្នុងគ្រួសារ និងការសន្សំប្រាក់ក្នុងសហគមន៍
- បង្កើនកំលាំង និងគំនិតអភិវឌ្ឍន៍របស់កុមារតាមរយៈការចូលរួមពីសហគមន៍
- ជួយជ្រោមជ្រែងគាំទ្រសកម្មភាពក្នុងសាលា ដើម្បីជាផលដល់ក្មេងៗ ទាំងនៅក្នុង និងក្រៅសាលា
- ជំរុញអោយម្តាយ និង សហគមន៍លើកកំពស់ការិតអនាម័យក្នុងគ្រួសារ និងសុខភាពរបស់ស្ត្រី និងកុមារ
- បន្ថយស្ថានភាពជំពាក់បំណុលក្នុងការខ្ចីលុយកាក់សំរាប់ស្រូវអង្ករហូបចុក
- ចាតតាំងអោយមានថវិកាតាមសហគមន៍ ដើម្បីផ្តល់នូវស្រូវ អង្ករ និងដើមទុនដែលគេត្រូវការ
- ជួយដល់គ្រួសារក្រីក្រអោយបង្កើនបានប្រាក់សន្សំ ដើម្បីទិញបាននូវសត្វពាហនៈសំរាប់ធ្វើការងារស្រែចំការ
- បង្កើតអោយមានហិបប្រាក់សន្សំក្នុងសហគមន៍ និង ពន្យល់ប្រជាពលរដ្ឋអោយគេស្វែងយល់ច្បាស់ ហើសសុខចិត្តចូលរួម និងជួយគ្នាទៅវិញទៅមក
- ជំរុញសហគមន៍ទាំងឡាយអោយកែលំអឡើងដល់ស្ថានភាពអនាម័យ និងទឹក
- បន្ថយមរណភាពរបស់កុមារបណ្តាលមកពីរោគកើតមកពីទឹក
- ជំរុញកាលបណ្តុះដាំកូនឈើអោយបានល្អក្នុងសហគមន៍ និងបន្ថយការចំណាយទាំងឡាយរបស់កសិករទៅលើពូជកូនឈើពីក្រៅសហគមន៍ ។

### ៦.២.២–ផលិតកម្មកសិកម្ម / ប្រាក់ចំណូល និង ការងារ

កិច្ចខំប្រឹងប្រែងនៃកម្មវិធីក្នុងវិស័យស្តារសេដ្ឋកិច្ច ឡើងវិញ គួរតែមានទិសដៅឆ្ពោះទៅ :

- សំរេចអោយបានការិតនៃផលិតកម្មក្នុងកាលកន្លងមកជាប្រវត្តិសាស្ត្រក្នុងវិស័យកសិកម្ម
- បង្កើនប្រាក់ចំណូលតាមជនបទ តាមរយៈគំរោងប្រែក្លាយកសិកម្មអោយបានទំនើបប្លែកៗគ្នា , និង
- ជួយជ្រោមជ្រែងប្រភពការងារត្រៀមបំរុងដែលនៅមានក្រៅ ។

ផ្នែកទាំងអស់នេះត្រូវតែរៀបចំអោយមានមុខព្រួញយ៉ាងនេះដើម្បីអោយសកម្មភាពសេដ្ឋកិច្ចអាចបង្កើតបានការងារនិងប្រាក់ចំណូល ព្រមទាំងអាចផ្តល់នូវផលប្រយោជន៍ច្រើនយ៉ាងថែមទៀត ។ ដូច្នេះ ថ្លៃដើមទាំងអស់ត្រូវតែគំរពឹងថាមានជាជំនួយបច្ចេកទេស , ការហ្វឹកហ្វឺន , ប្រាក់កាស ឬ ការអោយ

ខ្ទីប្រាក់ , ហើយសកម្មភាពទាំងឡាយនេះ ត្រូវបានមានលក្ខណៈប្រកបដោយសមត្ថភាពដែលត្រូវរំពឹងទុកជាមុន ដើម្បីផ្តួចផ្តើមអោយមានរបៀបដំណើរការមួយរីកចំរើនឡើងក្នុងវិស័យអន្តរាគមន៍ ។

ជាបន្ថែម អង្គការ **CARERE** នឹងប្រើប្រាស់ផ្នែកនេះ ដើម្បីជួយដល់កម្មវិធីសំរាប់បំពេញបន្ថែមដើម្បីការពារបរិស្ថាន ។ អាទិភាពមួយទៀតគឺ ជួយរដ្ឋាភិបាលក្នុងការបំភ្លឺនូវបញ្ហាសិទ្ធិទទួលដីធ្លី ហើយអង្គការ **CARERE** និងធ្វើកំណត់ត្រួនាទីគាំទ្រមួយសមស្របនៅទីនោះ ។

មុខព្រួញចំបង :

- សេដ្ឋកិច្ចសំរាប់ទ្រទ្រង់ខ្លួន
- ការស្តារឡើងវិញ និងការអភិវឌ្ឍន៍កសិកម្ម (របបទឹកភ្លៀង និងការបញ្ចូលទឹក)
- ការចិញ្ចឹមសត្វ
- ការហ្វឹកហ្វឺន និងគ្រឿងលើកទឹកចិត្តសំរាប់ការបង្កើតការងារក្នុងសកម្មភាពតាមផ្នែករួមផ្សំ
- ការហ្វឹកហ្វឺន និងជំនួយបច្ចេកទេសក្នុងវិស័យកសិកម្ម និងការចិញ្ចឹមសត្វ និង
- ការហ្វឹកហ្វឺន និង ជំនួយបច្ចេកទេសក្នុងវិស័យរដ្ឋបាល និង ចាត់ចែងរកទីផ្សារលក់ដូរ ។

សកម្មភាព

គំរោងការផលិតកម្មទាំងឡាយនឹងត្រូវផ្អែកលើបណ្តាការងារទាំងឡាយ ដែលមានអាទិភាពអាចសំរេចបានតាមផ្លូវសេដ្ឋកិច្ច ដែលគេសំគាល់ឃើញមាននៅតាមវិស័យការងារដែលជាវិស័យ អន្តរ–រាគមន៍របស់កម្មវិធីនេះ ។ នោះគឺ ÷

* ការផ្តល់នូវចំណេះដឹង និង បណ្តុះបណ្តាលអោយមានជំនាញបច្ចេកទេសក្នុងវិស័យកសិកម្មដល់បណ្តាអ្នកទទួលផលប្រយោជន៍ពីកម្មវិធី អ្នកអនុវត្តកម្មវិធីតាមមូលដ្ឋាន និងសមភាគីរដ្ឋាភិបាលនានា ។
* ការបង្កើនចំណេះដឹងនិងជំនាញបច្ចេកទេស ដើម្បីផ្តល់លទ្ធភាពដល់អ្នកធ្វើការទាំងឡាយក្នុងក៏រិតក្រសួងអោយមានគំនិតយល់ដឹង ពង្រីក និងចម្លងតាមយុទ្ធសាស្រ្តនានា របៀបអនុវត្តនិងវិធីសាស្រ្តផ្សេងៗសំរាប់កសិកម្មដែលអាចផ្តល់ជោគជ័យបាន ។
* ការភ្ជាប់ទំនាក់ទំនងលើការស្រាវជ្រាវខាងកសិកម្មក្នុងស្រុក ទៅនឹងការស្រាវជ្រាវកសិកម្មក្នុងពិភពលោកទាំងមូល ដោយបង្កើតឡើងនូវមជ្ឈមណ្ឌលកសិកម្មនានាសំរាប់ធ្វើការពិសោធន៍ និងបង្ហាញបច្ចេកទេសនានាដែលបានសំរបសំរួលរួចហើយ ។
* ការដឹកនាំធ្វើការសិក្សាស្រាវជ្រាវសេដ្ឋកិច្ចសង្គមនៅក្នុងតំបន់ ហើយនិងកំណត់ ព្រមទាំងបង្កើតនូវប្រព័ន្ធគំរូនានាដែលពាក់ព័ន្ធសំរាប់កសិកម្ម ។
* ការជួយសដល់អង្គការប្រតិបត្តិនៅតាមខេត្តនានា ដោយផ្តល់ជូននូវឧបករណ៍ និង សំភារៈ និងកិច្ចពិនិត្យតាមដានកម្មវិធី ។

* ការជួយគាំទ្រដល់ការជាវទិញនូវប្រភពធនធានសំរាប់ផលិតកម្ម ដោយរួមគ្នាជាមួយអង្គការ **CARERE** និង កម្មវិធីឥណទានដទៃៗទៀត ។
* ការអោយដាក់កុង និងអោយខ្ចីជាសេវាកម្ម ឬទំនិញតាមរយៈមជ្ឈមណ្ឌលចិញ្ចឹមគោទុក (ធនាគារគោ) ឃ្លាំងស្រូវ (ធនាគារស្រូវ) និងអ្វីៗដែលស្រដៀងគ្នានេះដោយរួមជាមួយនិងកម្មវិធីអភិវឌ្ឍន៍សហគមន៍នានា ។
* ការចែកចាយទឹក (ការសិក្សាផ្នែកបច្ចេកទេស ការស្តារប្រឡាយ និងប្រព័ន្ធផ្គត់ផ្គង់ទឹកដែលមានស្រាប់ ) រហូតដល់ ១.០០០ ហិកតា សំរាប់ផលិតកម្មស្រូវ ។
* ការគាំទ្រដល់កសិករ ដោយផ្គត់ផ្គង់អោយនូវឧបករណ៍តាមរយៈឥណទានសំរាប់ទីជនបទ ។
* ការបង្កើតឡើងនូវក្រុមមួយសំរាប់កែលំអគុណភាពដី និង រៀបចំសំរាប់ដំណាំស្រូវ ។
* លើកកំពស់ការថែទាំសុខភាពសត្វពាហនៈ រួមមានការចាក់ថ្នាំការពារ និងការទំលាក់ព្រូន ។
* ការប្រយុទ្ធទប់ទល់នឹងការច្រោះដី និងកិច្ចការពារបរិស្ថានតាមរយៈនៃការគ្រប់គ្រងដីធ្លី។
* ការបង្កើតតំបន់ស្រទះៗក្នុងព្រៃ ដើម្បីការពារកុំអោយមានការរាលដាលនៃការឆេះព្រៃឈើ និងបង្កើតតំបន់នានាដែលមានការបែងចែកទៅតាមចំណាត់ថ្នាក់ ។
* ការកសាងទំនប់ការពារដីក្នុងតំបន់ដីត្រូវច្រោះខ្វូច ។
* ការបង្កើននូវតំបន់សំរាប់រក្សាការពារត្រី ។
* ការបង្កើតកន្លែងបណ្តុះកូនឈើ និង រុក្ខជាតិ ។
* ការបង្ហាត់ហ្វឹកហ្វឺន និង ផ្តល់កិច្ចអភិវឌ្ឍន៍ដល់កសិករ និងកម្មករខាងការងារកសិកម្មក្នុងវិស័យបច្ចេកវិជ្ជាដាំដុះដែលបានកែលំអថ្មីៗ ។
* ការផ្តល់អោយនូវឱកាសដើម្បីប្រើប្រាស់ឧបករណ៍សមស្រប គ្រាប់ពូជ និងជីផ្សេងៗ ។
* ការស្ថាបនាឡើងវិញនូវទំនប់ទឹក និង ប្រព័ន្ធចែកចាយទឹក ។
* ការជំរុញលើកទឹកចិត្តដល់ការចិញ្ចឹមសត្វក្នុងទ្រង់ទ្រាយតូចសំរាប់ស្ត្រី និងគ្រួសារក្រីក្រ (ជ្រូក មាន់ ទា ) ។
* ការពង្រីកកិច្ចការដាំដំណាំហូបផ្លែ ដោយបង្កើតមជ្ឈមណ្ឌលសំរាប់ដាំដំណាំហូបផ្លែអមដោយកម្មវិធីបណ្តុះបណ្តាលផង ។
* ការជួយជ្រោមជ្រែងដល់ការងារចិញ្ចឹមត្រី និងកម្មវិធីហ្វឹកហ្វឺនដែលតម្រូវសំរាប់ទាំងអ្នកភូមិ ទាំងអ្នកបង្ហាត់បង្រៀន ។
* ការជួយជំរុញលើកទឹកចិត្តដល់ការផលិតសូត្រ ។
* ការពង្រីកកិច្ចការដាំដុះដំណាំសំរាប់បង្កើតសូត្រ និង
* ការពង្រីកការដាំដុះផ្សិត

* ការកំណត់ប្រាក់ចំណូលដែលរកបានដោយមិនផ្អែកលើវិស័យការងារកសិកម្ម និង ការកំណត់បញ្ជាក់ពីសកម្មភាពនានាដែលបង្កើតអោយមានការធ្វើ ព្រមទាំងការបង្កើតអោយមានការច្រើនបែបយ៉ាងសំរាប់ធ្វើនៅតាមទីជនបទ ដោយផ្តល់អោយនូវការបង្ហាត់ហ្វឹកហ្វឺន ។ វិស័យការងារទាំងឡាយដែលទាក់ទងដល់កសិកម្មនឹងត្រូវទទួលបាននូវអាទិភាពមុនគេ ។
* ដោយអាស្រ័យលើលក្ខណៈនៃផលិតកម្មក្នុងវិស័យការងារអន្តរាគមន៍និមួយៗ កម្មវិធីនេះត្រូវធ្វើការពិចារណាសំរាប់រយៈពេលមធ្យម និងរយៈពេលយូរ ចំពោះការផ្តើមចេញ ឬ ការស្តាបនាឡើងវិញនូវបច្ចេកវិជ្ជាកែច្នៃទុកយូរនូវចំណីអាហារដែលត្រូវសិរិតសំរាំងទុក និងការលក់បញ្ចេញតាមទីផ្សារ ដើម្បីបញ្ចូលគ្នាជាធ្លុងមួយនូវសេដ្ឋកិច្ចនិមួយៗ សេដ្ឋកិច្ចក្នុងតំបន់តូចតាច និង សេដ្ឋកិច្ចជាតិទាំងមូល ។

**៦.២.៣–ឥណទាន**

ឥណទានចាំបាច់ត្រូវក្លាយជាឧបករណ៍សំខាន់នៃយុទ្ធសាស្រ្តផលិតកម្ម ក្សនកម្ម និងយុទ្ធសាស្រ្តផ្អែកប្រាក់ចំណូល និងផ្តល់ការងារធ្វើ ។ ឥណទាននឹងទៅជាឧបករណ៍មួយយ៉ាងសំខាន់ក្នុងការផ្តល់មកនូវលទ្ធភាពខាងសេដ្ឋកិច្ចចំពោះសហគមន៍ខ្វះប្រាក់នានា ហើយកម្មវិធីនេះត្រូវបង្កើតឡើងនូវលក្ខណៈវិនិច្ឆ័យច្បាស់លាស់ និងមានប្រសិទ្ធភាពសំរាប់គ្រប់គ្រងរបស់ខ្លួន ដើម្បីអោយផលិតកម្មនិងគោលដៅស្វែងរកប្រាក់ចំណូលរបស់ខ្លួននោះសំរេចបានដោយមិនបាច់បង្កើតអោយមាន ឬ បន្ថែមការពឹងពាក់នៅតាមមូលដ្ឋាន ។ ចំពោះការសំរបសំរួលទាំងបីកំរិតរបស់អង្គការ **CARERE** កម្មវិធីនេះត្រូវអោយប្រាកដថាឥណទាននេះផ្ទាល់មិនត្រូវគេចាត់ទុកថាជាយុទ្ធសាស្រ្តមួយនោះទេ ប៉ុន្តែវាជាឧបករណ៍មួយសំរាប់សំរេចគោលដៅរបស់កម្មវិធីមក្នុងកិច្ចការស្តារឡើងវិញ និងអភិវឌ្ឍន៍ ។ **CARERE** ក៏ចាំបាច់ត្រូវធ្វើការយ៉ាងជិតស្និទ្ធ និងផ្លាស់ប្តូរពត៌មានទៅវិញទៅមកជាមួយកម្មវិធីឥណទានដទៃផ្សេងទៀតផងដែរ ដូចជាជាមួយអង្គការ **GERT , Concern** និងកម្មវិធី **ILO/LEDA** ជាដើម ។

ដើម្បីអោយអនុវត្តទៅបាន កម្មវិធីនេះត្រូវធានាថា ឥណទានអាចសងវិញបាន ។ ផែនការឥណទានជនបទផ្សេងៗត្រូវតែកំណត់អោយបានស្របទៅតាមប្រភេទអតិថិជនផ្សេងៗ ។ ការចាត់តាំងអង្គការ ការបង្ហាត់ហ្វឹកហ្វឺន ការជួយឧបត្ថម្ភខាងបច្ចេកទេស និងការជួយគាំទ្រខាងផ្នែកហេដ្ឋារចនាសម្ព័ន្ធដែលត្រូវការជាចាំបាច់ទាំងនោះ ជានិច្ចជាកាលត្រូវតែភ្ជាប់អោយមានទំនាក់ទំនងគ្នាមុនពេល និងក្នុងកំឡុងពេលធ្វើប្រតិបត្តិការឥណទាន ។ ទំរង់បែបបទ និងបរិមាណឥណទានត្រូវតែភ្ជាប់អោយមានការពាក់ព័ន្ធគ្នាយ៉ាងច្បាស់លាស់ទៅនឹងអត្រាកំណើនដែលស្តែងចេញតាមរយៈផលិតកម្ម និងប្រាក់ចំណូល ។

ដោយសារតែកម្មវិធីនេះនិងត្រូវចាប់ផ្តើមដំណើរការក្នុងស្ថានការណ៍មួយដែលគ្មានប្រព័ន្ធធនាគារជាផ្លូវការណាមួយបានចាប់ដំណើរការនៅឡើយនោះ ដូច្នេះគេត្រូវយល់ថា សកម្មភាពឥណទានភាគច្រើននឹងប្រើប្រាស់យន្តការក្រៅផ្លូវការ ។ ហេតុនេះហើយ លក្ខខ័ណ្ឌជាមូលដ្ឋានមួយសំរាប់ធ្វើអោយ

ផែនការឥណទានទាំងឡាយអាចសំរេចទៅបានក្នុងវិស័យសកម្មភាពនៃកម្មវិធីនេះ គឺតម្រូវអោយមានសេចក្តីប្តេជ្ញាចិត្ត និងការចូលរួមចំណែកពីមជ្ឈដ្ឋានសហគមន៍ ។

នៅឯកំរិតមូលដ្ឋាន កម្មវិធីនេះត្រូវធ្វើអោយប្រាកដថា ការរៀបចំអង្គការសហគមន៍ ការជឿទុកចិត្ត ការយល់គ្នាទៅវិញទៅមក ត្រូវបានគេបង្កើតឡើងមុនពេលចាប់ផ្តើមប្រតិបត្តិការឥណទានណាមួយ ។ ចំណុចនេះគឺត្រូវរួមបញ្ចូលទាំងការយល់ដឹងយ៉ាងពេញលេញអំពីគោលដការណ៍អនុវត្តដែលធ្លាប់មានពីមុនមកសំរាប់បញ្ហាឥណទាន និងយន្តការដទៃទៀតដែលមាននៅក្នុងសហគមន៍ ។ គេត្រូវចងក្រងជាសំណើច្បាស់លាស់នានា ស្តីពីថាតើត្រូវប្រើប្រាស់ និងត្រូវកែសំរួលយន្តការទាំងនោះតាមបែបណា ។ គណៈកម្មាធិការឥណទានមួយ (ថ្នាក់ដឹកនាំសហគមន៍ពាណិជ្ជករមូលដ្ឋាន អ្នកទទួលឥណទានទាំងឡាយដែលបានចាត់ចែងជាក្រុមៗ និងអ្នកឯកទេសខាងឥណទានរបស់អង្គការ **CARERE** ) គួរត្រូវបង្កើតឡើងជាផ្លូវការ ។ កម្មវិធីនេះត្រូវផ្តល់នូវការតាមដានអោយបានជាប់លាប់ទៀងទាត់មិនផ្លាស់ប្តូរ (ការបង្ហាត់ហ្វឹកហ្វឺន ជំនួយបច្ចេកទេស ការគ្រប់គ្រង ) ។

<u>ធនាគារសំរាប់ផ្តល់ប្រភពឥណទាន</u>

វិស័យអន្តរាគមន៍នេះ ទាក់ទិនទៅនឹងការផ្គត់ផ្គង់ប្រភពធនធានសំរាប់ផលិតកម្មទៅអោយអង្គការនានា ក្នុងចំណោមសហគមន៍ទទួលឥណទានទាំងឡាយ ដោយឆ្លងសហគមផលិតករ និងសមាគមការងារទីផ្សារនានា ។ល។ ធនាគារផ្តល់ប្រភពធនធាន មានគោលបំណងរួមវិភាគទានដល់ដំណើរការធ្វើអោយមានចំណីអាហារគ្រប់គ្រាន់ដោយប្រជាពលរដ្ឋខ្លួនឯង ដែលជាមុខសញ្ញានៅក្នុងដំណាក់ការដំបូង ព្រមទាំងមានបំណងជួយបង្កើតអោយមានចំណីអាហារលើសពីសេចក្តីត្រូវការ ដែលធ្វើអោយមានលទ្ធភាពដល់ការចាប់ផ្តើមអនុវត្តការសន្សំ និងវិនិយោគដទៃៗទៀត ។ កម្មវិធីនេះនឹងជួយដល់សហគមន៍អ្នកខ្ចីប្រាក់អោយរៀបចំខ្លួនឯង និងកែលំអអង្គការរបស់ខ្លួន ហើយនិងជួបពួកគេក្នុងការរៀបចំចាត់ចែងធនាគារផ្តល់ប្រភពធនធានក្នុងដំណាក់កាលដំបូង ។

–<u>មូលនិធិបង្វិល</u> : នេះទាក់ទងដល់ការជួយគាំទ្រខាងបច្ចេកទេស និងហិញ្ញវត្ថុដើម្បីបង្កើតអោយមានមូលនិធិអភិវឌ្ឍន៍ភូមិដ្ឋាន មូលនិធិអភិវឌ្ឍន៍កសិកម្ម ផែនការឥណទានរកស៊ីតូចតាច និងយន្តការអោយខ្ចីប្រាក់សំរាប់ការងារសាធារណៈនៅក្នុងសមាគមនានា ។ មូលនិធិទាំងនេះនឹងត្រូវប្រើសំរាប់ផ្តល់ប្រាក់ដល់សកម្មភាពផលិតកម្មទាំងក្នុង និងក្រៅក្របខ័ណ្ឌប្រពៃណី ព្រមទាំងផ្តល់ប្រាក់ដល់ការដួញដូរ និងសេវាកម្មផ្សេងៗ ក៏ដូចជាជួយបំរើដល់សិក្ខាការដែលបានសិក្សាចប់វគ្គហ្វឹកហ្វឺនបណ្តុះការប៉ិនប្រសប់ដែលទ្រទ្រង់ដោយអង្គការ **CARERE** ។ គោលដៅទីមួយរបស់ប្រតិបត្តិការនេះ គឺត្រូវធ្វើអោយប្រាកដថា អង្គការដែលខ្ចីប្រាក់ទាំងឡាយមានប្រព័ន្ធឥណទានដែលអាចបត់បែនផ្លាស់ប្តូរបាន និងអាចឆ្លើយតបទៅនឹងតម្រូវការផ្សេងៗតាមកាលវេលាត្រឹមត្រូវ ដើម្បីបំរើជាបឋមដល់ក្រុមជន ឬអ្នកទាំងឡាយនៅក្នុងតំបន់គោលដៅដែលមានលទ្ធភាពតិចតួច ឬ គ្មានលទ្ធភាពចូលរួមក្នុងយន្តការឥណទានផ្សេងៗដែលមានស្រាប់ ។ មូលនិធិបង្វិលអាចធ្វើអោយមានការរួមវិភាគទានយ៉ាងសំខាន់ដល់ការពង្រឹងសេដ្ឋកិច្ចគ្រួសារ និងជួយផ្តល់លទ្ធភាពអោយសហគមន៍ចាប់ផ្តើមការប្រមូលបង្កើនមូលនិធិផ្ទៃក្នុង ។

### ៦.២.៤—សុខភាព

គោលដៅសំខាន់នៅក្នុងផ្នែកនេះ គឺការថែទាំសុខភាពជាមូលដ្ឋាន និងយន្តការផ្តល់កិច្ចថែទាំសុខភាពបន្ទាប់បន្សំ ។ នេះអាចរួមបញ្ចូលទាំងការរៀបចំឡើងវិញ និងការកំណត់កម្មវិធីឡើងវិញសំរាប់បណ្តាញសេវាកម្មសុខភាពនៅតាមមូលដ្ឋាន ។ កិច្ចធ្វើអន្តរាគមន៍នានាក្នុងផ្នែកនេះមានតួនាទី និងឥទ្ធិពលមួយយ៉ាងសំខាន់ក្នុងការគាំទ្រដល់ដំណើរការអភិវឌ្ឍន៍ដោយផ្តល់នូវសេវាកម្មជាមូលដ្ឋាន និងជំរុញអោយមានការធ្វើវិនិយោគទុននៅផ្នែកដទៃផ្សេងទៀតដែលពាក់ព័ន្ធ និងមានការស្វែងរកទំនាក់ទំនងជាមួយទីភ្នាក់ងារឯកទេសទាំងឡាយរបស់អង្គការសហប្រជាជាតិដែលទាក់ទិនក្នុងអង្គការនេះ ។

គោលដៅសំខាន់ៗ

- ការអភិវឌ្ឍន៍សុខភាពជាមូលដ្ឋាន
- កែលំអការអប់រំសុខភាព និងការយល់ដឹងអំពីសុខភាពដែលទាក់ទងនឹងបរិដ្ឋាន
- ការកសាងសមត្ថកិច្ចកម្ពុជា

កម្មវិធីនេះនឹងរួមវិភាគទានផងដែរដល់កម្មវិធីនានាដែលឆ្លើយតបយ៉ាងបន្ទាន់ទៅនឹងមេរោគ **HIV**/ ជម្ងឺអេដ៍ ជម្ងឺគ្រុនចាញ់ របេង ជម្ងឺគ្រុនឈាម ឬជម្ងឺទាំងឡាយដែលអាចការពារបានដោយប្រើការចាក់ថ្នាំបង្ការ (**EPI**) នៅពេលដែលមានការកើនឡើងនៃសេចក្តីត្រូវការចាំបាច់នោះ ។

ភាពបាត់បង់ស្ទើរតែទាំងអស់នៃអ្នកដែលមានវិជ្ជាជីវៈជំនាញខាងសុខភាពនៅចុងទសវត្សទី៧០ បាននាំអោយមានការកើនឡើងយ៉ាងលឿននូវសកម្មភាពបង្ហាត់បង្រៀននៅទសវត្សទី ៨០ ដោយគ្មានការត្រួតពិនិត្យអោយល្អត្រឹមត្រូវអំពីគុណភាពអប់រំឡើយ ។ ជាលទ្ធផលគុណភាពនៃការថែរក្សាសុខភាពបានទទួលរងគ្រោះនៅស្ទើរតែគ្រប់កំរិតថ្នាក់ទាំងអស់ ដែលបណ្តាលមកពីការខ្វះខាតនូវអ្នកមើលខុសត្រូវជាច្រើនទៀតដែលជាប់ជាមួយនឹងស្ថានការណ៍នយោបាយ ។ អត្រាមរណៈភាពកុមារបច្ចុប្បន្នស្មើនឹង ១២៥/១០០០ កើតរស់ និងអត្រាមរណៈភាពម្តាយស្មើនឹង ៩/១០០០ កើតរស់ នោះគឺជាអត្រាមួយដ៏ខ្ពស់ណាស់បេកប្រៀបធៀបទៅនឹងប្រទេសដទៃទៀតក្នុងតំបន់ ។

ទោះជាមានកិច្ចខិតខំប្រឹងប្រែងដ៏គួរអោយកោតសរសើរជាច្រើនត្រូវបានអនុវត្តឡើងដោយអង្គការក្រៅរដ្ឋាភិបាលនានា និងអង្គការអន្តរជាតិនានា ដើម្បីជួយកែលំអដល់ការព្យាបាលជម្ងឺនៅតាមមន្ទីរពេទ្យ និងមន្ទីរពេទ្យស្រុកខ្លះៗនោះក៏ដោយ ក៏ការថែរក្សាសុខភាពតាមភូមិបានប្រែប្រួលតិចតួចណាស់ ហើយនៅសល់ការងារជាច្រើនទៀតដែលត្រូវធ្វើ ។ លើកលែងតែករណីមួយ គឺការកែលំអក្នុងការការចាកថ្នាំបង្ការនៅតំបន់ខ្លះៗ ដូចជានៅខេត្តបាត់ដំបងជាដើម ។ ទោះបីជាមានទីភ្នាក់ងារដែលមានសមត្ថភាព និងមានបំណងល្អជាច្រើនដែលកំពុងតែបំពេញការងារក្នុងវិស័យនេះយ៉ាងណាក៏ដោយ ក៏នៅមានការខ្វះខាតនូវរចនាសម្ព័ន្ធនិងមូលដ្ឋានទសំរាប់បើកស្ថាប័នជាទូទៅដើម្បីទ្រទ្រង់ដល់សកម្មភាពគំរោងការទាំងឡាយរបស់ទីភ្នាក់ងារទាំងនោះអោយ អាចគង់នៅយ៉ាងស្ថិតស្ថេរបាន ។

នៅក្នុងស្ថានការណ៍បែបនេះ កម្មវិធីនេះរិះរកអោយមានការបង្កើតឡើងវិញសេវាកម្មសុខាភិបាលមូលដ្ឋាន ដោយមានការចូលរួមពីតំណាងទាំងឡាយរបស់សហគមន៍ ពីអ្នកបច្ចេកទេសមូលដ្ឋាន

និងអង្គការមិនមែនរដ្ឋាភិបាលនានាដែលកំពុងធ្វើការក្នុងវិស័យថែរក្សាសុខភាពបឋម និងការងារផ្នែកសង្គមដទៃៗទៀត ។ អង្គការ **CARERE** និងគាំទ្រដល់ការឆ្លើយតបដែលធ្វើឡើងក្នុងភាពស្រុះស្រួលគ្នារវាងអ្នកចូលរួមផ្សេងៗក្នុងផ្នែកនេះ ចំពោះការធ្វើផែនការ ការធ្វើកម្មវិធី និងការអនុវត្តន៍ ។ សកម្មភាពនានាដែលនៅក្រោមផ្នែកនេះមាន ÷

ក–ការអភិវឌ្ឍន៍សកម្មភាព និងទីកន្លែង (មណ្ឌលសុខាភិបាលតូចៗ) ថែរក្សាសុខភាពបឋមនៅក្នុងគំរោងប្រតិបត្តិការនៃដំណើររៀបចំផែនការ និងធ្វើកម្មវិធីនៅតាមមូលដ្ឋានផ្សេងៗ ។

ខ–ការធ្វើវិភាគទានមួយដល់ប្រព័ន្ធមួយដែលទាក់ទងដល់ផ្នែកសុខាភិបាល ដោយស្ថិតនៅក្នុងយុទ្ធសាស្ត្រជំរុញការអភិវឌ្ឍន៍ជាទូទៅដល់ការងារផលិតកម្ម អប់រំ និងការពារបរិដ្ឋានរបស់ប្រជាពលរដ្ឋដែលជាមុខសញ្ញានៃកម្មវិធី ។

គ–ការអភិវឌ្ឍន៍នឹងធ្វើប្រព័ន្ធភាវូបនីយកម្មនៃការពិសោធន៍សាកល្បងក្នុងកិច្ចការរៀបចំ និងពង្រីកសេវាកម្មសុខាភិបាលនៅតាមមូលដ្ឋាន និងអនុលោមតាមលក្ខណៈទាំងឡាយដែលសង្កេតឃើញនៅតាមមូលដ្ឋាន និងអនុលោមតាមបេយ្យាលន័យ (ការប៉ាន់ស្មានទុកជាមុន) ដែលធ្វើឡើងក្នុងក៏រិតខេត្ត ។

ឃ–ការសំរបសំរួលដល់សកម្មភាពសុខាភិបាលរបស់ទីភ្នាក់ងារឯកទេស នៃអង្គការសហប្រជាជាតិ និងអង្គការក្រៅរដ្ឋាភិបាលនានានៅក្នុងតំបន់អន្តរាគមន៍ ។

សកម្មភាព

- –អប់រំដល់បុគ្គលិកផ្នែកអភិវឌ្ឍន៍សហគមន៍ក្នុងអង្គការ **CARERE** បុគ្គលិកសុខា–ភិបាលថ្នាក់ឃុំរបស់រដ្ឋាភិបាលក្នុងខេត្ត និងដៃគូអនុវត្តផ្សេងៗទៀត អំពីការថែរក្សាសុខភាពបឋមនៅក្នុងភូមិនានា ពិសេសចំពោះបញ្ហាផ្តល់ពត៌មានអំពីសុខភាពបឋម **(Primary Heslth Messages)** ការចាក់ថ្នាំបង្ការសុខភាពស្ត្រី កិច្ចការពារ និងត្រួតពិនិត្យជម្ងឺដែលអាចឆ្លងបាន ។
- –ជួយផ្តល់គ្លីនិក (កន្លែងព្យាបាលជម្ងឺ) ឧបករណ៍គ្រឿងសង្ហារឹម និងមធ្យោបាយដឹកជញ្ជូនសំរាប់បុគ្គលិក ។
- –គាំទ្រដល់ការហ្វឹកហ្វឺនបណ្តុះបណ្តាលអ្នកជំនាញក្នុងវិស័យសុខាភិបាល និងអ្នកថែរក្សាអ្នកជម្ងឺនៅក្នុងតំបន់ដែលមានភាពទន់ខ្សោយខ្លាំងមែនទែន ។ រៀបចំការអប់រំ និងការបង្ហាត់អំពីរបៀបចាត់ចែងការងារជាបន្តបន្ទាប់ដល់អ្នកមុខអ្នកការផ្នែកសុខាភិបាលថ្នាក់ខេត្តនិងស្រុក ។ ផ្តល់នូវជំនួយសំរាប់កសាងមន្ទីរពេទ្យ ឧបករណ៍គ្រឿងសង្ហារឹម និងមធ្យោបាយដឹកជញ្ជូនសំរាប់ការិយាល័យសុខាភិបាលស្រុក ហើយនិងជួយក្នុងក៏រិតតិចជាងនេះទៀតសំរាប់ការិយាល័យខេត្ត ។
- –រៀបចំអោយមានជាប្រចាំនូវការទាក់ទងគ្នាទៅវិញទៅមករវាងបុគ្គលិកឃុំ និងអ្នកត្រួតពិនិត្យប្រចាំស្រុក , ខេត្តតាមរយៈនៃការប្រជុំតំរង់ទិសដៅការងារមួយខែម្តងសំរាប់ស្រុក

និមួយៗ ។ លើកតំកើងការសំរបសំរួលជាមួយអង្គការក្រៅរដ្ឋាភិបាលនានា និង អង្គការអន្តរជាតិនានា ។

– បង្កើតអោយមានការទាក់ទងយ៉ាងជិតស្និទ្ធជាមួយក្រសួងសុខាភិបាល (ប្រជុំគណៈកម្មាធិការ **COCOM** មួយខែម្តង) និងមន្ទីរសុខាភិបាលខេត្ត (ប្រជុំគណៈកម្មាធិការ **COCOM** ខេត្តមួយខែម្តង) និងមន្ទីរសុខាភិបាលស្រុក ជាពិសេសការិយាល័យរៀបចំផែនការនិងគោលការណ៍អនុវត្តរបស់មន្ទីរទាំងនោះ ដើម្បីជំរាបពតិមាន និងប្រមាសអំពីផែនការការងាររបស់អង្គការ **CARERE** ។ បុគ្គលិកនៃក្រសួងសុខាភិបាលគួរធ្វើទស្សនកិច្ចរួមគ្នានៅការដ្ឋានគំរោងផែនការដើម្បីតាមដានមើលដំណើរការងារ ។

– លើកស្ទួយការអប់រំសុខភាពនិងការទាក់ទងគ្នាក្នុងចំណោមគំរោងការណ៍ផ្សេងៗរបស់អង្គការ **CARERE** ខាងផ្នែកសុខភាពដែលទាក់ទងដល់បរិដ្ឋាន និងលើកស្ទួយទំនាក់ទំនងជាមួយនាយកដ្ឋានសមភាគីរដ្ឋាភិបាលនៅមូលដ្ឋាន ។

– ដោយពិគ្រោះយោបល់ជាមួយក្រសួងសុខាភិបាល កំណត់ជ្រើសរើសផ្តល់អាទិភាពដល់ការអប់រំសុខភាព និងបណ្តាបញ្ហាសុខភាពផ្សេងៗ ដែលទាក់ទងនិងបរិដ្ឋាន ហើយនិងធ្វើអន្តរាគមន៍ដោយសមស្រប ។

– បង្កើតឡើងនូវកម្មវិធីបន្តជាប្រចាំមួយ ដែលផ្តល់អោយមានការអប់រំសុខភាពជាបន្តបន្ទាប់ និងការបង្ហាត់បង្រៀននៅនឹងកន្លែងធ្វើការ សំរាប់អ្នកផ្តល់ការថែរក្សាសុខភាពបច្ចុប្បន្ននៅក្នុងខេត្តទាំងឡាយ ដូចដែលបានកណត់ច្បាស់ក្នុងគោលការណ៍នយោបាយរបស់ប្រទេសជាតិ ។

– ធ្វើកិច្ចអភិវឌ្ឍន៍ឡើងវិញដល់សាលាគិលានុប្បដ្ឋាកប្រចាំតំបន់ នៅខេត្តបាត់ដំបងសំរាប់ឆ្មប និងគិលានុប្បដ្ឋាកកំរិត ២ ដូចដែលបានកំណត់ច្បាស់ក្នុងគោលការណ៍នយោបាយរបស់ប្រទេសជាតិ ។

– គាំទ្រដល់ការបង្ហាត់បង្រៀនអំពីបច្ចេកទេសជំនាញ និង/ឬផ្នែកចាត់ចែងការងារដោយស្របទៅតាមការអង្កេតឃើញក្នុងកំឡុងពេលអនុវត្តគំរោងការណ៍ ពោលគឺដូចជាអ្នកអប់រំគិលាប្បដ្ឋាកនៅសាលាបណ្តុះបណ្តាលគិលានុប្បដ្ឋាកនៅខេត្តបាត់ដំបង ឬទីប្រឹក្សាសុខាភិបាលខេត្ត ។

### ៦.២.៥–ហេដ្ឋារចនាសម្ព័ន្ធជនបទ

ផ្នែកហេដ្ឋារចនាសម្ព័ន្ធជនបទនៃកម្មវិធី ផ្តោតការយកចិត្តទុកដាក់នៅលើសក្តានុពលក្នុងកិច្ចការសំរួល និងកិច្ចការគាំទ្ររបស់ខ្លួន ដោយចាត់ទុកថាជាការបង្គ្រប់ដល់សកម្មភាពនានាដែលស្ថិតនៅក្រោមផ្នែកដទៃៗទៀត ។ ដូច្នេះ ការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធនេះមិនត្រូវចាត់ទុកថាជាគោលដៅចុងក្រោយនោះឡើយ តែផ្ទុយទៅវិញវាជាប្រភពដើម ដើម្បីជំរុញសកម្មភាពសេដ្ឋកិច្ច និង/ឬ សង្គមកិច្ចរីកចំរើនល្អគួរតលាស់ ។

គោលដៅសំខាន់ៗ

- ការបើកនិងធ្វើការកែលំអដល់ផ្លូវប្រភេទលេខ ២ និងលេខ ៣ ដើម្បីផ្តល់ឱកាសសំរាប់អ្នកផលិតនិងអតិថិជនប្រេកប្រាស់ទំនិញអោយមានលទ្ធភាពល្អប្រសើរឡើងក្នុងការធ្វើដំណើរទៅមក ទីផ្សារវត្ថុធាតុដើម និងទីផ្សារទំនិញប្រើប្រាស់ ។
- ការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធផលិតកម្ម និងហេដ្ឋារចាសម្ព័ន្ធសង្គម
- ការងារសហគមន៍មានទ្រង់ទ្រាយតូច និង
- ការផ្តល់មកអោយសាលារៀននូវហេដ្ឋារចនាសម្ព័ន្ធចាំបាច់ជាមូលដ្ឋានសំរាប់ការអនុវត្តន៍នូវដំណើរការអប់រំថ្នាក់បឋមសិក្សា ។

ដើម្បីធ្វើអោយហេដ្ឋារចនាសម្ព័ន្ធនេះអាចទៅជាកត្តាសំខាន់ជួយសំរួលដល់ការអភិវឌ្ឍន៍នៃសកម្មភាពសេដ្ឋកិច្ច និងសង្គមកិច្ចនៅក្នុងតំបន់អន្តាគមន៍របស់កម្មវិធីនេះ គំរោងការណ៍ហេដ្ឋារចនាសម្ព័ន្ធទាំងឡាយដែលត្រូវអនុវត្តនោះ និងត្រូវបង្កើតឡើងជាផ្នែកភ្ជាប់នឹងផ្នែកបង្គ្រប់នៃសកម្មភាពផ្សេងៗទៀតដែលត្រូវអនុវត្ត ។ ទន្ទឹមនឹងពលដែលគេទទួលស្គាលថា សកម្មភាពអស់ទាំងនេះមានសក្តានុពលភាពអាចបង្កើតអោយមានការងារធ្វើ នោះគេក៏ទទួលស្គាល់ផងដែរពីការកំរិតព្រំដែនរបស់វាក្នុងរឿងនេះ (ពោលគឺរយៈពេលខ្លី ឱកាសសំរាប់ការផ្លាស់ប្តូរមុខទំនិញត្រូវបានកំណត់ ។ល។) ។

អង្គការ **CARERE** នឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គការ ILO ដើម្បីអនុវត្តសំរេចកិច្ចការផ្លូវថ្នល់នានានៅក្នុងផ្នែកនេះ ដោយធ្វើការសំរបសំរួល និងតំរង់ទិសដល់ការងារនានាអោយបានរឹតតែទូលំទូលាយថែមទៀត ។

### ៦.២.៦–ទឹក និង អនាម័យ

ដោយឡែក ក្នុងផ្នែកទឹកនិងអនាម័យ (**WATSAN** ) នេះ អង្គការសហប្រជាជាតិបានពង្រីកគោលការណ៍នយោបាយអស់រយៈពេលយូរមកហើយ ហើយបទអន្តរាគមន៍របស់អង្គការ **CARE-RE** នឹងត្រូវលើកគំរោងឡើងអោយបានស្របទៅតាមគោលនយោបាយទាំងឡាយ ស្តីអំពីបរិដ្ឋាន និងសុខភាពប្រជាពលរដ្ឋ និង ស្ថាប័ន ការចាត់ចែងសហគមន៍និងហិរញ្ញវត្ថុ និងបច្ចេកទេស ។

ក្នុងចំណោមបញ្ហាចម្បងដែលកំពុងស្ថិតនៅចំពោះមុខផ្នែកនេះរួមមាន ÷ គោលនយោបាយហួសសម័យ ស្ថាប័នតាមផ្នែកមិនមានចំនួនគ្រប់គ្រាន់ ខ្វះមន្ត្រី និងបុគ្គលិកបំរើគំរោងការណ៍តាមគ្រប់ជាន់ថ្នាក់ទាំងអស់ ដែលបានទទួលការបង្ហាត់ហ្វឹកហ្វឺនការប្រើប្រាស់បច្ចេកវិជ្ជាមិនសមស្រប និងការប្រើប្រាស់នូវយន្តការហិរញ្ញវត្ថុដែលគ្មានប្រសិទ្ធភាពសំរាប់ការប្រមែប្រមូលនិធិ និងចែកចាយប្រាក់ ។

គោលដៅសំខាន់ៗ

ដោយនឹកឃើញដល់រចនាសម្ព័ន្ធ ៤ ចំណុច នៃគោលនយោបាយរបស់អង្គការសហប្រជាជាតិសំរាប់ផ្នែកនេះ កិច្ចខិតខំប្រឹងប្រែងផ្នែកទឹកនិងអនាម័យរបស់អង្គការ **CARERE** និងមានគោលដៅដូចតទៅ ÷

បរិដ្ឋាននិងសុខភាព

* បង្កើនសៀងនៃការផ្គត់ផ្គង់សេវាកម្មផ្នែកទឹកនិងអនាម័យ ចំពោះប្រជាពលរដ្ឋក្រីក្រនៅជនបទនិងជុំវិញទីក្រុង ដោយអនុវត្តកម្មវិធីសំរបសំរួលមួយ ។
* ការពារបរិដ្ឋាននិងការពារសុខភាពតាមរយៈនៃការចាត់ចែងរួមគ្នានូវប្រភពទឹក និង កាកសំណល់វត្ថុរាងនិងរឹង ។ ការចាត់ចែងប្រភពទឹកនិងអនាម័យរួមគ្នានេះរួមមានវិធានការចំរុះផ្សេងៗ ដូចជាវិធានការផ្នែកនីតិកម្ម គោលនយោបាយកំណត់តម្លៃ និងវិធានការបង្ខំអោយអនុវត្តតាមការកំណត់ ព្រមទាំងមានកិច្ចការដទៃផ្សេងទៀត ។

ប្រជាពលរដ្ឋនិងស្ថាប័ន

* លើកទឹកចិត្តនិងលើកស្ទួយការអភិវឌ្ឍន៍នៃយុទ្ធសាស្ត្រទឹកនិងអនាម័យជាតិ ។
* អនុវត្តការកែទម្រង់ស្ថាប័នដើម្បីជំរុញអោយមានការអនុវត្តន៍រួមគ្នាតាមគំរោងទឹកនិងអនាម័យ ។ ការកែទម្រង់ទាំងនេះរួមមានការផ្លាស់ប្តូរទម្រង់ការតិរិយាបថ និងអាកប្បកិរិយានានា ព្រមទាំងការរួមចំណែកយ៉ាងពេញលេញពីស្ត្រីនៅគ្រប់ជាន់ថ្នាក់នៃស្ថាប័ននានាផ្នែក (ទឹកនិងអនាម័យ) ។
* លើកទឹកចិត្តរដ្ឋាភិបាលនិងអង្គការ **CARERE** ដើម្បីខិតទៅរកតួនាទីជាអ្នកជួយលើកស្ទួយនិងអ្នកជួយសំរួលការងារជាជាងធ្វើជាអ្នកផ្គត់ផ្គង់ ។ គោលបំណងគឺធ្វើអោយឈានដល់មានភាពជាសមភាគីសហការរវាងរដ្ឋាភិបាលនិងសហគមន៍ (វាទំនងដូចជាត្រូវការរយៈពេលយូរច្រើនឆ្នាំដើម្បីឈានដល់ដំណាក់កាលនេះ ហើយនៅ ចន្លោះពេលនោះ ទីភ្នាក់ងារផ្តល់កិច្ចគាំទ្រខាងក្រៅទាំងឡាយចាំបាច់ត្រូវរក្សាទុកតួនាទីជាអ្នកផ្គតផ្គង់ថែមពីលើតួនាទីអ្នកលើកស្ទួយនិងអ្នកជួយសំរបសំរួលនោះ ។
* កសាងអោយមានសមត្ថភាពធំជាងមុនសំរាប់រៀបចំផែនការ និងអនុវត្តតាមគំរោងការទាំងឡាយដោយពង្រឹងស្ថាប័នផ្នែក (ទឹកនិងអនាម័យ) នានា និងដោយពង្រឹងប្រភពធនធានមនុស្ស ។ ការបង្ហាត់បង្រៀន រួមបញ្ចូលទាំងបញ្ហាបច្ចេកទេស និងបញ្ហាសុខភាពផង ។
* រិះរកវិធីផ្សេងទៀតដែលមិនប្រើរូបិយវត្ថុ ដើម្បីលើកស្ទួយទឹកចិត្តដល់បុគ្គលិកបំរើគំរោងការណ៍ ដោយទទួលស្គាល់នូវការពិតថា រដ្ឋាភិបាលប្រហែលជាមិនអាចប្រើប្រាស់ខែដើម្បីធ្វើជាកត្តាជំរុញទឹកចិត្តទេ ។ ការលើកទឹកចិត្តបែបនេះលលល រួមមានការបង្ហាត់បង្រៀននៅនឹងកន្លែងធ្វើការ ការអនុវត្តន៍តាមគោលនយោបាយតម្លើងឋានៈយ៉ាងសកម្មការចាត់ចែងបុគ្គលិកអោយបានត្រឹមត្រូវប្រាកដប្រជា និងជាយថាហេតុគឺការបង្កើតរចនាសម្ព័ន្ធអាជីពនានា ដែលត្រូវបានគ្រោងឡើងយ៉ាងល្អប្រណិត ។

## ហិរញ្ញវត្ថុ និង បច្ចេកវិជ្ជា

ការរឹតត្បិតជាចំណងមួយដែលមាននៅចំពោះមុខគំរោងការណ៍ទឹកនិងអនាម័យក្នុងប្រទេសកម្ពុជា គឺការខ្វះខាតទាំងនៅក្នុងរដ្ឋាភិបាល ទាំងនៅក្នុងទីភ្នាក់ងារគាំទ្រពីខាងក្រៅ ដែលមិនអាចធ្វើអោយមានការប្រើប្រាស់ដោយប្រសិទ្ធភាពនូវប្រភពធនធាននានាដែលអាចយកមកប្រើប្រាស់បាន ។

គោលបំណងទាំងឡាយគឺ ÷

* លើកស្ទួយលទ្ធភាពទ្រទ្រង់ដល់ដំណើរការការងារនៃគំរោងការណ៍ និងបង្កើនអត្ថប្រយោជន៍ដោយអនុលោមទៅតាមគោលការណ៍អនុវត្តហិរញ្ញវត្ថុនានា ដែលជួយកែលំអដល់ការចាត់ចែងភោគទ្រព្យដែលមានស្រាប់ ហើយដែលធ្វើអោយកាន់តែមានការប្រើប្រាស់យ៉ាងទូលំទូលាយថែមទៀតនូវបច្ចេវិជ្ជាសមស្រប ។
* បន្តជំរុញដល់ការកសាងសមត្ថភាព និងលទ្ធភាពទ្រទ្រង់ដំណើរការងារនៃគំរោង ដោយបង្កើតអោយមានរឹតតែទូលំទូលាយថែមទៀតនូវការអោយខ្ចីប្រាក់ក្នុងល័ក្ខខ័ណ្ឌងាយស្រួល និងការផ្តល់ជំនួយដទៃៗទៀត ។
* បង្កើតអោយបានច្បាស់លាស់នូវយុទ្ធសាស្ត្រប្រចាំផ្នែក និងផែនការនានាសំរាប់ធ្វើសកម្មភាពដែលអាចធ្វើអោយគេយកចិត្តទុកដាក់ក្នុងដំណើរការរៀបចំផែនការជាតិ ដែលលទ្ធផលនេះនឹងនាំមកនូវឱកាសសំរាប់បង្កើនថវិកាផ្គត់ផ្គង់ដល់ផ្នែក (ទឹកនិងអនាម័យ) នេះ ។

របៀបអនុវត្តការងារ

* ការបង្កើតអោយបានច្បាស់លាស់នូវផែនការប្រចាំផ្នែក និងផែនការសំរាប់ធ្វើសកម្មភាព
* ធ្វើការងារតាមរយៈស្ថាប័ន និងរចនាស្ព័ន្ធនានាដែលមានស្រាប់ ដើម្បីបង្កើតអោយមានការប្រើប្រាស់ដ៏ប្រសើរបំផុតនៃបទពិសោធន៍ចំណេះដឹងនិងការជំនាញដែលបានមកពីមូលដ្ឋាន ហើយនិងជួយបង្កអោយមានសមត្ថភាពដើម្បីជាយថាហេតុ អាចអនុវត្តទៅមុខទៀតបានដោយគ្មានជំនួយពីខាងក្រៅ ។
* រៀបចំការបង្ហាត់បង្រៀនតាមគ្រប់កំរិតថ្នាក់ ដើម្បីបង្កើនឋានៈបុគ្គលិកដែលមានស្រាប់ និងដើម្បីបណ្តុះបណ្តាលបុគ្គលិកថ្មីៗ ស្របតាមសេចក្តីត្រូវការ ។
* ពង្រឹងសមត្ថភាពប្រើប្រាស់ និងចែកចាយមូលនិធិ ហើយបន្ទាប់ពីនោះមើលខុសត្រូវលើរបៀបប្រើប្រាស់មូលនិធិនោះ ។
* ចាត់វិធានការអនុវត្តដើម្បីធ្វើអោយប្រាកដថា ទីតាំង និងឧបករណ៍សំរាប់ផ្នែកទឹកនិងអនាម័យត្រូវបានប្រើប្រាស់យ៉ាងមានប្រសិទ្ធភាព ដោយសហគមន៍អ្នកទទួលផលប្រយោជន៍នានា ។

* ពង្រឹងស្ថាប័នផ្នែកនានា និងលើកទឹកចិត្តដល់ការអភិវឌ្ឍន៍ប្រភពធនធានមនុស្ស ។ កិច្ចការបណ្តុះបណ្តាលគឺជាផ្នែកការងារចំបងហើយការចូលរួមរបស់ស្ត្រីនៅគ្រប់ជាន់ថ្នាក់ នៃដំណើរការរៀបចំផែនការនិងអនុវត្តកម្មវិធីនោះក៏ត្រូវលើកស្ទួយផងដែរ ។
* ជំរុញកិច្ចការទ្រទ្រង់កម្មវិធីនេះតាមរយៈគោលការណ៍អនុវត្តត្រឹមត្រូវខាងផ្នែកហិរញ្ញវត្ថុនិងការប្រើប្រាស់បច្ចេកទេសសមស្រប ។ ផ្នែកសំខាន់មួយគឺការបង្កើតយុទ្ធសាស្ត្រប្រចាំផ្នែកនិងផ្នែកការងារអោយបានច្បាស់លាស់ដែលធ្វើអោយគេចាប់អារម្មណ៍ឃើញថាគេត្រូវការផ្តល់ថវិកាដល់ផ្នែក (ទឹកនិងអនាម័យ) នេះ ហើយដែលអាចធ្វើជាមគ្គុទ្ទេសក៏មួយសំរាប់អនុវត្តគំរោងការណ៍ ។
* ធ្វើការអភិវឌ្ឍន៍យុទ្ធសាស្ត្រទឹកនិងអនាម័យជាតិដែលរួមមានទាំងការចាត់ចែងរួមគ្នា នូវប្រភពទឹកនិងកាកសំណល់វត្ថុរាវ និង រឹង ។
* បង្កើតនូវសមត្ថភាពតាមមូលដ្ឋានដោយធ្វើអោយមានការអោយខ្ចីប្រាក់ក្នុងល័ក្ខខ័ណ្ឌងាយស្រួល និងការផ្តល់នូវនូវជំនួយឧបត្ថម្ភផ្សេងៗ ។



រូបថត ១ : ការចិញ្ចឹមគោនៅភូមិគយមែង ឃុំឬស្សីក្រោក ស្រុកមង្គលបូរី..



រូបថត ២ : សិប្បកម្មធ្វើអង្រឹងនៅភូមិប្រលាយល្អួងក្រោម



រូបថតទី ៣ : សកម្មភាពដកស្មៅបែកក្បាលនៅភូមិប្រលាយល្វងក្រោម



រូបថតទី ៤ : សកម្មភាពបាញ់ថ្នាំសំលាប់កាជីបនៅភូមិប្រាយល្វងក្រោម



រូបថត ៥ : សកម្មភាពបង្រៀនដំណាំឈើហូបផ្លែនៅចំការដើមឈើភូមិជំទាវ




រូបថត ៦ : ការជីកអណ្តូងដៃរបស់កសិករនៅឃុំអូរស្វ័តឧបត្ថម្ភដោយអង្គការ CARERE...

# សន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

* * *

ឆ្លងតាមការសិក្សាវាយតំម្លៃពីកិច្ចអភិវឌ្ឍន៍សហគមន៍ ក្នុងខេត្តបន្ទាយមានជ័យ គិតពីថ្ងៃ ទី ០៦ ខែ កក្កដា ឆ្នាំ ១៩៩៥ ដល់ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៩៥ យើងខ្ញុំអាចធ្វើការសន្និដ្ឋានលើចំណុច មួយចំនួន ដូចខាងក្រោម ÷

ចំណុចទី ១ : ចំពោះផលិតកម្មផ្នែកដំណាំកសិករបានឈានជាជំហានៗ កែលំអឡើងវិញ នូវរបៀបដាំដុះ ដោយបញ្ចូលបច្ចេកទេសជឿនលឿនសមស្របទៅក្នុងផលិតកម្មដើម្បីលើកកំពស់ ទិន្នផល ដី , ទិន្នផលពលកម្ម និងមានលទ្ធភាពសមស្របក្នុងការប្រើប្រាស់ធនធានធម្មជាតិ ។

ចំណុចទី ២ : ចំពោះការចិញ្ចឹមសត្វ កសិករបានអនុវត្តជាបណ្តើរៗនូវការចិញ្ចឹមទៅតាម បច្ចេកទេសសមស្របដើម្បីទាញរកប្រាក់កំរៃដោះស្រាយម្ហូបអាហារ កំលាំងអូសទាញ និងជីដាក់ដំណាំ ។

ចំណុចទី ៣ : ចំពោះផ្នែកធារាសាស្ត្រ កសិករបានយល់ដឹងច្បាស់លាស់អំពីគោលបំណង និងការចូលរួមយ៉ាងសកម្មក្នុងការជួសជុលទំនប់ទឹក និងលើកផ្លូវតាមរយៈអង្ករពលកម្ម គឺមានការជួយ ឧបត្ថម្ភពីអង្គការ **World Food Progromme** ផ្តល់អង្ករដល់ប្រជាពលរដ្ឋដែលបានចូលរួមលើកផ្លូវ ។

ចំណុចទី ៤ : ចំពោះផ្នែកឥណទានកសិកម្ម កសិករភាគច្រើនមានលទ្ធភាពទទួលបាននូវ ប្រភពទុន ដើម្បីធ្វើអោយកើនឡើងនូវផលិតកម្មដំណាំស្រូវ ព្រោះអត្រាការប្រាក់ទាប ២ ភាគរយ ក្នុងមួយ ខែ ធ្វើអោយកសិករមានចំណាប់ចង់ខ្ចីដែលឧបត្ថម្ភពីអង្គការ **CARERE** សហការជាមួយមន្ទីរកសិកម្ម ខេត្ត ។

ចំណុចទី ៥ : ចំពោះកំរិតយល់ដឹងរបស់កសិករអំពីកម្មវិធីឥណទានកសិកម្ម គណៈកម្មការ អភិវឌ្ឍន៍ ក្រុមឥណទាន ក្រុមកសិករ និង គោលបំណងនៃការធ្វើអភិវឌ្ឍន៍មានកំរិតខ្ពស់បង្គួរ ។

ចំណុចទី ៦ : ចំពោះសកម្មភាពអប់រំផ្សព្វផ្សាយរបស់ក្រុមអភិវឌ្ឍន៍ បានអនុវត្តតាមរូបភាព ដែលសំខាន់គឺ ផ្សព្វផ្សាយតាមលក្ខណៈប្រមូលផ្តុំនៅតាមលំនៅដ្ឋាន , ផ្សព្វផ្សាយតាមរយៈទស្សនកិច្ច , ផ្សព្វផ្សាយតាមរយៈបុគ្គល និង បុគ្គល ។

ចំណុចទី ៧ : ចំពោះប្រព័ន្ធការងារចាត់តាំង និងគ្រប់គ្រងបានរៀបចំឡើងយ៉ាងសមស្រប ដែលអាចមានទំនាក់ទំនងទៅវិញទៅមក នូវការងារទាំងនោះ គឺការងារដាំដុះ , ការងារចិញ្ចឹមសត្វ , ការ ងារធារាសាស្ត្រ , ការងារឥណទាន , ការងារផ្លូវថ្នល់ , សាលារៀន , អណ្តូងទឹក , សុខភាពប្រជាពលរដ្ឋ ជីកស្រះ , និងអប់រំផ្សព្វផ្សាយ ។

គ្រប់សមិទ្ធផលនៃការងារ គឺបានមកពីការឧបត្ថម្ភគាំទ្រពីមន្ទីរកសិកម្មខេត្ត និងអង្គការសហប្រ ជាជាតិ **CARERE** ការរួមសហការពីអាជ្ញាធរមូលដ្ឋាន ក្រុមអភិវឌ្ឍន៍ និងជាពិសេសបំផុតគឺមានការចូល រួមរបស់ប្រជាជន ។

ការខ្វះខាត និងសំណូមពរ :

ចំណុចទី ១ : ការធ្វើអោយមានប្រសិទ្ធភាពកើតខ្ពស់នៃការជ្រាបចូលនូវបច្ចេកទេសវិទ្យាសាស្ត្រជឿនលឿន ក្នុងស្រទាប់កសិករជាការងារមួយលំបាក និងទាមទារនូវរយៈពេលមួយដ៏យូរអង្វែង ។ ដោយហេតុថា កសិករភាគច្រើនបានលង់ជ្រៅ និងមានជំនឿយ៉ាងមុតមាំតាមរបៀបបង្កបង្កើនផលបែបបុរាណ ។ ដូច្នេះដើម្បីកែប្រែនូវជំនឿ និងរបៀបរបបចាស់នេះ បានការងារនូវអប់រំផ្សព្វផ្សាយដែលមានប្រសិទ្ធភាពខ្ពស់ គឺ :

– ការបង្កើននូវការអប់រំផ្សព្វផ្សាយតាមរយៈការធ្វើបង្ហាញ តែមិនមែនបង្ហាញគ្រាន់តែបង្ហាញនោះទេ ជួគឺជាគំរូមួយដ៏ល្អ ។

–ការផ្ដល់រង្វាន់ ឬ ការសរសើរលើកទឹកចិត្តចំពោះកសិករដែលមានស្នាដៃក្នុងការបង្កើនផល ឬការងារចិញ្ចឹមសត្វដោយអនុវត្តតាមបច្ចេកទេសដែលបានណែនាំ ដោយទទួលបាននូវទិន្នផលខ្ពស់ ដើម្បីបំផុសនូវចំណង់ចំណូលចិត្តរបស់កសិករអោយកាន់តែខ្ពស់ ដើម្បីបំផុសនូវចំណង់ចំណុលចិត្តរបស់កសិករអោយកាន់តែខ្ពស់ និងបង្កើនភាពមើលឃើញនៃកសិករដទៃទៀត ។

ចំណុចទី ២ : ការខ្វះខាតក្នុងការចិញ្ចឹមសត្វពាហនៈ (គោ–ជ្រូក) និងមាន់របស់កសិករនៅមានច្រើន គឺខ្វះខាតនូវមូលដ្ឋានសំភារៈ និងបច្ចេកទេស ជាពិសេសគឺក្រោល និង ទ្រុង ។ ការលែងសត្វអោយដើររកស៊ី ដោយសេរី បណ្ដាលអោយជះឥទ្ធិពលមិនល្អដល់ផ្នែកផលិតកម្មដំណាំ ជាប្រភពនូវជម្ងឺឆ្លងផ្សេងៗ និងបង្កអោយមានជំលោះជាញឹកញាប់រវាងកសិករ និងអ្នកចិញ្ចឹមសត្វ ។

ហេតុនេះ ត្រូវមានវិធានការអោយបានសមស្រប ដើម្បីឈានជាជំហានៗឆ្ពោះទៅលើកកំពស់មុខរបរចិញ្ចឹមសត្វអោយប្រកបដោយបរិមាណ និង គុណភាពពកើតខ្ពស់ ក្រៅពីការផ្គត់ផ្គង់សាច់ចេញ ការចិញ្ចឹមសត្វនឹងផ្ដល់នូវប្រភពជីដែលផ្នែកដាំដុះត្រូវការមិនអាចខ្វះបាន បើសិននិយាយដល់ប្រពលវប្បកម្ម និងការកែលំអគណុភាពដី ។

ចំណុចទី ៣ : ដើម្បីឆ្លើយតបទៅនឹងកង្វះខាតរបស់កសិករ ក្នុងការប្រើប្រាស់ទឹកសំរាប់ការងារស្រែចំការ វិធានការសំខាន់បំផុតគឺអភិវឌ្ឍន៍ផ្នែកធារាសាស្ត្រ ។ ថ្វីត្បិតតែការងារធារាសាស្ត្របានអនុវត្តការដោះស្រាយទឹកប្រើប្រាស់ទឹកសំរាប់គ្រួសារបានមួយកើត ហើយក៏ដោយ តែបើពិនិត្យផ្នែកស្រោចស្រពក្នុងការងារបង្កបង្កើនផលស្រូវឃើញថាពុំធានាបានទាំងស្រុងនៅឡើយទេ ។ ម៉្យាងទៀតផ្នែកធារាសាស្ត្រ គួរគប្បីពិនិត្យលទ្ធភាពស្ថាបនាផងដែរនូវប្រព័ន្ធប្រឡាយបញ្ចេញទឹក ដើម្បីបន្ថយនូវភាពលើសពីសេចក្ដីត្រូវការនៃបរិមាណទឹក ។

ចំណុចទី ៤ : ក្នុងតួនាទីជាអ្នកអប់រំផ្សព្វផ្សាយសំរាប់ក្រុមអភិវឌ្ឍន៍ គួរគប្បីបង្កើន (រៀនសូត្រ) ជានិច្ចនូវកើតយល់ដឹង និងទេពកោសល្យផ្ទាល់ខ្លួន ដើម្បីយល់អោយបានស៊ីជំរៅពីបញ្ហារបស់កសិករ ពោលគឺរស់នៅជាមួយកសិកររៀនសូត្រពីគាត់ និងក្ដាប់អោយបានពីចិត្តសាស្ត្ររបស់គាត់ ដើម្បីងាយស្រួលក្នុងការជួយគាត់ក្នុងការស្វែងរកដំណោះស្រាយ ។

ចំណុចទី ៥ : ក្រើនរំលឹកអោយបានញឹកញាប់នូវគ្រប់ការអនុវត្តន៍ដែលបានធ្វើការកែប្រែហើយដល់កសិករ ដើម្បីអោយគេយល់កាន់តែច្បាស់ហើយចងចាំជានិច្ច ។

ចំណុចទី ៦ : ក្នុងតួនាទីជាអ្នកអប់រំផ្សព្វផ្សាយសំរាប់ក្រុមអភិវឌ្ឍន៍ គួរគប្បីដាច់ខាតត្រូវតែជាគំរូល្អទាំងសកម្មភាពការងារ និងការរស់នៅ ។

ចំណុចទី ៧ : ដើម្បីអោយដំណើរការអភិវឌ្ឍន៍បន្តទៅបានជានិច្ច សំរាប់ក្រុមអភិវឌ្ឍន៍គួរគប្បីធ្វើអោយកសិករខ្លះដែលនៅមិនទាន់យល់ច្បាស់អោយគេបានយល់ច្បាស់ថាគ្រប់បញ្ហាដែលបានដោះស្រាយរួចហើយ គឺជាបញ្ហាដែលកសិករទាំងអស់គ្នាបានដោះស្រាយរួចហើយគ្រប់សមិទ្ធផលដែលបានមកពីការដោះស្រាយបញ្ហា គឺជាសមិទ្ធផលរបស់កសិករទាំងអស់គ្នា ហើយគប្បីបង្ហាញអោយកសិករយល់ថាយើងនឹងមិនត្រូវការអ្វីបន្តិចឡើយ នៃសមិទ្ធផលទាំងនេះ នៅពេលដែលយើងត្រូវចាកចេញពីភូមិឋានរបស់កសិករហើយអ្វីដែលយើងត្រូវការ គឺនៅពេលដែលយើងត្រឡប់ជួបគេវិញម្តងម្កាល គឺយើងនឹងបានឃើញភាពស្រស់បំព្រងរបស់គេ និងភាពរុងរឿងនៃគ្រួសារ និងភូមិឋានរបស់គេ ។

# បណ្ណាល័យសាស្រ្ត

* * * *


១- an Evaluation of the World Bank's Expersion , International Bank , Washington , D . C , USA , 1985

២- Boyce James K , Evenson Robert E , National and International Research and Extension Programmes , Agricultural Development Council INC , 1975

៣- Brayant Coralie White Course G , Managing Rural development With Small Farmer Participation , Kumarien Press . INC , 1984

៤- Cerna Michacl M , Coulten Juhn K , Roussel John F . A , Research - Extension - Farmer , A two Way Continuum for Agricultural Development , in Ternation Bank for World Bank and UNCP Symposium , Washing D.C. 1985

៥- Document of the Strategy of Rice Seed Production , UNDP / CARERE

៦- Document of the Strategy of Credit for Vegetable Production , UNDP / CARERE

៧- របាយការណ៍កសិកម្មខេត្ត

៨- របាយការណ៍កសិកម្មស្រុកមង្គលបូរី

៩-រួមជាមួយកសិករដើម្បីអភិវឌ្ឍន៍

១០- ឯកសារយុទ្ធសាស្រ្តកម្មវិធីរយៈពេលបីឆ្នាំ ១៩៩៤ រហូតដល់ឆ្នាំ ១៩៩៦

១១- ឯកសារ ស្តីពីការបង្កើតតួនាទី និងភារកិច្ចរបស់គណៈកម្មការអភិវឌ្ឍន៍ភូមិ

ទំរង់បែបបទនៃការអង្កេត

៚

I. សមាជិកគ្រួសារ និង គំនិតយល់ឃើញនៃមេគ្រួសារ

១- ឈ្មោះមេគ្រួសារ... អាយុ... ភេទ... សូមបញ្ជាក់ផងបើមេគ្រួសារជាស្ត្រីមេម៉ាយ

២- តើសមាជិកក្នុងគ្រួសារសរុបប៉ុន្មាននាក់ ? ស្រីប៉ុន្មាន ? ប្រុសប៉ុន្មាន ?

៣- តើអ្នកមានកូនសរុបប៉ុន្មាននាក់តាំងពីមិនទាន់បែកចេញ ?

៤- តើអ្នកបានរៀនដល់ថ្នាក់ណា ?

៥- តើអ្នកអានអក្សរបានដែរឬទេនាពេលបច្ចុប្បន្ន ?

៦- តើអ្នកយល់ថាព្រៃឈើមានសារៈសំខាន់អ្វីខ្លះសំរាប់មនុស្ស ? សំរាប់អាកាសធាតុ ? សំរាប់ដី ? សំរាប់ទឹក ? សំរាប់សត្វ ?

៧- តើអ្នកយល់ថាព្រៃឈើនឹងអស់ដែរឬទេ ? ហេតុអ្វី ?

II. អំពីរបបទទួលកម្មសិទ្ធិដីធ្លី

១- តើរដ្ឋចែកដីឲ្យគ្រួសារអ្នកប៉ុន្មាន ឬ អ្នកទទួលដីពីកេរ្តិ៍មរតក ?

២- តើអ្នកសព្វថ្ងៃមានដីស្រែប៉ុន្មានហិកតា "ឬអារ" ?

៣- តើអ្នកមានដីទួល "ដីចំការ ឬ ដីព្រៃ" ប៉ុន្មានហិកតា "ឬអារ" ?

៤- តើដីភូមិរបស់អ្នកប៉ុន្មានអារ ?

៥- តើអ្នកមានបានប្រើប្រាស់ដីស្រែរបស់អ្នកអស់ឬទេជារៀងរាល់ឆ្នាំ ? បើមិនអស់ហេតុអ្វី ?

៦- តើអ្នកមានធ្វើចំការឬទេ ? បើគ្មានហេតុអ្វី ?

៧- តើដីដែលអ្នកកាន់កាប់សព្វថ្ងៃសុទ្ធតែមានលិខិតប្រគល់ដីធ្លីអស់ហើយឬនៅ ?

III. អំពីដំណាំ

១- តើអ្នកប្រើស្រូវក្នុងស្រុក ឬ ស្រូវនាំចូលសំរាប់ស្ទូងរាល់ឆ្នាំ ?

២- តើផលស្រូវជារៀងរាល់ឆ្នាំបានប៉ុន្មាន ?

៣- តើអ្នកមានធ្វើជីកំប៉ុស្តឬទេ ?

៤- តើអ្នកប្រើជីអ្វីខ្លះដាក់ស្រែ ? បរិមាណប៉ុន្មាន ? បានពីណា ? បើទិញថ្លៃប៉ុន្មាន ?

៥- តើអ្នកមានធ្វើស្រែប្រាំងឬទេ ? បើមានពូជស្រូវអ្វី ? បានប៉ុន្មានថាំង ?

៦- តើនៅឆ្នាំកន្លងទៅនេះផលស្រូវរបស់អ្នកយ៉ាងដូចម្តេចដែរ ? បើទាបជាងសព្វដង ហេតុអ្វី ?

៧- តើនៅលើដីភូមិរបស់អ្នកមានដាំប្រភេទដំណាំអ្វីខ្លះ ? បើគ្មានហេតុអ្វី ?

៨- តើអ្នកដែលបានយកផលទៅលក់ដែរឬទេ ?

៩- តើដំណាំទាំងនោះលូតលាស់យ៉ាងដូចម្តេចដែរ ? អ្នកបានពូជមកពីណាមកដាំ ?

១០- តើអ្នកចូលចិត្តដាំដំណាំអ្វីខ្លះ ?

១១- តើនៅលើដីចំការរបស់អ្នកមានដាំដំណាំអ្វីខ្លះ ?

១២. តើការលូតលាស់នៃដំណាំទាំងនោះយ៉ាងដូចម្ដេច ? ហេតុអ្វី ?
១៣. តើអ្នកមានគំរោងដាំអ្វីជាប្រចាំលើដីរបស់អ្នក ? ហេតុអ្វី ?
១៤. តើមានបញ្ហាអ្វីខ្លះលើដំណាំរបស់អ្នកក្រោយពីដាំរួច ?
១៥. តើដំណាំទាំងនេះបានផ្ដល់ផលទៅលក់ដែររឬទេ ?

## IV. អំពីការចិញ្ចឹមសត្វ

១. តើអ្នកមានគោ ក្របី ប៉ុន្មាន ? បើគ្មានហេតុអ្វី ?
២. តើអ្នកឃ្វាលគោ ក្របី ឬ លែង ? ហេតុអ្វី ?
៣. តើអ្នកឃ្វាល ឬ លែង នៅឯណា ?
៤. តើបញ្ហាស្មៅគោ ក្របី យ៉ាងណាដែរ ?
៥. តើគោ ក្របីរបស់អ្នកធ្លាប់មានជម្ងឺដែរ ឬ យ៉ាងណា ? បើមានអ្នកធ្វើដូចម្ដេច ?
៦. តើអ្នកមានចិញ្ចឹមជ្រូកដែររឬទេ ? បើគ្មានហេតុអ្វី ? បើមានប៉ុន្មានក្បាល ?
៧. តើអ្នកបានអ្វីជាចំណីជ្រូក ? បានពីណា ?
៨. តើជ្រូករបស់អ្នកធ្លាប់មានជម្ងឺដែររឬទេ ? បើមានអ្នកធ្វើដូចម្ដេច ?
៩. តើអ្នកមានចិញ្ចឹមប៉ុន្មាន ? ទាប៉ុន្មាន ? បើគ្មានហេតុអ្វី ?
១០. តើអ្នកចិញ្ចឹមដោយរបៀបណា ?
១១. តើអ្នកមានបញ្ហាចោទលើការចិញ្ចឹមមាន់ ទា ឬទេ ? បើមានអ្នកធ្វើដូចម្ដេច ?

## V. អំពីសេដ្ឋកិច្ច និង មុខរបរ

១. តើស្រូវរបស់អ្នកហូបគ្រប់ដែររឬទេ ? បើខ្វះ ខ្វះប៉ុន្មានខែ ?
២. ពេលខ្វះអ្នកធ្វើដូចម្ដេច ?
៣. តើពេលរដូវប្រាំងអ្នកធ្វើអ្វីខ្លះ ?
៤. បើរកឧស រកនៅឯណា ? រកដោយវិធីណា ."ប្រមូលមែកងាប់ ឬ កាប់ដើមឈើ" ?
៥. តើអ្នកមានមុខជំនាញអ្វីដែររឬទេ ?

## VI. អំពីការប្រើប្រាស់ប្រភពទឹក ឧស និង សំភារៈកសិកម្ម

១. តើអ្នកមានអណ្ដូងទឹកប្រើប្រាស់ផ្ទាល់ខ្លួនឬទេ ? បើគ្មានហេតុអ្វី ?
២. តើអណ្ដូងរបស់អ្នកអាចមានទឹកប្រើប្រាស់ពេញមួយឆ្នាំដែររឬទេ ?
៣. តើអណ្ដូងទឹករបស់អ្នកជំរៅប៉ុន្មាន ? បើរាក់ហេតុអ្វីមិនជីកអោយជ្រៅ ?
៤. តើបញ្ហាទឹកនៅក្នុងភូមិរបស់អ្នកយ៉ាងដូចម្ដេចដែរ ?
៥. តើអ្នកមានជីកស្រះដែររឬទេ ?
៦. តើអ្នកទៅរកឧសនៅឯណា ?
៧. តើពីផ្ទះរបស់អ្នកទៅកន្លែងរកឧសចម្ងាយប៉ុន្មាន ?
៨. តើអ្នកត្រូវចំណាយពេលប៉ុន្មានដើម្បីរកឧសក្នុងមួយសប្ដាហ៍ ?
៩. តើអ្នកមានយល់ថាឧសកាន់តែលំបាករក និង ឆ្ងាយទៅៗ ឬទេ ?

១០- តើអ្នកប្រើចង្ក្រានប្រភេទដូចម្តេច ?
១១- តើអ្នកមាននង្គ័លឬទេ ? ប៉ុន្មានគ្រឿង ?
១២- តើអ្នកមានរនាស់ឬទេ ? ប៉ុន្មានគ្រឿង ?
១៣- តើអ្នកមានរទេះគោឬទេ ? ប៉ុន្មានគ្រឿង ?
១៤- តើអ្នកមានកង់ឬទេ ? ប៉ុន្មានគ្រឿង ?
១៥- តើអ្នកមានម៉ូតូឬទេ ? ប៉ុន្មានគ្រឿង ?